មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍ប្រចាំឆមាសលើកទី៦៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា

ខែធ្នូ ឆ្នាំ២០១៣

USAID
ជំនួយពីពលរដ្ឋអាមេរិក

EAST . WEST MANAGEMENT INSTITUTE
Program on Rights and Justice (PRAJ)
កម្មវិធីសិទ្ធិ និង យុត្តិធម៌ ( ប្រាជ្ញ )

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

របាយការណ៍ស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ជាលទ្ធផលនៃការអនុវត្តន៍គម្រោងសង្កេតការណ៍សវនាការ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋានមានសិទ្ធិស្មើគ្នា និងទទួលបានអំណាច ដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេស។ ម.ស.ម.ក មានគោលបំណងចង់បាននីតិរដ្ឋ ជាជាងនិទណ្ឌភាពស្ថាប័នរឹងមាំ ជាជាងបុគ្គលខ្លាំង និងចង់បានសង្គមសេរីពហុបក្ស ដែលក្នុងនោះភាពចម្រុះត្រូវបានគេទទួលយក និងសាទរ ជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបព្រាបសកំពុងហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវបញ្ជាក់អំពីការទាមទារសេរីភាពនៅកម្ពុជា។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ម.ស.ម.ក ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ព្រមទាំងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមសូមទស្សនាគេហទំព័រ www.cchrcambodia.org។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ កើតចេញពីកិច្ចឧបត្ថម្ភគាំទ្រ ដោយសប្បុរសអំពីសំណាក់ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក ("ទ.អ.អ.ស.អ") និងវិទ្យាស្ថានគ្រប់គ្រងបូព៌ាបស្ចិមប្រទេស និងកិច្ចឧបត្ថម្ភគាំទ្រ ដោយសប្បុរសពីការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ ខ្លឹមសារនៃរបាយការណ៍នេះ គឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ ទ.អ.អ.ស.អ រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬ វិទ្យាស្ថានគ្រប់គ្រងបូព៌ា បស្ចិម ឬ ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។

## សំណួរ និង ការឆ្លើយតប

ប្រសិនបើលោកអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើលោកអ្នកចង់ផ្តល់យោបល់តប សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org។

របាយការណ៍នេះ និងការបោះពុម្ពផ្សាយផ្សេងៗរបស់ ម.ស.ម.ក អាចស្វែងរកបានតាមរយៈ www.cchrcambodia.org និងក៏អាចស្វែងរកបានផងដែរនៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជាដែលបង្ហោះដោយ ម.ស.ម.ក តាមរយៈ www.sithi.org។

ទិន្នន័យ ដែលបានសង្កេតទាំងអស់ក៏អាចស្វែងរកបាននៅលើប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការតាមរយៈ tmp.sithi.org ។

(cc) ២០១៣ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក
ខណ្ឌចម្ការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

# មាតិកា

**ការពន្យល់អត្ថន័យ** ........ 1
**ខ្លឹមសារសង្ខេប** ........ 3
**១.សេចក្តីផ្តើម** ........ 7
ក្របខណ្ឌច្បាប់នៅកម្ពុជា ........ 7
បរិបទនយោបាយ ........ 8
គោលបំណង ក្រុមគោលដៅ និងវិសាលភាពនៃរបាយការណ៍ ........ 9
**២. វិធីសាស្ត្រ** ........ 10
រយៈពេល និងទីតាំង ........ 10
ការផ្តោតលើការសង្កេតការណ៍ ........ 11
រចនាសម្ព័ន្ធ ........ 11
បុគ្គលិក និងការបណ្តុះបណ្តាល ........ 12
នីតិវិធីសង្កេតការណ៍សវនាការ ........ 13
ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ........ 13
ការវិភាគ និង កិច្ចពិភាក្សា ........ 14
**៣. ទិន្នន័យ និង ការវាយតម្លៃ** ........ 15
សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ........ 16
សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ........ 19
សិទ្ធិយល់ពីបទចោទប្រកាន់ ........ 25
ការពន្យល់ប្រាប់សិទ្ធិ ........ 31
សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី ........ 33
សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ ........ 34
សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស ........ 38
ភាពឯករាជ្យ ភាពមិនលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រម ........ 40
សិទ្ធិបង្ហាញភស្តុតាង ........ 44
សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព ........ 51
ហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល ........ 53
ការហាមឃាត់ប្រឆាំងនឹងការអនុវត្តន៍អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ........ 54
សវនាការពាក់ព័ន្ធនឹងអនីតិជន ........ 55
អនីតិជន-ភាពឯកជន ........ 56
អនីតិជន-ការឃុំខ្លួនបណ្តោះអាសន្ន ........ 58
អនីតិជន–ការផ្តន្ទាទោស ........ 60
**៤. សេចក្តីសន្និដ្ឋាន និង អនុសាសន៍** ........ 63
**៥. គន្ថនិទ្ទេស** ........ 67

នីតិអន្តរជាតិ ........ 67
នីតិជាតិ ........ 68
**៦. ឧបសម្ព័ន្ធ** ........ 73
ឧបសម្ព័ន្ធទី១៖ តារាងសង្កេតការណ៍ ........ 73
ឯកសារភ្ជាប់ទី១៖ ជនជាប់ចោទជាអនីតិជន ........ 90
ឧបសម្ព័ន្ធទី២៖ បញ្ជីច្បាប់ជាមូលដ្ឋាន ........ 95
ឧបសម្ព័ន្ធទី៣៖ ក្រមសីលធម៌មន្ត្រីសង្កេតការណ៍សវនាការ ........ 105

# តារាងតួលេខ


តួលេខទី១៖សវនាការដែលបានសង្កេត ............ 15
តួលេខទី២៖ ការប្រៀបធៀបចំនួនសរុបនៃសវនាការដែលបានសង្កេតជាមួយនឹងអំឡុងពេលរបាយការណ៍មុន ............ 16
តួលេខទី៣៖ សិទ្ធិទទួលបានសវនាការជាសាធារណៈ ............ 17
តួលេខទី៤៖ សិទ្ធិទទួលបានសវនាការជាសាធារណៈ៖ ការប្រៀបធៀបទិន្នន័យពីរបាយការណ៍មុននៃសវនាការដែលបានសង្កេតការណ៍ទាំងអស់ ............ 18
តួលេខទី៥៖ ការឃុំខ្លួនបណ្ដោះអាសន្ន ............ 21
តួលេខទី៦៖ ការឃុំខ្លួនបណ្ដោះអាសន្នលើសរយៈពេលកំណត់ដោយច្បាប់ ............ 22
តួលេខទី៧៖ សិទ្ធិយល់ពីបទចោទប្រកាន់ - នៅគ្រប់តុលាការទាំងអស់ដែលបានសង្កេត ............ 26
តួលេខទី៨៖ និន្នាការសរុបចំពោះសិទ្ធិយល់ដឹងពីប្រភេទនៃបទចោទប្រកាន់ ............ 28
តួលេខទី៩៖ ការពន្យល់ប្រាប់សិទ្ធិ ............ 31
តួលេខទី១០៖ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្ដី ............ 33
តួលេខទី១១៖ សិទ្ធិមានមេធាវី ............ 35
តួលេខទី១២៖ សិទ្ធិមានវត្តមានក្នុងសវនាការ ............ 37
តួលេខទី១៣៖ ការសន្មតជាមុនថាគ្មានទោស ............ 38
តួលេខទី១៤៖ ឯករាជ្យភាព ភាពមិនលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រម ............ 41
តួលេខទី១៥៖ វិជ្ជាជីវៈរបស់ចៅក្រម ការប្រើប្រាស់ទូរសព្ទដៃរបស់ចៅក្រមនៅក្នុងសវនាការ ............ 42
តួលេខ ១៦៖ ទិដ្ឋភាពទូទៅនៃការប្រើប្រាស់ទូរសព្ទដោយចៅក្រម ............ 43
តួលេខទី១៧៖ សិទ្ធិបង្ហាញភស្តុតាង ............ 45
តួលេខ១៨៖ ទិដ្ឋភាពទូទៅចំពោះសិទ្ធិបង្ហាញភស្តុតាង ............ 46
តួលេខទី១៩៖ សិទ្ធិហៅ និងសាកសួរសាក្សី ............ 46
តួលេខទី២០៖ សិទ្ធិទទួលបានការបង្ហាញយ៉ាងពេញលេញ ............ 50
តួលេខទី២១៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព ............ 51
តួលេខទី២២៖ ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដង ............ 53
តួលេខ២៣៖ ទិដ្ឋភាពនៃនិន្នាការចំពោះការហាមឃាត់ការកាត់ទោសទ្វេរដង ............ 54
តួលេខ២៤៖ ការហាមឃាត់ការអនុវត្តន៍អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ............ 55
តួលេខទី២៥៖ សវនាការពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជន ............ 56
តួលេខទី២៦៖ ភាពឯកជនក្នុងសវនាការរបស់អនីតិជន ............ 57
តួលេខទី២៧៖ ការឃុំខ្លួនបណ្ដោះអាសន្នលើអនីតិជន ............ 59
តួលេខ២៨៖ ការផ្ដន្ទាទោសអនីតិជន ............ 61
តួលេខ២៩៖ ទិដ្ឋភាពនៃការផ្ដន្ទាទោសអនីតិជន ............ 62

# ការពន្យល់អត្ថន័យ

| | |
|---|---|
| "តុលាការខេត្តបន្ទាយ-មានជ័យ" | សាលាដំបូងខេត្តបន្ទាយមានជ័យ |
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| "CAT" | អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឲ្យបាត់តម្លៃជាមនុស្ស |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍សវនាការ របស់មន្ត្រីសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ក្នុងការកត់ត្រាទិន្នន័យពេលសង្កេតការណ៍សវនាការ |
| សេចក្តីណែនាំ | សេចក្តីណែនាំសំខាន់ៗ ដើម្បីជួយមន្ត្រីសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឲ្យយល់ពីសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍សវនាការ |
| "ក.ក.ច.យ" | ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលកម្ពុជា |
| ក្រមសីលធម៌ | ឯកសារសង្ខេបស្តីពីកាតព្វកិច្ចនៃការមិនជ្រៀតជ្រែក មិនលម្អៀង និងរក្សាការសម្ងាត់ដែលតម្រូវឲ្យមន្ត្រីសង្កេតការណ៍សវនាការគោរពតាម |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| "អ.ស.ក" | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ជាប្រព័ន្ធដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រើសម្រាប់រក្សាទិន្នន័យ ដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍សវនាការ |
| របាយការណ៍ប្រចាំឆមាសទី១ | របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាប្រចាំឆមាសទី១ របស់ ម.ស.ម.ក ខែកក្កដា ឆ្នាំ២០១០ |
| អំឡុងពេលរបាយ-ការណ៍ទី១ | ការសង្កេតសវនាការចាប់ពីថ្ងៃទី១០ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ |
| របាយការណ៍ប្រចាំឆមាសទី២ | របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាប្រចាំឆមាសលើកទី២ នៅខែមីនា ឆ្នាំ២០១១ |
| អំឡុងពេលរបាយ-ការណ៍ទី២ | ការសង្កេតសវនាការចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ |
| របាយការណ៍ប្រចាំឆមាសទី៣ | របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាប្រចាំឆមាសលើកទី៣ របស់ ម.ស.ម.ក នៅខែមករា ឆ្នាំ២០១២ |
| អំឡុងពេលរបាយ-ការណ៍ទី៣ | ការសង្កេតសវនាការចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ |
| របាយការណ៍ប្រចាំឆមាសទី៤ | របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាប្រចាំឆមាសទី៤ របស់ ម.ស.ម.ក ខែមីនា ឆ្នាំ២០១២ |
| អំឡុងពេលរបាយ-ការណ៍ទី៤ | ការសង្កេតសវនាការចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ |

| | |
|---|---|
| របាយការណ៍ប្រចាំឆមាសទី៥ | របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាប្រចាំឆមាសទី៥ របស់ ម.ស.ម.ក ខែវិច្ឆិកា ឆ្នាំ២០១២ |
| អំឡុងពេលរបាយ-ការណ៍ទី៥ | ការសង្កេតសវនាការចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ |
| របាយការណ៍ប្រចាំឆមាសទី៦ | របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាប្រចាំឆមាសទី៦ របស់ ម.ស.ម.ក ខែធ្នូ ឆ្នាំ២០១៣ |
| អំឡុងពេលរបាយ-ការណ៍ទី៦ | ការសង្កេតសវនាការចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ |
| "ក.អ.ស.ព.ន" | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| តុលាការខេត្តកណ្តាល | សាលាដំបូងខេត្តកណ្តាល |
| "យុទ្ធសាស្ត្រ ក.ច.យ" | យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ |
| "ក.យ.ធ" | ក្រសួងយុត្តិធម៌ |
| "អ.ម.រ" | អង្គការមិនមែនរដ្ឋាភិបាល |
| "ODIHR" | ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស និងវិទ្យាស្ថានប្រជាធិបតេយ្យ |
| "OHCHR" | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| "OPCAT" | ពិធីសារជម្រើសភ្ជាប់នឹងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម |
| "OSCE" | អង្គការទទួលបន្ទុកសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ |
| តុលាការរាជធានីភ្នំពេញ | សាលាដំបូងរាជធានីភ្នំពេញ |
| "ប្រាជ្ញ" | កម្មវិធីសិទ្ធិ និងយុត្តិធម៌ |
| គម្រោង | គម្រោងសង្កេតការណ៍សវនាការនៅកម្ពុជា |
| "រ.ប.វ.ត" | រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ |
| តុលាការខេត្តរតនគិរី | សាលាដំបូងខេត្តរតនគិរី |
| របាយការណ៍ | របាយការណ៍ប្រចាំឆមាសស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា |
| "រ.រ.ក" | រាជរដ្ឋាភិបាលកម្ពុជា |
| មន្ត្រីសង្កេតការណ៍ | មន្ត្រីសង្កេតការណ៍សវនាការរបស់ម.ស.ម.ក |
| "ស.ស.ស.ម" | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| "អ.ស.ប" | អង្គការសហប្រជាជាតិ |
| "អ៊ុនតាក់" | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា |
| "ច្បាប់អ៊ុនតាក់" | បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ១៩៩២ |
| ទ.អ.អ.ស.អ | ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក |

# ខ្លឹមសារសង្ខេប

របាយការណ៍នេះ ("របាយការណ៍") គឺជាលទ្ធផលមួយនៃគម្រោងសង្កេតការណ៍សវនាការនៅកម្ពុជា ("គម្រោង") ដែលអនុវត្តដោយ ម.ស.ម.ក។ របាយការណ៍នេះបង្ហាញនិងវិភាគទិន្នន័យដែលប្រមូលបានពីការសង្កេតការណ៍សវនាការចំនួន ៣៥៤ ដែលជាប់ពាក់ព័ន្ធនឹងជនជាប់ចោទចំនួន ៧១៩ នាក់នៃបទល្មើសព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី ("តុលាការរាជធានីភ្នំពេញ") សាលាដំបូងខេត្តបន្ទាយមានជ័យ ("តុលាការខេត្តបន្ទាយមានជ័យ") និងសាលាដំបូងខេត្តរតនគិរី ("តុលាការខេត្តរតនគិរី") ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ ("អំឡុងពេលរបាយការណ៍ទី៦")។ នេះគឺជារបាយការណ៍ប្រចាំឆមាសលើកទី៦ របស់គម្រោង។

មន្ត្រីសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ចូលរួមសង្កេតការណ៍សវនាការក្នុងបទល្មើសព្រហ្មទណ្ឌនៅតុលាការរាជធានីភ្នំពេញ តុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី ជាប្រចាំថ្ងៃ ដោយប្រើតារាងសង្កេតការណ៍សវនាការដែលមានសំណួរប្រមាណជាង ៧០ ជាឧបករណ៍សម្រាប់វាស់ស្ទង់នូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសវនាការ និងចំពោះជនជាប់ចោទនីមួយៗ។

មកដល់បច្ចុប្បន្ននេះ ម.ស.ម.កបានចេញផ្សាយនូវរបាយការណ៍ប្រចាំឆមាសចំនួន ៥ លើករួចមកហើយ។ មុនការបោះពុម្ពរបាយការណ៍នីមួយៗ តុលាការដែលបានសង្កេតការណ៍ត្រូវបានផ្ដល់ឱកាសក្នុងឆ្លើយតបនឹងអ្វីដែលបានរកឃើញតាមរយៈកិច្ចប្រជុំជាមួយនឹងបុគ្គលិករបស់គម្រោង ដើម្បីអាចបញ្ចូលមតិយោបល់ទាំងនោះទៅក្នុងរបាយការណ៍ជាផ្លូវការ។ បន្ទាប់ពីការបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆមាសនីមួយៗ បុគ្គលិកគម្រោងសម្របសម្រួល និងជួបប្រជុំជាមួយតំណាងរបស់តុលាការដែលគម្រោងបានសង្កេត ព្រមទាំងអង្គការ អង្គភាព និងស្ថាប័ននានាដែលធ្វើការលើវិស័យយុត្តិធម៌ដទៃទៀត ដើម្បីពិភាក្សាដោះស្រាយនូវអនុសាសន៍ដែលបានលើកឡើងនៅក្នុងរបាយការណ៍។ កិច្ចប្រជុំនេះជាមូលដ្ឋានសម្រាប់ធ្វើការផ្លាស់ប្ដូរគំនិតគ្នា និងផ្ដល់លទ្ធភាពឲ្យយល់កាន់តែច្បាស់អំពីបញ្ហាប្រឈមទាំងឡាយ ដែលបានជួបប្រទះដោយស្ថាប័នដែលធ្វើការពង្រឹងប្រព័ន្ធយុត្តិធម៌។ កិច្ចប្រជុំពិភាក្សានេះមានគោលបំណងលើកកម្ពស់ និងជួយសម្រួលដល់ការអនុវត្តន៍អនុសាសន៍ទាំងឡាយ ដែលបានផ្ដល់ជូននៅក្នុងរបាយការណ៍ប្រចាំឆមាស។

ទិន្នន័យនៅក្នុងរបាយការណ៍នេះនឹងធ្វើការប្រៀបធៀបទិន្នន័យ ដែលប្រមូលបានពីសវនាការនៅតាមតុលាការរាជធានីភ្នំពេញ តុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី។ ទិន្នន័យដែលបានមកពីគ្រប់តុលាការទាំងអស់ត្រូវបានលើកយកមកបង្ហាញដោយធ្វើការប្រៀបធៀប និងការកំណត់ពីនិន្នាការក្នុងគោលបំណងកំណត់អំពីបញ្ហាដែលពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

ជាចំណុចវិជ្ជមានក្នុងការកត់សម្គាល់ឃើញថា មានបញ្ហាតិចតួចប៉ុណ្ណោះកើតឡើងពាក់ព័ន្ធនឹងរយៈពេល និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្ដីនៅក្នុងអំឡុងពេលរបាយការណ៍ទី៦នេះ។ នៅតុលាការរាជធានីភ្នំពេញ មានករណីរាយការណ៍តែមួយប៉ុណ្ណោះដែលមេធាវីការពារខាងចុងចោទត្រូវបានតុលាការប្រាប់ឲ្យការពារនៅថ្ងៃសវនាការតែម្ដង និងករណីរបៀបនេះមានបួនដែលបានកើតឡើងនៅ

តុលាការខេត្តបន្ទាយមានជ័យ។ ពុំមានរបាយការណ៍ដូចគ្នានេះមកពីតុលាការខេត្តរតនគិរីនោះទេ ដែលជាទូទៅបំពេញបានយ៉ាងប្រសើរក្នុងការអនុលោមតាមនីតិវិធីនៃការជំនុំជម្រះដោយយុត្តិធម៌។

ក៏មានសមិទ្ធិផលច្រើនដែរ ដែលបានសង្កេតឃើញនៅតុលាការខេត្តបន្ទាយមានជ័យ ដូចជាការដែលបានលុបបំបាត់ចោលនូវការអនុវត្តន៍លើអ្នកទោស ដែលបានចូលរួមសវនាការដោយពាក់ឯកសណ្ឋានជាអ្នកទោសស្ទើរតែទាំងស្រុងនៅក្នុងតុលាការ ហើយសវនាការទាំងអស់ដែលបានសង្កេតនៅតុលាការខេត្តបន្ទាយមានជ័យ ជនជាប់ចោទទាំងអស់បានបង្ហាញខ្លួនដោយពុំពាក់អាវជាអ្នកទោសនោះទេ។ ទោះជាយ៉ាងនេះក្តី ជនជាប់ចោទជាច្រើននៅតែបង្ហាញខ្លួននៅតុលាការក្នុងឯកសណ្ឋានជាអ្នកទោសក្នុងករណីជាច្រើននៅតុលាការរាជធានីភ្នំពេញ ដែលមាន ៨៣% នៃជនជាប់ចោទទាំងអស់ និងតុលាការខេត្តរតនគិរី ដែលមាន ៧០% នៃជនជាប់ចោទទាំងអស់។

កត្តាវិជ្ជមានបន្ថែមទៀតរួមមានអវត្តមាននៃសេចក្តីថ្លែងការណ៍របស់ចៅក្រមនៅតាមតុលាការ ដែលបានសង្កេតការណ៍ពាក់ព័ន្ធនឹងភាពគ្មានទោស ឬ ពិរុទ្ធភាពរបស់ជនត្រូវចោទមុនពេលសាលក្រមត្រូវបានប្រកាស ដោយរួមជាមួយនឹងហេតុដែលថាពុំមានការយល់ឃើញណាមួយដែលបង្ហាញថាចៅក្រមមានផលប្រយោជន៍នៅក្នុងរឿងក្តី ក្រៅតែពីតួនាទីតាមផ្លូវច្បាប់របស់គាត់នោះទេ។ ការប្រកាន់ខ្ជាប់ទៅនឹងបទដ្ឋាន និងនីតិវិធីក្នុងការទទួលបានសវនាការយុត្តិធម៌នេះ ដើម្បីពង្រឹងដល់ការគោរពគោលការណ៍សច្ចធារណ៍នៃនិរទោស។

ទាក់ទិននឹងសិទ្ធិបង្ហាញភស្តុតាង ជាទូទៅចៅក្រមអនុវត្តនីតិវិធីបានយ៉ាងត្រឹមត្រូវ ដោយមានតែមួយករណីដែលបានរាយការណ៍ប៉ុណ្ណោះ (នៅតុលាការរាជធានីភ្នំពេញ) ដែលភាគីត្រូវបានរារាំងមិនឲ្យសួរលើសាក្សី។

ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យក៏បង្ហាញបញ្ហាព្រួយបារម្ភមួយចំនួន និងស្នើទាក់ទងនឹងបទដ្ឋានទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួន មានការប្រសើរឡើងតិចតួច ឬហាក់ដូចជាពុំមានសោះចាប់តាំងពីអំឡុងពេលរបាយការណ៍ទី៥។ នៅខណៈដែលតុលាការ ជាពិសេសតុលាការខេត្តរតនគិរី ដែលបានលើកឡើងឲ្យមានអត្រានៃការប្រតិបត្តិតាម ១០០% ដែលជាទូទៅបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនដំណឹងដល់ជនជាប់ចោទអំពីប្រភេទនៃបទចោទប្រកាន់ ចៅក្រមនៅតែខកខានក្នុងការផ្តល់ការពន្យល់ដ៏ពេញលេញទៅដល់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគេ។ ឧទាហរណ៍ ពុំមានចៅក្រមណាម្នាក់នៅក្នុងករណីទាំងអស់នៃសវនាការ ដែលបានសង្កេតការណ៍បានពន្យល់ដល់ជនជាប់ចោទថាខ្លួនមានសិទ្ធិមិននិយាយស្តីនោះឡើយ។ ការខកខានបែបនេះគឺជាការគួរឲ្យបារម្ភជាពិសេស នៅគ្រាដែលកម្រិតនៃសិទ្ធិទទួលបានមេធាវីនៅតែទាបសម្រាប់ការចោទប្រកាន់ពីបទមជ្ឈិម និងនៅខណៈដែលអត្រា ១០០% នៃការទទួលបានមេធាវីសម្រាប់បទឧក្រិដ្ឋដែលជាការតម្រូវតាមផ្លូវច្បាប់មិនទាន់បានសម្រេចនៅឡើយ។ មានករណីចំនួន ៤ នៅតុលាការខេត្តបន្ទាយមានជ័យ ដែលជនជាប់ចោទប្រឈមនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋពុំត្រូវបានមេធាវីតំណាងតាមផ្លូវច្បាប់នោះទេ។ ជនជាប់ចោទទាំងអស់ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋនៅតុលាការខេត្តរតនគិរី និងតុលាការរាជធានីភ្នំពេញ គឺត្រូវបានមេធាវីតំណាងតាមផ្លូវច្បាប់។ កម្រិតនៃមេធាវីការពារនៅ

ក្នុងករណីបទមជ្ឈិមនៅតែមានអត្រាទាបគួរឲ្យបារម្ភ ដោយមានត្រឹមតែ ៣៣,៥% នៃជនជាប់ចោទទាំងអស់ត្រូវបានមេធាវីការពារនៅតុលាការរាជធានីភ្នំពេញ និងត្រឹមតែ ២១% នៅតុលាការខេត្តបន្ទាយមានជ័យ។ តុលាការខេត្តរតនគិរីមានការរីឌ្ឍន៍ប្រសើរជាងបន្តិចដោយមានចំនួន ៦១% នៃជនជាប់ចោទក្នុងបទមជ្ឈិមត្រូវបានមេធាវីការពារ។

កម្រិតនៃការឃុំខ្លួនបណ្តោះអាសន្ននៅតែមានខ្ពស់ ហើយចៅក្រមបន្តឃុំខ្លួនបុគ្គលជាច្រើនក្នុងករណីជាច្រើន។ នៅខណៈដែលមានភាពប្រសើរឡើងមួយចំនួននៅតុលាការខេត្តបន្ទាយមានជ័យ ដែលមានការកាត់បន្ថយក្នុងការប្រើប្រាស់វិធានការឃុំខ្លួនបណ្តោះអាសន្ន យើងឃើញថាតុលាការរាជធានីភ្នំពេញ និង តុលាការខេត្តរតនគិរី មានការកើនឡើងចំនួនភាគរយនៃករណី ដែលបានអនុវត្តវិធានការឃុំខ្លួនបណ្តោះអាសន្នដោយគិតចាប់តាំងពីអំឡុងពេលរបាយការណ៍មុន។ នៅក្នុងអំឡុងពេលរបាយការណ៍ទី៦ មន្ត្រីសង្កេតការណ៍របស់ ម.ស.ម.ក កត់សម្គាល់ឃើញថាមានករណីគួរឲ្យចាប់អារម្មណ៍ចំនួន ១៦ នៃការឃុំខ្លួនបណ្តោះអាសន្នលើស និងខុសច្បាប់។

ជាការគួរឲ្យសោកស្តាយផងដែរ ដែលចៅក្រមនៅតែបន្តប្រើប្រាស់ទូរសព្ទដៃរបស់ខ្លួននៅក្នុងពេលសវនាការ។ នៅតុលាការរាជធានីភ្នំពេញ មានចំនួន ១៩% ដែលចៅក្រមបានទទួលទូរសព្ទនិយាយក្នុងពេលសវនាការ ករណីដូចគ្នានេះមានចំនួន ២១% នៅតុលាការខេត្តបន្ទាយមានជ័យ និង ១៧% នៅតុលាការខេត្តរតនគិរី។ នៅខណៈដែលចំណុចនេះបង្ហាញពីភាពប្រសើរឡើងជាលំដាប់នៅពេលធ្វើការប្រៀបធៀបភាគរយនៃចៅក្រមបានទទួលទូរសព្ទនិយាយនៅក្នុងសវនាការទាំងអស់ ដែលបានសង្កេតការណ៍ក្នុងអំឡុងពេលរបាយការណ៍ទី៦ (ចំនួន ១៩%) និងសវនាការទាំងអស់ដែលបានសង្កេតការណ៍ក្នុងអំឡុងរបាយការណ៍ទី៥ (ចំនួន ២០%) ការបន្តប្រើប្រាស់ទូរសព្ទដៃដោយចៅក្រម ដែលបញ្ហានេះងាយស្រួលនឹងជៀសវៀងបាន ពុំបានធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់តុលាការបានប្រសើរឡើងឡើយ។

ក្នុងចំណោមសវនាការទាំងអស់ដែលបានសង្កេតការណ៍ក្នុងអំឡុងពេលរបាយការណ៍ទី៦នេះ មានចំនួន ៣ ករណីទាក់ទិននឹងការគំរាមកំហែងដែលកើតឡើងនៅតុលាការខេត្តបន្ទាយមានជ័យទាំងអស់ ដែលការគំរាមកំហែងត្រូវបានរាយការណ៍ថា បានធ្វើឡើងដើម្បីទទួលបានការសារភាព និងមានការចោទប្រកាន់ចំនួន ២៤ ករណីដែលបានប្រើប្រាស់ទម្រង់ផ្សេងៗនៃការប្រើហិង្សាលើរាងកាយ (ចំនួន ១៣ ករណីកើតឡើងនៅតុលាការរាជធានីភ្នំពេញ និងចំនួន ១១ ករណីកើតឡើងនៅតុលាការខេត្តបន្ទាយមានជ័យ)។

ទាក់ទិននឹងករណីជាប់ពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជន កម្រិតនៃការឃុំខ្លួនបណ្តោះអាសន្ននៅតែមានខ្ពស់ដែលពុំអាចទទួលយកបាន។ ពុំមានករណីណាមួយដែលជាប់ពាក់ព័ន្ធនឹងអនីតិជនក្នុងចំណោមសវនាការទាំងអស់ដែលបានសង្កេតការណ៍នៅខេត្តរតនគិរីនោះឡើង រីឯនៅតុលាការរាជធានីភ្នំពេញ ការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជនមានចំនួន ៩២% នៃករណីទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងអនីតិជន និងនៅតុលាការខេត្តបន្ទាយមានជ័យមានចំនួន ៩០% នៃករណីទាំងអស់ ដែលបញ្ហានេះបង្ហាញពីការគួរឲ្យព្រួយបារម្ភថា ជនជាប់ចោទជាអនីតិជន គឺហាក់ដូចជាងាយនឹងត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន ជាងជនជាប់ចោទជានីតិជន។

ក្នុងចំណោមជនជាប់ចោទជាអនីតិជនទាំងអស់ ដែលត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ គ្រប់អនីតិជនត្រូវទទួលទោសក្នុងពន្ធនាគារភ្លាមៗ។ មានតែ ១ ករណីប៉ុណ្ណោះ ដែលចៅក្រមបានពិចារណាលើការអនុវត្តន៍ទោសឲ្យនៅក្រៅឃុំសម្រាប់ជនប្រព្រឹត្តល្មើសជាអនីតិជនម្នាក់ ហើយក្នុងសំណុំរឿងនេះចៅក្រមបានសម្រេចដាក់ទោសចំនួន ៦ ខែក្នុងពន្ធនាគារ និងទោសព្យួរសាកល្បងចំនួន ៣ ឆ្នាំ ដែលប្រសើរជាងការជាប់ក្នុងពន្ធនាគារចំនួន ៣ ឆ្នាំ និង ៦ ខែ។

អនុសាសន៍ក្នុងរបាយការណ៍នេះត្រូវបានផ្តល់ជូនទៅអង្គភាព និងស្ថាប័នផ្សេងៗដោយបង្ហាញអំពីភាពជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមកនៃស្ថាប័នទាំងនោះនៅក្នុងប្រព័ន្ធយុត្តិធម៌។ ប្រសិនជានឹងមានចំណុចសំខាន់ៗដែលត្រូវធ្វើឲ្យប្រសើរឡើងក្នុងការប្រកាន់ខ្ជាប់នូវបទដ្ឋាននៃការទទួលបានសវនាការយុត្តិធម៌ ដូច្នេះជាការចាំបាច់ណាស់ ដែលថាបណ្តាដៃគូដែលពាក់ព័ន្ធទាំងអស់នឹងធ្វើការរួមគ្នា ដើម្បីឆ្ពោះទៅសម្រេចគោលដៅរួម។ ការធ្វើឲ្យប្រសើរឡើងទាំងនេះនឹងអាស្រ័យលើកិច្ចសហប្រតិបត្តិការ និងការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ("រ.រ.ក") ក្រសួងយុត្តិធម៌ ("ក.យ.ធ") អាជ្ញាធរអនុវត្តច្បាប់ អាជ្ញាធរពន្ធនាគារ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល ("អ.ម.រ") និងស្ថាប័នដទៃទៀតដែលពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ យើងសង្ឃឹមថា ទិន្នន័យ ការវិភាគ និងអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍នេះនឹងអាចជួយបង្កើននូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងគាំទ្រកិច្ចការទាំងនោះ ដើម្បីធានាថា ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាអាចផ្តល់យុត្តិធម៌ និងសមភាពដល់បុគ្គលគ្រប់រូប។

# ១.សេចក្ដីផ្ដើម

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសិទ្ធិមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល និងស្ថិតនៅកម្រិតខ្ពស់បំផុតក្នុងច្បាប់អន្តរជាតិរបស់មហាសន្និបាតអង្គការសហប្រជាជាតជាតិ ទាំងនៅក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ("ស.ស.ស.ម")[1] និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។[2] សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ")[3] និងត្រូវបានធានាដោយបទប្បញ្ញត្តិមួយចំនួនទៀតនៅក្នុងច្បាប់ជាតិ។[4]

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌រួមបញ្ចូលនូវសិទ្ធិផ្សេងៗគ្នាមួយចំនួនរបស់មនុស្សម្នាក់ៗ ដែលចាប់ផ្ដើមពីសិទ្ធិទាក់ទងនឹងនីតិវិធីមុនសវនាការ ដូចជាការចាប់ខ្លួន និងការសួរចម្លើយ រហូតទៅដល់សិទ្ធិទាក់ទិននឹងការជំនុំជម្រះផ្ទាល់តែម្ដង ដូចជាសិទ្ធិទទួលបានសវនាការជាសាធារណៈ ក៏ដូចជាសិទ្ធិទូលំទូលាយជាងនេះទៀត តួយ៉ាងសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាផ្នែកដ៏សំខាន់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ហើយដែលផ្ដល់ឲ្យបុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទទួលបាននូវការអនុវត្តន៍ដោយយុត្តិធម៌ និងស្មើភាពគ្នា នៅគ្រាដែលអាជ្ញាធររដ្ឋកំណត់ពីពិរុទ្ធភាព ឬនិរទោសរបស់ពួកគេ។ នៅពេលមានការអនុវត្តន៍យ៉ាងត្រឹមត្រូវហើយនោះ សិទ្ធិរបស់ជនជាប់ចោទ និងជនរងគ្រោះត្រូវបានគោរព ហើយធានាអំពីការគ្រប់គ្រប់វិស័យយុត្តិធម៌មួយដ៏ត្រឹមត្រូវ។

## ក្របខណ្ឌច្បាប់នៅកម្ពុជា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ធានានូវឯករាជ្យភាពរបស់តុលាការ ព្រមទាំងសិទ្ធិសន្មតទុកជាមុនថាគ្មានទោសរហូតដល់ពេលពិរុទ្ធភាពត្រូវបានរកឃើញ។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ចែងអំពីនីតិវិធីនៃការស៊ើបសួរ និងនីតិវិធីសវនាការបទល្មើសព្រហ្មទណ្ឌ ព្រមទាំងបទប្បញ្ញត្តិមួយចំនួនទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ដែលត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ២០០៩ និងចូលជាធរមានទាំងស្រុងនៅខែធ្នូ ឆ្នាំ២០១០ បញ្ញត្តអំពីប្រភេទបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្ដន្ទាទោស។ ប្រទេសកម្ពុជាក៏ត្រូវបានចងភ្ជាប់កាតព្វកិច្ចដោយកិច្ចព្រមព្រៀងអន្តរជាតិដែលខ្លួនជាភាគីផងដែរ។ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងកតិកាសញ្ញាអន្តរជាតិស្ដី

---

[1] មហាសន្និបាតអង្គការសហប្រជាជាតិ- មាត្រា១០ នៃ *សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស* ចុះថ្ងៃទី១០ខែធ្នូឆ្នាំ១៩៤៨។

[2] មហាសន្និបាតអង្គការសហប្រជាជាតិ- មាត្រា១៤ នៃ *កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ចុះថ្ងៃទី១៦ខែធ្នូ ឆ្នាំ១៩៦៦។

[3] មាត្រា៣១នៃរដ្ឋធម្មនុញ្ញធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមរយៈការរួមបញ្ចូលសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអនុសញ្ញាអន្តរជាតិដទៃទៀត រួមទាំង កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយទៅក្នុងអត្ថបទរបស់ខ្លួន។មាត្រា៣៨និងមាត្រា១២៨នៃរដ្ឋធម្មនុញ្ញក៏បានធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដទៃទៀតផងដែរ។

[4] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងអំពីសិទ្ធិមួយចំនួននៅក្នុងនីតិវិធីដែលជួយធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។ឧទាហរណ៍៖ មាត្រា៣០០ ចែងថាជនជាប់ចោទត្រូវអមដោយមេធាវីដែលខ្លួនបានជ្រើសរើស។

ពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") សុទ្ធតែជានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយសាលាជម្រះក្តីមួយឯករាជ្យ និងមិនលម្អៀង។

ប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជារួមបញ្ចូលផងដែរនូវដំណើរការនៃការស៊ើបសួរ។ ប្រព័ន្ធតុលាការត្រូវបានបង្កើតឡើងដោយរួមមានសាលាដំបូងរាជធានី ១ និងសាលាដំបូងខេត្តចំនួន ២៣ តុលាការយោធាចំនួន ១ សាលាឧទ្ធរណ៍ចំនួន ១ និងតុលាការកំពូល។ នៅឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ("អ.ស.ប") បានព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់ទោសអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើសាហាវយង់ឃ្នងដែលប្រព្រឹត្តដោយខ្មែរក្រហម។

រដ្ឋធម្មនុញ្ញបញ្ញត្តថា ប្រទេសកម្ពុជា *"ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចដែលមានចែងក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ កតិកាសញ្ញា និងអនុសញ្ញាទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"*។[5] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់អំពីស្មារតីនៃរដ្ឋធម្មនុញ្ញ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលលើកឡើងថា *"អនុសញ្ញាអន្តរជាតិទាំងឡាយដែលប្រទេសកម្ពុជាបានទទួលស្គាល់"* បង្កើតជាផ្នែកមួយនៃច្បាប់ដែលចៅក្រមជំនុំជម្រះត្រូវតែគោរព។[6] ម្យ៉ាងវិញ មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញក៏ចែងអំពីឯករាជ្យភាព និងភាពឥតលម្អៀងរបស់តុលាការកម្ពុជា៖ *"អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានា រក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"*។ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានអនុម័តក្នុងឆ្នាំ២០០៧ ប្រមូលផ្តុំ និងចងក្រងជាក្រមនៃបទប្បញ្ញត្តិមុនៗទាក់ទិននឹងនីតិវិធីនៃប្រព័ន្ធតុលាការ និងព្រហ្មទណ្ឌ ដែលត្រូវបានបញ្ញត្តនៅក្នុងច្បាប់កាលពីរដ្ឋាភិបាលនៃសម័យអន្តរកាល។[7] ក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តយ៉ាងលម្អិតអំពីនីតិវិធីទាំងឡាយដែលត្រូវតែគោរពតាមក្នុងការស៊ើបអង្កេត សវនាការ និងបណ្តឹងឧបាស្រ័យនានា។

នៅក្នុងខែធ្នូ ឆ្នាំ២០១០ ក្រមព្រហ្មទណ្ឌបានចូលជាធរមាន ដែលចែងអំពីបណ្តុំនៃបទល្មើសព្រហ្មទណ្ឌថ្មីៗជាច្រើន ការចាត់ថ្នាក់បទល្មើស និងគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ យុត្តាធិការដែនដី និងការផ្តន្ទាទោស។

## បរិបទនយោបាយ

នៅក្នុងខែមិថុនា ឆ្នាំ២០០៣ គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល បានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ("យុទ្ធសាស្ត្រ")។[8] យុទ្ធសាស្ត្រនេះចង្អុលបង្ហាញគោលការណ៍ណែនាំសំខាន់ៗបួនដែលមានចែងក្នុងបទប្បញ្ញត្តិមួយចំនួននៃរដ្ឋធម្មនុញ្ញ ដើម្បីឈានឆ្ពោះទៅរកកំណែទម្រង់ច្បាប់ និងប្រព័ន្ធ

---

[5] មាត្រា៣១នៃរដ្ឋធម្មនុញ្ញ។

[6] សេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ នៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

[7] បទប្បញ្ញត្តិទាក់ទងនឹងប្រព័ន្ធតុលាការ ច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ អនុវត្តក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ("ច្បាប់អ៊ុនតាក់")។

[8] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ៖ *យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ* ដែល រ.រ.ក បានអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥។

យុត្តិធម៌៖ សិទ្ធិសេរីភាពបុគ្គល លទ្ធិប្រជាធិបតេយ្យសេរី ការបែងចែងអំណាច និងនីតិរដ្ឋ។[9] នៅក្នុងយុទ្ធសាស្ត្រនេះក៏មានកំណត់គោលដៅយុទ្ធសាស្ត្រចំនួន ៧ ផងដែរ ដែលបង្កើតបានជាមូលដ្ឋាននៃផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលក្រោយមកត្រូវបានអនុម័តកាលពីឆ្នាំ២០០៥។[10]

គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ("គម្រោង") ជាអ្នកសង្កេតការណ៍ឯករាជ្យ និងឥតលម្អៀងលើសវនាការព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីខែសីហា ឆ្នាំ២០០៩។ នៅក្នុងតួនាទីនេះ គោលបំណងរបស់គម្រោង គឺប្រមូលទិន្នន័យដែលអាចយកមកធ្វើការវិភាគ ដើម្បីធ្វើកំណត់បង្ហាញពីចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងប្រព័ន្ធយុត្តិធម៌។ តាមរយៈការយកចិត្តទុកដាក់ទៅលើផ្នែកនានានៅក្នុងដំណើរការសវនាការ ដែលទាមទារឲ្យមានការចាប់អារម្មណ៍ជាខ្លាំង និងធ្វើការផ្តល់អនុសាសន៍ជាក់ស្តែងដែលអាចអនុវត្តបានទៅដល់ស្ថានប័នពាក់ព័ន្ធនានាក្នុងវិស័យយុត្តិធម៌ ម.ស.ម.ក គាំទ្រនូវកិច្ចខិតខំទាំងឡាយដើម្បីពង្រឹង និងធ្វើកំណែទម្រង់លើប្រព័ន្ធយុត្តិធម៌សម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់។

## គោលបំណង ក្រុមគោលដៅ និង វិសាលភាពនៃរបាយការណ៍

នេះគឺ ជារបាយការណ៍ប្រចាំឆមាសលើកទី៦ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ដែលបានធ្វើឡើងដោយគម្រោងនេះ។ មុនពេលដែលរបាយការណ៍នេះត្រូវបានបញ្ចប់ និងបោះពុម្ពផ្សាយ សេចក្តីព្រាងរបាយការណ៍ត្រូវបានផ្ញើទៅប្រធានតុលាការរាជធានីភ្នំពេញ ប្រធានតុលាការខេត្តបន្ទាយមានជ័យ និងប្រធានតុលាការខេត្តរតនគិរី។ គោលបំណងនៃការផ្ញើសេចក្តីព្រាងនៃរបាយការណ៍ទៅតុលាការទាំងឡាយដែលបានសង្កេតការណ៍ គឺផ្តល់ឱកាសដល់តុលាការទាំងនោះក្នុងការឆ្លើយតប និងការផ្តល់មតិយោបល់ផ្សេងអំពីអ្វីដែលបានរកឃើញនៅក្នុងរបាយការណ៍ ព្រមទាំងអនុញ្ញាតឲ្យតុលាការទាំងនោះអាចផ្តល់អនុសាសន៍បន្ថែមទៀត។

របាយការណ៍ប្រចាំឆមាសលើកទី១ ("របាយការណ៍ប្រចាំឆមាសលើកទី១") ត្រូវបានបោះពុម្ពផ្សាយកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ របាយការណ៍ប្រចាំឆមាសលើកទី២ ("របាយការណ៍ប្រចាំឆមាសលើក ទី២") ត្រូវបានបោះពុម្ពផ្សាយកាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ របាយការណ៍ប្រចាំឆមាសលើកទី៣ ("របាយការណ៍ប្រចាំឆមាសលើកទី៣") ត្រូវបានបោះពុម្ពផ្សាយកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១២ របាយការណ៍ប្រចាំឆមាសលើកទី៤ ("របាយការណ៍ប្រចាំឆមាសលើកទី៤") ត្រូវបានបោះពុម្ពផ្សាយកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ របាយការណ៍ប្រចាំឆមាសលើកទី៥ ("របាយការណ៍ប្រចាំឆមាសលើកទី៥") ត្រូវបានបោះពុម្ពផ្សាយកាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១២។

រចនាសម្ព័ន្ធនៃរបាយការណ៍នេះមានលក្ខណៈដូចតទៅ៖

ផ្នែកទី២ បង្ហាញអំពីវិធីសាស្ត្រដែលនឹងត្រូវអនុវត្តនៅពេលប្រមូលទិន្នន័យ និងរៀបចំរបាយការណ៍។

---

[9] យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ទំព័រទី៣។

[10] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ៖ *ផែនការសកម្មភាពសម្រាប់ការអនុវត្តន៍យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ* ដែល រ.រ.ក បានអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥។

ផ្នែកទី៣ "ទិន្នន័យ និងការរកឃើញ" បង្ហាញពីទិន្នន័យ ដែលប្រមូលបានពីតុលាការចំនួន ៣ ចាប់ ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ ក្នុងគោលបំណងកំណត់អំពីនិន្នាការនៃការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

ផ្នែកទី៤ "សេចក្តីសន្និដ្ឋាន និងអនុសាសន៍" គឺការផ្តល់នូវអនុសាសន៍លើបញ្ហាដែលពាក់ព័ន្ធទៅនឹងផ្នែកដែលបានរកឃើញ។

គោលបំណងនៃរបាយការណ៍គឺដើម្បីផ្តល់នូវការវិភាគនិន្នាការ ដែលកើតចេញពីតុលាការព្រហ្មទណ្ឌរបស់កម្ពុជា ធ្វើការប្រៀបធៀបទៅនឹងរបាយការណ៍មុនៗ ដើម្បីវាស់វែងកម្រិតនៃប្រសិទ្ធភាពដែលបានអនុវត្តអនុសាសន៍ពីមុន ព្រមទាំងដើម្បីបង្កើតជាវេទិកាមួយ ដែលអាចលើកឡើងពីអនុសាសន៍បន្ថែមទៀត និងអនុវត្តឲ្យរឹតតែប្រសើរឡើង។

# ២. វិធីសាស្រ្ត

គម្រោងនេះត្រូវបានអនុវត្តដោយ ម.ស.ម.ក ដែលជាផ្នែកមួយនៃកម្មវិធីគោលនយោបាយ និងការតស៊ូមតិ។ គម្រោងនេះត្រូវបានអនុវត្ត និងរបាយការណ៍ត្រូវបានសរសេរបន្ទាប់ពីវិធីសាស្រ្តដែលបានកំណត់ក្នុងជំពូកនេះ។ គោលបំណងនៃការចែករំលែកវិធីសាស្រ្តនេះជាមួយនឹងអង្គការដទៃទៀត គឺដើម្បីអាចជួយបង្កើននូវកិច្ចសហប្រតិបត្តិការនៅក្នុងផ្នែកសង្កេតការណ៍សវនាការ និងដើម្បីសម្រួលដល់កិច្ចពិភាក្សារវាងបណ្តាដៃគូទាំងអស់ ដែលខិតខំឲ្យមានការគោរព និងការប្រកាន់ខ្ជាប់ឲ្យរឹតតែខ្លាំងឡើងចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅប្រទេសកម្ពុជា។

## រយៈពេល និង ទីតាំង

របាយការណ៍នេះបង្ហាញ និងវិភាគទិន្នន័យដែលបានមកពីសវនាការរឿងក្តីព្រហ្មទណ្ឌចំនួន ៣៥៤ ដែលមានជនជាប់ចោទចំនួន ៧១៩ នាក់។ សវនាការទាំងនេះត្រូវបានសង្កេតនៅឯតុលាការរាជធានីភ្នំពេញ តុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី ក្នុងអំឡុងពេលរបាយការណ៍ទី៦ (ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២)។ តុលាការរាជធានីភ្នំពេញត្រូវបានជ្រើសរើសជាគោលដៅនៃគម្រោង ព្រោះជាតុលាការដែលស្ថិតនៅក្នុងរាជធានី និងមានវិសាលភាពធំ ព្រមទាំងជាតំបន់ដែលមានប្រជាជនច្រើនជាងគេនៅប្រទេសកម្ពុជា តុលាការនេះមានចំនួនរឿងក្តីច្រើនជាងតុលាការដទៃទៀត ហើយការប្រព្រឹត្តទៅរបស់តុលាការនេះត្រូវបានរាយការណ៍យ៉ាងទូលាយ និងជាទូទៅមានឥទ្ធិពលខ្លាំងជាងតុលាការដទៃទៀតនៅប្រទេសកម្ពុជា។ តុលាការរាជធានីភ្នំពេញត្រូវបានធ្វើការសង្កេតគ្រប់របាយការណ៍ប្រចាំឆមាសមុនៗទាំងអស់អំពីសិទ្ធិទទួលបានការជំនុំជំម្រះដោយយុត្តិធម៌។

ការសង្កេតការណ៍សវនាការនៅតុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី បានចាប់ផ្តើមនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ដើម្បីពង្រីកនូវការផ្តោតការយកចិត្តទុកដាក់ទៅលើភូមិសាស្រ្តនៃការសង្កេតការណ៍ និងដើម្បីធ្វើការប្រៀបធៀបនូវនិន្នាការ និងការអនុវត្តន៍រវាងតុលាការដែលមានទីតាំងសង្គមសេដ្ឋកិច្ចខុសៗគ្នា។ តុលាការខេត្តបន្ទាយមានជ័យត្រូវបានជ្រើសរើស ដោយសារមានទីតាំងភូមិសាស្រ្តនៅជាប់នឹងព្រំដែនដែលមានសកម្មភាពពាណិជ្ជកម្មមាញឹកច្រើន។ តុលាការនេះក៏ដើរតួនាទីយ៉ាងសំខាន់ដែរ

ក្នុងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល។ តុលាការខេត្តរតនគិរីត្រូវបានជ្រើសរើសក៏ព្រោះតែទីតាំងភូមិសាស្ត្រ និងភាពដាច់ស្រយាលរបស់ខេត្តនេះ អាចឲ្យមានការពិនិត្យមើលទៅលើភាពខុសប្លែកគ្នាក្នុងការអនុវត្តន៍របស់តុលាការដែលនៅឆ្ងាយពីរាជធានី បើសិនជាមាន។ ទាំងតុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី សុទ្ធតែធ្លាប់បានធ្វើការសង្កេតពីមុនមកដោយគម្រោង (តុលា-ការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី ត្រូវបានសង្កេតក្នុងរបាយការណ៍ទី៥)។

## ការផ្តោតលើការសង្កេតការណ៍

ការសង្កេតការណ៍សវនាការផ្តោតលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួន។ ដើម្បីកំណត់ថាសិទ្ធិណាខ្លះត្រូវបានលើកយកមកថ្លឹងថ្លែង ម.ស.ម.ក ពឹងផ្អែកលើប្រភពពីខាងក្រៅដូចជារបាយ-ការណ៍ និងការសិក្សាស្រាវជ្រាវផ្សេងៗអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា និងអំពីប្រព័ន្ធយុត្តិធម៌កម្ពុជា។ ពុំមានការសន្និដ្ឋានវិជ្ជមាន ឬ អវិជ្ជមានណាមួយត្រូវបានទាញចេញពីការបំភ្លេចសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដទៃទៀត ដែលស្ថិតនៅក្នុងរបាយការណ៍នេះឡើយ។

សិទ្ធិខាងក្រោមត្រូវបានជ្រើសរើសសម្រាប់គោលបំណងនៃការសង្កេតការណ៍៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល
- សិទ្ធិយល់ដឹងអំពីបទចោទប្រកាន់
- សិទ្ធិទទួលបានការពន្យល់ប្រាប់សិទ្ធិដល់ជនជាប់ចោទ
- សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការការពារក្តី
- សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀង
- សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាកស្សី)
- សិទ្ធិទទួលដឹងឮភស្តុតាងសម្រាប់រៀបចំការពារខ្លួន
- សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង និងសិទ្ធិមិនសារភាពទោសដែលកើតចេញពីការបង្ខិតបង្ខំ ឬលួងលោម។
- ការហាមឃាត់ប្រឆាំងទៅនឹងការអនុវត្តន៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (ត្រូវបានជំនុំជម្រះចំពោះបទល្មើសដែលអំពើនោះមិនមែនជាបទល្មើសក្នុងពេលដែលសកម្មភាពនោះត្រូវបានប្រព្រឹត្ត) និង
- សិទ្ធិជនជាប់ចោទជាអនីតិជន។

## រចនាសម្ព័ន្ធ

ដើម្បីឲ្យការកត់ត្រាទិន្នន័យពាក់ព័ន្ធនឹងការជំនុំជម្រះឲ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ ម.ស.ម.ក បានបង្កើតតារាងសង្កេតការណ៍សវនាការ ("តារាងសង្កេតការណ៍") សម្រាប់ឲ្យមន្ត្រីសង្កេតការណ៍ប្រើប្រាស់នៅក្នុងតុលាការ (ឧបសម្ព័ន្ធទី១)។ តារាងសង្កេតការណ៍នេះត្រូវបានបង្កើតស្របតាមបរិបទរបស់គម្រោង និងមានសំណួរប្រមាណជាង ៧៨ ដែលចម្លើយទៅនឹងសំណួរទាំងនេះនឹងបង្ហាញថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដោយតុលាការដែរឬទេ។ សំណួរភាគច្រើនមានចម្លើយ ៤ ប្រភេទដូចជា៖ "មាន" "គ្មាន" "មិនពាក់ព័ន្ធ" ឬ "មិនដឹង"។ ម.ស.ម.ក ក៏បង្កើតឧបសម្ព័ន្ធមួយទំព័រភ្ជាប់ទៅនឹង

តារាងសង្កេតការណ៍សម្រាប់ការប្រើប្រាស់ក្នុងសវនាការដែលមានជនជាប់ចោទជាអនីតិជន (ឯកសារភ្ជាប់ទី១)។ តាមរយៈតារាងសង្កេតការណ៍នេះ មន្ត្រីសង្កេតការណ៍ធ្វើការសង្កេតលើការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពេញមួយសវនាការ និងសង្កេតលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទម្នាក់ៗ។ ទិន្នន័យដែលបានផ្តល់នៅក្នុងតារាងក្នុងផ្នែកទី៣ បង្ហាញពីការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលទាក់ទងទៅនឹងជនជាប់ចោទលើកលែងតែមានកំណត់ផ្សេងពីនេះ។

មន្ត្រីសង្កេតការណ៍ត្រូវបានផ្តល់ជូននូវបញ្ជីច្បាប់ (ឧបសម្ព័ន្ធទី២) ដែលគូសបញ្ជាក់អំពីច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនានា ដែលជួយពង្រឹងដល់សំណួរនីមួយនៅក្នុងតារាងសង្កេតការណ៍។ ឧបករណ៍នេះអាចផ្តល់នូវភាពងាយស្រួលក្នុងការយោងច្បាប់ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នីមួយៗ ដែលបានសង្កេតការណ៍។

ម.ស.ម.ក ប្តេជ្ញាគោរពតាមគោលការណ៍អន្តរជាតិ ដែលអនុវត្តចំពោះការសង្កេតការណ៍សវនាការ[11] និងបានបង្កើតនូវក្រមសីលធម៌សម្រាប់មន្ត្រីសង្កេតការណ៍របស់ខ្លួន ("ក្រមសីលធម៌") (ឧបសម្ព័ន្ធទី៣)។ ក្រមសីលធម៌សម្រាប់មន្ត្រីសង្កេតការណ៍ គូសបញ្ជាក់ពីកាតព្វកិច្ចមិនប្រៀតប្រៀក ភាពមិនលម្អៀង និងការរក្សាការសម្ងាត់ ដែលមន្ត្រីសង្កេតការណ៍ត្រូវគោរពតាម ។

ចំណុចចុងក្រោយ ដោយសារតែយល់ឃើញថា តារាងសង្កេតការណ៍សវនាការមានលក្ខណៈសង្ខេបយ៉ាងខ្លីនោះ ម.ស.ម.ក បានចងក្រងសេចក្តីណែនាំប្រកបដោយខ្លឹមសារងាយយល់ ("សេចក្តីណែនាំស្តីពីតារាងសង្កេតការណ៍") ដើម្បីធានាឲ្យមានការបកស្រាយរួមមួយសម្រាប់សំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍ព្រមទាំងការយល់ដឹងអំពីមូលដ្ឋានច្បាប់ និងគោលបំណងនៃសំណួរនីមួយៗ។ សេចក្តីណែនាំនេះមានសារៈសំខាន់ជាខ្លាំងក្នុងការធានាអំពីការយល់ដឹងច្បាស់លាស់នូវសំណួរនីមួយៗ និងធានាអំពីភាពស៊ីសង្វាក់គ្នាក្នុងចំណោមមន្ត្រីសង្កេតការណ៍សវនាការទាំងពេលបច្ចុប្បន្ន និងអនាគត។

## បុគ្គលិក និង ការបណ្តុះបណ្តាល

នៅក្នុងអំឡុងពេលរបាយការណ៍ ក្រុមការងាររបស់គម្រោងមានមន្ត្រីសង្កេតការណ៍ចំនួន ៣ នាក់ ដែលពោរពេញទៅដោយគុណសម្បត្តិ ជំនាញឯកទេស និងចំណេះដឹងផ្នែកច្បាប់។ អ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ជាតិ និងអន្តរជាតិផ្តល់ជំនួយគាំទ្រដល់ក្រុមមន្ត្រីសង្កេតការណ៍។ ដូចបានកត់សម្គាល់ខាងលើ មន្ត្រីសង្កេតការណ៍ត្រូវគោរពតាមក្រមសីលធម៌។ មុនពេលសង្កេតការណ៍សវនាការចាប់ផ្តើម មន្ត្រីសង្កេតការណ៍ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលយ៉ាងហ្មត់ចត់ទាំងផ្នែកទ្រឹស្តី និងការអនុវត្តន៍ ដែលរួមមានការបណ្តុះបណ្តាលស្តីពី៖

- ការសង្កេតការណ៍សវនាការ និងការប្រើប្រាស់តារាងសង្កេតការណ៍ក្រមសីលធម៌

[11] សូមមើល៖ អង្គការលើកលែងទោសអន្តរជាតិ *សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ* (ទីក្រុងឡុង៍៖ បោះពុម្ពផ្សាយដោយអង្គការលើកលែងទោសអន្តរជាតិឆ្នាំ១៩៩៨)AI Index POL ៣០/កុម្ភៈ/៩៨។ ដើលៃនណា ភីជីក និង វ៉ានីសា លេសនី *អ្វីទៅជាការជំនុំជម្រះដោយយុត្តិធម៌៖សេចក្តីណែនាំជាមូលដ្ឋានស្តីពីបទដ្ឋាន និងការអនុវត្តន៍ច្បាប់* ទីក្រុងញ៉ូវយ៉ក៖គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្សឆ្នាំ២០០០។ អង្គការសន្តិសុខនិងសហប្រតិបត្តិការអឺរ៉ុប (OSCE) /ការិយាល័យវិទ្យាស្ថានលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស (ODIHR) *សង្កេតការណ៍សវនាការ៖ សៀវភៅមគ្គុទេសក៏សម្រាប់អ្នកអនុវត្ត*(ទីក្រុងប៉ូឡូញ៖ OSCE/ ODIHR ឆ្នាំ២០០៨)។ បាបារ៉ា អូលីវើរ៉ា និង លីនដា បេសារាទី ម៉ូរ៉ាអេដ *សៀវភៅសង្កេតការណ៍សវនាការនៃគណៈកម្មការអ្នកច្បាប់អន្តរជាតិ* (ទីក្រុងហ្សឺណែវ៖ គណៈកម្មការអ្នកច្បាប់អន្តរជាតិឆ្នាំ២០០២)។

- ក្រមសីលធម៌ និងសារៈសំខាន់នៃភាពមិនលម្អៀង ការមិនជ្រៀតជ្រែក ការរក្សាការសម្ងាត់ និងលក្ខណៈវិជ្ជាជីវៈ និង
- បទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ក្នុងច្បាប់ជាតិ និងអន្តរជាតិ។

មន្ត្រីសង្កេតការណ៍សវនាការចំណាយពេលវេលាស្ទើរតែរាល់ថ្ងៃក្នុងការសង្កេតការណ៍សវនាការ ជំនុំជម្រះរឿងព្រហ្មទណ្ឌនៅតុលាការ ហើយហេតុដូច្នេះទទួលបាននូវចំណេះដឹងច្បាស់លាស់អំពីដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ដែលអនុវត្តជាប្រចាំនៅក្នុងប្រទេសកម្ពុជា។ មន្ត្រីសង្កេតការណ៍សវនាការបានបង្កើតទំនាក់ទំនងល្អ និងវិជ្ជមានជាមួយបុគ្គលិករបស់តុលាការដែលខ្លួនបានសង្កេត ដែលជាកិច្ចគាំទ្រដល់គោលបំណងរបស់គម្រោងក្នុងការបំពេញការងារក្នុងភាពដៃគូជាមួយតុលាការ និងដៃគូពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ដទៃទៀតដើម្បីលើកកម្ពស់ការទទួលស្គាល់ និងការអនុវត្តន៍បទប្បញ្ញត្តិនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឲ្យបានរឹតតែប្រសើរឡើង។

## នីតិវិធីសង្កេតការណ៍សវនាការ

នៅក្នុងអំឡុងពេលរបាយការណ៍ទី៦នេះ មន្ត្រីសង្កេតការណ៍ម្នាក់ត្រូវបានចាត់តាំងទៅតាមតុលាការដែលបានធ្វើការសង្កេតទាំង៣។ តាមរយៈការចាត់តាំងមន្ត្រីសង្កេតការណ៍ទៅកាន់តុលាការដែលបានកំណត់ ការធ្វើបែបនេះអាចឲ្យមន្ត្រីទាំងនោះមានភាពជិតស្និទ្ធជាមួយនឹងតុលាការ និងដើម្បីបង្កើតទំនាក់ទំនងជាមួយនឹងមន្ត្រីតុលាការ និងចៅក្រម។ ការជំនុំជម្រះជាក់លាក់ គឺពុំត្រូវបានផ្តោតជាគោលដៅសំខាន់នោះទេ ផ្ទុយទៅវិញសវនាការត្រូវបានសង្កេតការណ៍តាមចិត្តដោយសេរី ដែលអាស្រ័យលើកាលវិភាគរបស់តុលាការ ដើម្បីធានាថាដំណើរការនៃការប្រមូលទិន្នន័យនៅតែរក្សាគោលបំណងរបស់គម្រោងបាន។ នៅពេលដែលមន្ត្រីសង្កេតការណ៍ចុះទៅធ្វើការអង្កេតសវនាការណាមួយ ព័ត៌មានត្រូវបានកត់ត្រាទុកដោយផ្ទាល់ទៅក្នុងតារាងសង្កេតការណ៍។ ព័ត៌មានដែលស្វែងរក គឺមានកម្រិតទៅតាមដំណើរការសវនការផ្ទាល់ និងពុំមានកិច្ចសម្ភាសន៍ ឬ កិច្ចពិភាក្សាបន្ថែមទៀតត្រូវបានធ្វើឡើងនោះទេ លើកលែងតែនៅពេលដែលមន្ត្រីសង្កេតការណ៍សវនាការខិតខំស្វែងរកព័ត៌មានទាក់ទិនទៅនឹងសាលក្រមនៃការជំនុំជម្រះ ដែលពុំត្រូវបានប្រកាសនៅថ្ងៃសវនាការ តែត្រូវបានលើកទៅប្រកាសនៅកាលបរិច្ឆេទក្រោយៗទៀត។

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យ

បន្ទាប់ពីបញ្ចប់សវនាការនីមួយៗ ទិន្នន័យនៅក្នុងតារាងសង្កេតការណ៍សវនាការត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ("ប្រព័ន្ធគ្រប់គ្រងទិន្នន័យ")។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យឆ្លុះបញ្ចាំងអំពីសំណួរនៅក្នុងតារាងសង្កេតការណ៍ និងត្រូវបានបង្កើតឡើងតាមរយៈការប្រើប្រាស់កម្មវិធី Microsoft Visual Basic។ បន្ថែមទៅលើការរក្សាទុកទិន្នន័យ ដែលបានមកពីតារាងសង្កេតការណ៍ ប្រព័ន្ធគ្រប់គ្រងទិន្នន័យត្រូវបានបង្កើតឡើង ដើម្បីវិភាគទិន្នន័យដែលបានរក្សាទុក ឧទាហរណ៍ប្រព័ន្ធនេះនឹងបង្ហាញសញ្ញាពីការឃុំខ្លួនបណ្តោះអាសន្នលើសថិរវេលាដែលបញ្ញត្តដោយច្បាប់។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យគឺត្រូវផ្តួចផ្តើមដើម្បីធ្វើជាឧបករណ៍មួយសម្រាប់ប្រើប្រាស់ផ្ទៃក្នុងដោយបុគ្គលិក ម.ស.ម.ក តែទោះជាយ៉ាងនេះក្តី កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ប្រព័ន្ធគ្រប់គ្រងទិន្នន័យនេះត្រូវបានដាក់ឲ្យប្រើប្រាស់ជាប្រព័ន្ធគ្រប់គ្រងទិន្នន័យជាសាធារណៈ ដែលអាចស្វែងរកបានពីគ្រប់សំណាក់សាធារណជនទូទៅទាំងអស់

តាមរយៈគេហទំព័ររបស់សិទ្ធិមនុស្សរបស់ ម.ស.ម.ក។ យើងសង្ឃឹមថា ប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅពេលនេះ អាចដាក់ឲ្យប្រើប្រាស់ពុំមែនត្រឹមតែជាឧបករណ៍សម្រាប់ផ្ទុកទិន្នន័យប៉ុណ្ណោះទេ តែថែមទាំងដើម្បីលើកឡើងពីការយល់ដឹងជាសាធារណៈពាក់ព័ន្ធនឹងបញ្ហានៃការជំនុំជម្រះដោយយុត្តិធម៌ និងដើម្បីផ្តល់ព័ត៌មានដល់សាធារណជនដែលពុំធ្លាប់មានពីមុនមក។

## ការវិភាគ និង កិច្ចពិភាក្សា

ម.ស.ម.ក វិភាគទិន្នន័យនៃសវនាការដែលត្រូវបានកត់ត្រាទុកក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងកំណត់បង្ហាញពីការអនុវត្តន៍វិជ្ជមាន ព្រមទាំងផ្នែកដែលគួរឲ្យបារម្ភនានាដែលកើតមាននៅក្នុងសវនាការ។ ទិន្នន័យ គឺផ្អែកលើចម្លើយដែលមន្ត្រីសង្កេតការណ៍សវនាការបានឆ្លើយទៅនឹងសំណួរនៅក្នុងតារាងសង្កេតការណ៍។ បន្ទាប់មក ការវិភាគជាលក្ខណៈប្រៀបធៀបក៏ត្រូវបានធ្វើឡើងដើម្បីកំណត់បង្ហាញពីនិន្នាការនៅក្នុងការអនុវត្តន៍របស់តុលាការនីមួយៗ វាយតម្លៃលើភាពប្រសើរឡើង និងលើកឡើងអំពីអនុសាសន៍បន្ថែមទៀត។ គោលបំណងចម្បងនៃការវិភាគនេះ គឺដើម្បីកំណត់បង្ហាញពីភាពខ្លាំង និងខ្សោយរបស់តុលាការនីមួយៗ និងដើម្បីពិភាក្សាលើបញ្ហាទាំងអស់នេះជាមួយនឹងតុលាការ និងបណ្តាដៃគូធ្វើការលើវិស័យយុត្តិធម៌ ដើម្បីបង្កើត និងអនុវត្តវិធីសាស្ត្រនានាក្នុងការធ្វើឲ្យប្រសើរឡើងនូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការកម្ពុជា។

គោលបំណងរបស់គម្រោង គឺផ្តល់ទិន្នន័យដ៏ត្រឹមត្រូវដែលជាមូលដ្ឋានយោងក្នុងការជំរុញឲ្យមានការផ្លាស់ប្តូរឲ្យប្រសើរឡើងនៃការអនុវត្តន៍របស់តុលាការ ព្រមទាំងឈានទៅរកការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ឲ្យបានទូលំទូលាយ។ សេចក្តីព្រាងចុងក្រោយនៃរបាយការណ៍ប្រចាំឆមាសនេះត្រូវបានផ្ញើជូនប្រធានតុលាការដែលបានសង្កេត ដើម្បីស្វែងរកមតិយោបល់ និងអនុសាសន៍មុនពេលបោះពុម្ពផ្សាយ។ នៅពេលចេញផ្សាយ ម.ស.ម.ក ចែកចាយរបាយការណ៍នេះទៅឲ្យដៃគូពាក់ព័ន្ធនានា ព្រមទាំងស្នើសុំជួបប្រជុំ ឬធ្វើបទបង្ហាញ ដើម្បីផ្តល់ការពន្យល់បន្ថែមទៅលើទិន្នន័យ ការវិភាគ និងអនុសាសន៍។ បុគ្គលិកគម្រោងក៏ស្នើសុំជួបប្រជុំផងដែរជាមួយនឹងតំណាងតុលាការដែលបានសង្កេត ព្រមទាំងអង្គការ អង្គភាព និងស្ថាប័នពាក់ព័ន្ធវិស័យយុត្តិធម៌ដទៃទៀត ដែលជាប់ទាក់ទងនឹងអនុសាសន៍នៅក្នុងរបាយការណ៍។ កិច្ចប្រជុំនេះជាឱកាសមួយសម្រាប់ផ្លាស់ប្តូរគំនិតយោបល់ និងនាំឲ្យមានការយល់ច្បាស់អំពីផលលំបាកដែលប្រឈមមុខដោយអ្នកធ្វើការដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌។ កិច្ចប្រជុំពិភាក្សាមានគោលបំណងក្នុងការលើកកម្ពស់ការអនុវត្តន៍អនុសាសន៍ ដែលមាននៅក្នុងរបាយការណ៍ ឬវិធានការណ៍ដទៃទៀតដែលអាចដោះស្រាយនូវការព្រួយបារម្ភដែលជាមូលហេតុនៃការផ្តល់អនុសាសន៍ទាំងនោះផងដែរ។

លទ្ធផលនៃកិច្ចពិភាក្សាទាំងនេះ ត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះដើម្បីជួយពន្យល់អំពីនិន្នាការ និងអ្វីដែលត្រូវធ្វើឲ្យល្អឡើងនៅក្នុងអនុសាសន៍ដែលបានកំណត់ក្នុងរបាយការណ៍។

## ៣. ទិន្នន័យ និង ការវាយតម្លៃ

នៅក្នុងអំឡុងពេលរបាយការណ៍ទី៦ មន្ត្រីសង្កេតការណ៍បានធ្វើការសង្កេតការណ៍សវនាការសរុបចំនួន ៣៥៤ នៅតុលាការរាជធានីភ្នំពេញ តុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី ដែលក្នុងនោះមានជនជាប់ចោទសរុបចំនួន ៧១៩ នាក់។

ផ្នែកនេះបង្ហាញពីទិន្នន័យ "ដើម" ដែលបានកត់ត្រាដោយមន្ត្រីសង្កេតការណ៍ដោយប្រើប្រាស់តារាងសង្កេតការណ៍ ដែលផ្អែកលើសិទ្ធិនីមួយៗក្នុងពេលសង្កេតការណ៍សវនាការនីមួយៗ និងវាយតម្លៃទិន្នន័យទាំងនេះ។ ទិន្នន័យដែលប្រមូលបានពីតុលាការនីមួយៗត្រូវបានបង្ហាញស្របគ្នាក្នុងគោលបំណងធ្វើការប្រៀបធៀប និងវិភាគពីនិន្នាការនៃការអនុវត្តន៍ក្នុងតុលាការ។ ទិន្នន័យដែលមាននៅក្នុងតារាងខាងក្រោមនេះគឺជាទិន្នន័យដែលទាក់ទងទៅនឹងជនជាប់ចោទម្នាក់ៗ លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ។

**តួលេខទី១៖ សវនាការដែលបានសង្កេត**

| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| បទឧក្រិដ្ឋ | ៦៦ | ៣៦ | ៩០ | ២៨ | ៧ | ២៣ |
| បទមជ្ឈិម | ១១៧ | ៦៤ | ១០១ | ៧២ | ២៣ | ៧៧ |
| ចំនួនសវនាការសរុប | ១៨៣ | | ១៤១ | | ៣០* | |

*ចំនួនសវនាការដែលបានសង្កេតការណ៍នៅតុលាការខេត្តរតនគិរីមានកម្រិតទាបជាងការរំពឹងទុក ដោយសារតែអត្រាទាបជាខ្លាំងនៃសំណុំរឿងនៅតុលាការនេះបើធៀបនឹងតុលាការផ្សេងទៀតដែលបានសង្កេត។

តួលេខទី១ខាងលើបង្ហាញអំពីចំនួន និងទីតាំងនៃសវនាការព្រហ្មទណ្ឌ ដែលបានសង្កេតដោយមន្ត្រីសង្កេតការណ៍ក្នុងអំឡុងពេលរបាយការណ៍ទី៦ ព្រមទាំងធ្វើការបែងចែកបទចោទប្រកាន់ជា ២ ចំណាត់ថ្នាក់នៃបទល្មើសផ្សេងគ្នាដែលកើតមានក្នុងអំឡុងពេលរបាយការណ៍នេះ។ មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកំណត់និយមន័យនៃបទឧក្រិដ្ឋថា ជាបទល្មើសទាំងឡាយណា ដែលអប្បបរមានៃទោសជាប់ពន្ធនាគារលើសពី ៥ ឆ្នាំ។ មាត្រា ៤៧ បានឲ្យនិយមន័យបទមជ្ឈិមថា ជាបទល្មើសទាំងឡាយណា ដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៦ ថ្ងៃ និងក្រោម ឬ ស្មើនឹង ៥ ឆ្នាំ។ បទលហុត្រូវបានឲ្យនិយមន័យថា ជាបទល្មើសដែលការដាក់ទោសត្រឹមតែពិន័យជាប្រាក់ ឬ ទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង ៦ ថ្ងៃ។[12] ពុំមានសវនាការបទលហុនៅក្នុងអំឡុងពេលនៃរបាយការណ៍ទី៦នេះទេ។

[12] មាត្រា៤៨ នៃក្រមព្រហ្មទណ្ឌ។

**តួលេខទី២៖ ការប្រៀបធៀបចំនួនសរុបនៃសវនាការដែលបានសង្កេតជាមួយនឹងអំឡុងពេលរបាយការណ៍មុន**

| ចំនួនសវនាការសរុបដែលបានសង្កេត | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំនួនសវនាការ | ១៩៩ | | ៥៣២ | | ៥៨៥ | | ៣៩៨ | | ៤៦៣ | | ៣៥៤ | |
| បទឧក្រិដ្ឋ | ១០៥ | ៥៣ | ២៤៥ | ៤៦ | ២៧៥ | ៤៧ | ១៥៣ | ៣៨ | ១៧០ | ៣៧ | ១១៣ | ៣២ |
| បទមជ្ឈិម | ៩៤ | ៤៧ | ២៨៧ | ៥៤ | ៣១០ | ៥៣ | ២៤៥ | ៦២ | ២៩២ | ៦៣ | ២៤១ | ៦៨ |
| បទលហុ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | <១ | ០ | ០ |

ស្របពេលដែលរបាយការណ៍នេះផ្តោតលើទិន្នន័យ ដែលធ្វើការពិនិត្យប្រៀបធៀបក្នុងអំឡុងពេលរបាយការណ៍ទី៦ របាយការណ៍នេះក៏នឹងធ្វើការប្រៀបធៀបជាមួយនឹងអំឡុងពេលរបាយការណ៍មុនៗ ដើម្បីវាស់វែងការវិវឌ្ឍន៍លើទិសដៅនៃគម្រោងទាំងមូល ក្នុងការវិភាគចុងក្រោយអំពីកម្រិតនៃការគោរពតាមបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងធ្វើការប្រៀបធៀបរវាងតំបន់ភូមិសាស្ត្រផ្សេងៗគ្នា។

## សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖

- **មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖** *"ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការនិងសាលាជម្រះក្តី។ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យនិងមិនលម្អៀងដែលបង្កើតដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌និងជាសាធារណៈដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ[...]។"*
- **មាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖*"សវនាការត្រូវធ្វើឡើងជាសាធារណៈ។"*

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការសម្រេចថាមានទោស ឬ គ្មានទោសនៅក្នុងសវនាការជាសាធារណៈ លើកលែងតែក្នុងករណីពិសេសជាក់លាក់មួយចំនួន ឧទាហរណ៍៖ នៅពេលដែលតុលាការយល់ឃើញថា សវនាការជាសាធារណៈអាចបង្កឲ្យមាន *"ការប៉ះពាល់ធ្ងន់ធ្ងរ"* ដល់សណ្តាប់ធ្នាប់សង្គម ឬដល់ទំនៀមទម្លាប់ដ៏ល្អប្រពៃ។[13] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈពាក់ព័ន្ធនឹងធាតុផ្សំមួយចំនួន៖ សវនា

[13] មាត្រា៣១៦នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា តុលាការអាចបង្គាប់ឲ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តទៅជា *សម្ងាត់* ប្រសិនបើតុលាការយល់ឃើញថា សវនាការជាសាធារណៈអាចបង្កឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សង្គម ឬដល់ទំនៀមទម្លាប់ល្អ ប៉ុន្តែត្រូវតែមានការពន្យល់ជាលាយលក្ខណ៍អក្សរនៃការបង្គាប់បែបនោះបញ្ចូលជាមួយនឹងសាលក្រមលើអង្គសេចក្តី។

ការគួរតែបើកចំហជាទូទៅសម្រាប់សាធារណជន និងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ព័ត៌មានពីទីកន្លែង និងកាលបរិច្ឆេទនៃសវនាការគួរតែអាចរកបានជាសាធារណៈ ហើយគួរតែមានសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីធានាការចូលរួមពីសាធារណជន។[14]

### តួលេខទី៣៖ សិទ្ធិទទួលបានសវនាការជាសាធារណៈ

| តើការជូនដំណឹងអំពីសវនាការត្រូវបានបិទផ្សាយលើក្តារខៀនក្រៅបន្ទប់សវនាការដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៤២ | ២៣ | ៥២ | ៣៧ | ០ | ០ |
| គ្មាន | ១៤១ | ៧៧ | ៨៩ | ៦៣ | ៣០ | ១០០ |
| **តើសាធារណជនត្រូវបានរារាំង ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ?** | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ១ | ១ | ០ | ០ |
| គ្មាន | ១៨៣ | ១០០ | ១៤០ | ៩៩ | ៣០ | ១០០ |

នៅក្នុងករណីជាច្រើននៅតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តបន្ទាយមានជ័យ ការជូនដំណឹងអំពីសវនាការពុំត្រូវបានបិទផ្សាយនោះទេ ហើយក៏ជាការគួរឲ្យខកចិត្តដូចគ្នានេះដែរដោយកត់សម្គាល់ឃើញថាពុំមានការជូនដំណឹងអ្វីទាល់តែសោះត្រូវបានបិទនៅតុលាការខេត្តរតនគិរី។ ទោះជាយ៉ាងនេះក្តី ក្រុមការងាររបស់ ម.ស.ម.ក បានជួបពិភាក្សាជាមួយនឹងប្រធានសាលាដំបូងខេត្តរតនគិរីកាលពីខែសីហា ឆ្នាំ២០១៣ ដែលលោកបានពន្យល់ថា បន្ទាប់ពីលោកត្រូវបានតែងតាំងជាប្រធានកាលពីចុងឆ្នាំ២០១២ គាត់បានណែនាំទៅមន្ត្រីតុលាការឲ្យបិទកាលបរិច្ឆេទសវនាការជំនុំជម្រះលើក្តារខៀនផ្តល់ព័ត៌មានដល់សាធារណជន។[15] ក្រុមការងារសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក អាចបញ្ជាក់បានថា មានការបិទផ្សាយការជូនដំណឹងជា

---

មាត្រា១៤(១)នៃ ក.ស.អ.ស.ព.ន ចែងថាសារព័ត៌មាន និងសាធារណជនពុំគួរអនុញ្ញាតឲ្យចូលរួមក្នុងសវនាការទាំងស្រុង ឬផ្នែកណាមួយនៃសវនាការដោយសម្អាងលើ *"ទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិនៅក្នុងសង្គមប្រជាធិបតេយ្យ"* ដែលភាពជាសាធារណៈអាចធ្វើឲ្យខូចខាតដល់ប្រយោជន៍យុត្តិធម៌ ឬនៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ។

[14] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ កថាខ័ណ្ឌទី៦.២នៃសេចក្តីជូនដំណឹងលេខ ២១៥/១៩៨៦ *វ៉ាន់មៀ តទល់នឹងប្រទេសហូឡង់* ។ ដកស្រង់នៅក្នុងកំណត់ត្រាយោងលេខ១២។

[15] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តរតនគិរី លោកចៅក្រម សួស ឡា ប្រធានតុលាការ និងលោកចៅក្រម ឯក ប៉ូលីហ្វើល និងលោកចៅក្រម អ៊ី សុវណ្ណ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

សាធារណៈនៅក្នុងអំឡុងពេលដែលក្រុមការងារបានទៅជួបជាមួយនឹងតំណាងតុលាការ។ ប៉ុន្តែត្រង់ថា ការបិទផ្សាយជាសាធារណៈត្រូវបានធ្វើក្នុងវិសាលភាពកម្រិតណានោះ គឺត្រូវតែពិនិត្យពិច័យបន្តទៀត។ នៅក្នុងជំនួបជាច់ដោយឡែកមួយទៀតជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ កាលពីខែសីហា ឆ្នាំ២០១៣ តំណាងតុលាការបានគូសបញ្ជាក់ថា តុលាការបានធ្វើឲ្យប្រសើរឡើងជាច្រើននៅក្នុងការបិទផ្សាយកាលបរិច្ឆេទជំនុំជម្រះ បន្ទាប់ពីពិនិត្យមើលលើអនុសាសន៍មួយចំនួនក្នុងរបាយការណ៍មុនៗរបស់ ម.ស.ម.ក។[16]

ដូចបានគូសបញ្ជាក់នៅក្នុងរបាយការណ៍មុនៗ បញ្ជីជំសាមញ្ញប្រចាំសប្តាហ៍របស់តុលាការក៏អាចបិទបង្ហាញនៅតុលាការបានដែរ ដោយពុំចាំបាច់មានក្តារខៀនបិទប្រកាសនោះទេ ល្គឹកណាតែព័ត៌មានដែលពាក់ព័ន្ធផ្សេងទៀតត្រូវបិទបង្ហាញតាមទម្រង់ផ្សេងៗ។ មានករណីតែមួយគត់ដែលសាធារណជនម្នាក់ពុំត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងបន្ទប់តុលាការ (ដោយសារជននោះមានអាការស្រវឹង និងឡូឡា)។ ជាការគួរឲ្យកោតសរសើរដែរដែលឃើញថាសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈជាទូទៅ គឺត្រូវបានគោរពតាម។

**តួលេខទី៤៖ សិទ្ធិទទួលបានសវនាការជាសាធារណៈ៖ ការប្រៀបធៀបទិន្នន័យពីរបាយការណ៍មុននៃសវនាការដែលបានសង្កេតការណ៍ទាំងអស់**

| តើការជូនដំណឹងអំពីសវនាការត្រូវបានបិទផ្សាយលើក្តារខៀនក្រៅបន្ទប់សវនាការដែរឬទេ? | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៥ | ៣ | ០ | ០ | ២៣៤ | ៤០ | ១៩៥ | ៤៩ | ១១៨ | ២៥ | ៩៤ | ២៧ |
| គ្មាន | ១៩៤ | ៩៧ | ៥៣២ | ១០០ | ៣៥១ | ៦០ | ២០៣ | ៥១ | ៣៤៥ | ៧៥ | ២៦០ | ៧៣ |

| តើសាធារណជនត្រូវបានរារាំង ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ? | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | ០ | ០ | ១ | ០,៥ | ១ | ០.២ | ១ | ០,៥ |
| គ្មាន | ១៩៩ | ១០០ | ៥៣២ | ១០០ | ៥៨៥ | ១០០ | ៣៩៧ | ៩៩,៥ | ៤៦២ | ៩៩,៨ | ៣៥៣ | ៩៩,៥ |

[16] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

ក្រោយពីតួលេខនៃការបិទផ្សាយជាសាធារណៈអំពីការជូនដំណឹងសវនាការមានកម្រិតខ្ពស់ នៅក្នុងអំឡុងពេលរបាយការណ៍ទី៣ និង ទី៤ ករណីនេះត្រូវឃើញថាមានការធ្លាក់ចុះក្នុងអំឡុងពេលរបាយការណ៍ទី៥ ហើយក៏ឃើញថាធ្លាក់ចុះក្នុងអំឡុងពេលរបាយការណ៍ទី៦ទៀត។ ការចូលជាសាធារណៈទៅក្នុងបន្ទប់សវនាការ គឺមានកម្រិតខ្ពស់បិតថេរ ហើយជាចំណុចវិជ្ជមានដែលឃើញថានិន្នាការនេះនៅបន្តមាននៅក្នុងរបាយការណ៍ទី៦នេះ។ សវនាការត្រូវបានធ្វើឡើងដោយបើកចំហ និងជាសាធារណៈ ដែលបង្ហាញពីមូលដ្ឋានគ្រឹះនៃការជំនុំជម្រះដោយយុត្តិធម៌ ជាពិសេសសដោយឃើញពីការកើនឡើងនៅក្នុងផលប្រយោជន៍ និងការចូលរួមជាសាធារណៈអំពីបញ្ហាផ្លូវច្បាប់ដែលមើលឃើញនាពេលចុងក្រោយនេះនៅប្រទេសកម្ពុជា។

## សិទ្ធិមានសេរីភាព និង សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ៖** *"ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់។"*
- **មាត្រា១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖** *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។"*
- **មាត្រា៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖** *"បុគ្គលណាដែលបានចាប់ខ្លួន ឬ ឃុំខ្លួនពីបទព្រហ្មទណ្ឌនឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រមឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឲ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឲ្យនៅក្រៅឃុំត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះនៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តន៍សាលក្រម។"*
- **មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងក្នុងផ្នែកនេះ។"*
- **មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាជាការចាំបាច់៖*

  *១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការកុំឲ្យកើតឡើងជាថ្មី។*

  *២. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។*

  *៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ*

  *៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។*

  *៥. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ។*

  *៦.ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។*

- **មាត្រា ២០៨-២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ ថិរវេលាកំណត់នៃការឃុំខ្លួនបណ្តោះអាសន្ន**

  *ការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ មានថិរវេលាចំនួន៦ខែ។ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះអាចត្រូវបានពន្យារតែ២ដងគត់ ដោយមានរយៈពេល៦ខែតាមរយៈដីកា និងមានសម្អាងហេតុត្រឹមត្រូវ (មាត្រា២០៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។*

  *ការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន ដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម មានថរិវេលាចំនួន៤ខែ។ ថរិវេលានេះអាចពន្យារបានតែម្តងគត់មិនអាចលើសពី២ខែ ដោយមានដីកានិងមានសម្អាងហេតុត្រឹមត្រូវ(មាត្រា២០៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។*

  *ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ មានថរិវេលាមិនលើសពី៤ខែ កាលណាជនជាប់ចោទមានអាយុក្រោម១៦ឆ្នាំ ឬ៦ខែកាលណាជនជាប់ចោទមានអាយុ ពី១៦ដល់១៨ឆ្នាំ (មាត្រា២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។*

  *ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិមមានថរិវេលាមិនលើសពី២ខែ កាលណាជនជាប់ចោទមានអាយុក្រោម១៦ឆ្នាំ ឬ៤ខែ កាលណាជនជាប់ចោទមានអាយុចាប់ពី១៦ដល់១៨ឆ្នាំ (មាត្រា២១៤ ក្រមនីតិវិធីព្រហ្មទណ្ឌ)។*

  *ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានពន្យាររយៈពេល៤ខែបន្ថែមទៀតគិតចាប់ពីថ្ងៃចេញដីកាដំណោះស្រាយ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល៤ខែនោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង (មាត្រា២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្នរយៈពេល៤ខែគឺកំណត់ដោយច្បាប់។*

សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់ គឺសិទ្ធិសំខាន់មួយក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សច្ចាធារណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន គឺជាចំណុចស្នូលនៃសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស។ លើកលែងតែក្នុងកាលៈទេសៈពិសេស នៅពេលដែលពុំមានវិធានការដាក់លាក់ផ្សេងទៀត ជនម្នាក់អាចនឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន។ ស្របពេលដែលជួនកាលតុលាការមានការចាំបាច់ត្រូវសម្រេចដាក់ជនម្នាក់ឲ្យស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងភាពយុត្តិធម៌ឲ្យបានត្រឹមត្រូវ និងដើម្បីការពារជនរងគ្រោះ និងសាក្សី ការប្រើប្រាស់វិធានការឃុំខ្លួនបណ្តោះអាសន្នច្រើនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការសន្មតជាមុនថាគ្មានទោស ដរាបណាមានការសម្រេចផ្តន្ទាទោសដោយសាលាជម្រះក្តីឥតលម្អៀង និងមានសមត្ថកិច្ច។

### តួលេខទី៥៖ ការឃុំខ្លួនបណ្ដោះអាសន្នក្នុងអំឡុងពេលរបាយការណ៍ទី៦

| តើមានការឃុំខ្លួនបណ្ដោះអាសន្នដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ២៨១ | ៨២ | ១៩៣ | ៥៨ | ៣៤ | ៧២ |
| គ្មាន | ៥០ | ១៥ | ១២៩ | ៣៩ | ១៣ | ២៨ |
| មិនដឹង | ១០ | ៣ | ៩ | ៣ | ០ | ០ |

តុលាការខេត្តបន្ទាយមានជ័យមានកម្រិតនៃការឃុំខ្លួនបណ្ដោះអាសន្នទាប ប្រសិនបើធៀបនឹងតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តរតនគិរី។ កម្រិតនៃការឃុំខ្លួនបណ្ដោះអាសន្ននៅតុលាការខេត្តបន្ទាយមានជ័យក្នុងអំឡុងពេលរបាយការណ៍ទី៦បង្ហាញពីភាពប្រសើរឡើងបន្តិចពីចំនួន ៦១% នៅក្នុងអំឡុងពេលរបាយការណ៍ទី៥ ធៀបទៅនឹងចំនួន ៥៨% នៃអំឡុងពេលរបាយការណ៍ទី៦។ ទោះជាយ៉ាងនេះក្ដី កម្រិតនៃការឃុំខ្លួនបណ្ដោះអាសន្នមានការកើនឡើងនៅតុលាការរាជធានីភ្នំពេញពីចំនួន ៧៦% និងតុលាការខេត្តរតនគិរីពីចំនួន ៧០% ចាប់តាំងពីអំឡុងពេលរបាយការណ៍មុនធៀបទៅនឹងចំនួន ៨២% និង ៧២% នៅក្នុងអំឡុងពេលរបាយការណ៍ទី៦នេះ។

នៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សាដាច់ដោយឡែកពីគ្នាជាមួយនឹងប្រធានតុលាការខេត្តរតនគិរី[17] និងតំណាងតុលាការខេត្តបន្ទាយមានជ័យ[18] កាលពីខែសីហា ឆ្នាំ២០១៣ តុលាការទាំងពីរនេះបានពន្យល់ថាតុលាការមានផលលំបាកនៅក្នុងការគ្រប់គ្រងជនជាប់ចោទ ប្រសិនបើអនុញ្ញាតឲ្យជនជាប់ចោទមានសេរីភាព ដោយសារតែជនជាប់ចោទជាញឹកញាប់ពុំមានអាសយដ្ឋាន ឬ មុខរបរច្បាស់លាស់។

នៅក្នុងជំនួបដាច់ដោយឡែកមួយទៀតនៅតុលាការរាជធានីភ្នំពេញ តំណាងតុលាការបានពន្យល់ថាកម្រិតខ្ពស់នៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងអំឡុងពេលរបាយការណ៍នេះ ដោយសារតែតុលាការផ្ដល់អាទិភាពជាសំខាន់លើសំណុំរឿងទាំងឡាយណា ដែលមានជនជាប់ចោទស្ថិតក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។ លើសពីនេះទៀត តំណាងតុលាការបានបញ្ជាក់ថា បើយោងតាមមាត្រា ២០៤ និងមាត្រា ២០៥ នៃក្រមនីតិវិធី

[17] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តរតនគិរី លោកចៅក្រម សួស ឡា ប្រធានតុលាការ និងលោកចៅក្រម ឯក ប៉ូលីហ្វីល និងលោកចៅក្រម អ៊ី សុវណ្ណ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

[18] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ជាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

ព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន។[19] ទោះជាយ៉ាងនេះក្ដី របាយការណ៍ប្រចាំឆមាសមុនៗទាំងប្រាំលើកចេញផ្សាយដោយ ម.ស.ម.ក បង្ហាញថា ការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានអនុវត្តច្រើនជាង ៨០% នៃសំណុំរឿងទាំងអស់ដែលបានសង្កេត។ ជាមួយនឹងអត្រាខ្ពស់នៃការឃុំខ្លួនបណ្ដោះអាសន្នបែបនេះ ហាក់ដូចជាគួរឲ្យមានមន្ទិលសង្ស័យដែលថា ច្បាប់ត្រូវបានយកមកអនុវត្តត្រឹមត្រូវឬយ៉ាងណា។

### តួលេខទី៦៖ ការឃុំខ្លួនបណ្ដោះអាសន្នលើសរយៈពេលកំណត់ដោយច្បាប់

| ចំនួន | តុលាការនិងកាលបរិច្ឆេទ (ថ្ងៃខែឆ្នាំ) | ប្រភេទនៃបទចោទប្រកាន់ និងរយៈពេលអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្នតាមច្បាប់ | រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នជាក់ស្ដែង | រយៈពេលហួសនៃការឃុំខ្លួនបណ្ដោះអាសន្ន | ការផ្ដន្ទាទោសចុងក្រោយ | ចំណារបន្ថែម |
|---|---|---|---|---|---|---|
| ១ | ភ្នំពេញ ១០.០១.១២ | មជ្ឈិម ១០ខែ | ២១.០២.១១ ដល់ ១៣.០១.១៣ | ១៣ថ្ងៃ | ទោសពន្ធនាគារ ២ឆ្នាំ | មិនពាក់ព័ន្ធ |
| ២ | រតនគិរី ១៧.០១.១២ | មជ្ឈិម ១០ខែ | ០៧.០៨.១០ ដល់ ៣១.០១.១២ | ៧ខែ ២៤ថ្ងៃ | ទោសពន្ធនាគារ ១ឆ្នាំ | សារភាពនៅពេលចាប់ខ្លួន |
| ៣ | ភ្នំពេញ ០២.០២.១២ | មជ្ឈិម ១០ខែ | ជ.ចោទទី១៖ ២១.០៣.១១* ដល់ ១៤.០២.១២<br><br>ជ.ចោទទី២៖ ២៣.០៣.១១* ដល់ ១៤.០២.១២ | ជ.ចោទទី១ ៖ ២៤ថ្ងៃ<br><br>ជ.ចោទទី២ ៖ ២២ថ្ងៃ | ជ.ចោទទី១៖ ទោសពន្ធនាគារ ១ឆ្នាំ៦ខែ ពិន័យ ៣លានរៀល និងសំណង១ម៉ឺនរៀល<br>ជ.ចោទទី២៖ ទោសពន្ធនាគារ ១ឆ្នាំ ៦ខែ ពិន័យ ៣លានរៀល និងសំណង១ពាន់រៀល | មិនពាក់ព័ន្ធ |
| ៤ | បន្ទាយមានជ័យ ២៣.០២.១២ | មជ្ឈិម ១០ខែ | ០៧.០៤.១១* ដល់ ១២.០៣.១២ | ១ខែ ៥ថ្ងៃ | ទោសពន្ធនាគារ ២ឆ្នាំ | សារភាពនៅពេលចាប់ខ្លួន |

[19] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការរាជធានីភ្នំពេញ លោកចៅក្រម អឿង សៀង អនុប្រធានតុលាការ លោកចៅក្រម កោវណ្ណី អនុប្រធានតុលាការ លោកព្រះរាជអាជ្ញារង សុខ រឿន លោកចៅក្រម សេង នាង លោកចៅក្រម អ៊ី ឋាវរៈ លោកស្រីចៅក្រម សែមសក្តិកូឡា និងលោកស្រីចៅក្រម ចាំង ស៊ីណាត នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | បន្ទាយមានជ័យ ០៩.០២.១២ | មជ្ឈិម ១០ខែ | ២៧.០៣.១១* ដល់ ០៧.០៣.១២ | ១ខែ ១០ថ្ងៃ | ទោសពន្ធនាគារ ២ឆ្នាំ | ជនជាប់ចោទម្នាក់ក្នុងចំណោមពនាក់ បានសារភាពនៅពេលចាប់ខ្លួន |
| ៦ | បន្ទាយមានជ័យ ០២.០២.១២ | មជ្ឈិម ១០ខែ (នីតិជន) ៨ខែ (អនីតិជនអាយុចន្លោះពី ១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ) | ០១.០៣.១១* ដល់ ១០.០២.១២ | នីតិជនៈ ១ខែ ៩ថ្ងៃ អនីតិជនៈ៣ ខែ ៩ថ្ងៃ | នីតិជន (x៣)ៈ ទោសពន្ធនាគារ ២x៣ ឆ្នាំ ទោសពន្ធនាគារ ១x៧ឆ្នាំ អនីតិជន (x២)ៈទោសពន្ធនាគារ៣ឆ្នាំ | ជនជាប់ចោទត្រូវបានចោទប្រកាន់ពីដំបូងនិងជំនុំជម្រះពីបទមជ្ឈិម ហើយចៅក្រមបានប្តូរបទចោទនៅពេលប្រកាសសាលក្រម។ ហេតុដូច្នេះរយៈពេលកំណត់ដែលអនុវត្តគឺសម្រាប់ជនជាប់ចោទបទមជ្ឈិម។ |
| ៧ | បន្ទាយមានជ័យ ១៣.០៣.១២ | មជ្ឈិម ១០ខែ | ១៣.០២.១១* ដល់ ០៦.០៣.១២ | ១ខែ ២៣ថ្ងៃ | ទោសពន្ធនាគារ ២ឆ្នាំ ទោសពន្ធនាគារ ៦ខែ និងពិន័យ៦លានរៀល | មិនពាក់ព័ន្ធ |
| ៨ | បន្ទាយមានជ័យ ០៧.០៣.១២ | មជ្ឈិម ១០ខែ | ជ.ចោទទី១ &ទី២ ៈ០៧.០៣.១១* ដល់ ២៧.០៣.១២ ជ.ចោទទី៣ៈ ពុំដឹងកាលបរិច្ឆេទនៃការចាប់ខ្លួន/ការឃុំខ្លួនបណ្តោះអាសន្ន | ជ.ចោទទី១ &ទី២ៈ២ខែ | ជ.ចោទទី១ &ទី២ ៈ ទោសពន្ធនាគារ៥ឆ្នាំ ជ.ចោទទី៣ៈ ទោសពន្ធនាគារ ២ខែ | ជ.ចោទទី១ & ទី៣ បានសារភាពនៅពេលចាប់ខ្លួន |
| ៩ | ភ្នំពេញ ២៩.០៥.១២ | មជ្ឈិម ១០ខែ | ៣០.០៥.១១* ដល់ ០៧.០៦.១២ | ២ខែ ៧ ថ្ងៃ | ទោសពន្ធនាគារ ២ឆ្នាំ | ក្នុងពេលសវនាការចៅក្រមទទួលស្គាល់ថាជនជាប់ចោទទាំង២បានចំណាយពេលយ៉ាងយូរនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដោយពន្យល់ថាសវនាការត្រូវបានផ្អាកនៅដំណាក់កាលមួយដើម្បីឲ្យមាន |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ការបើកការស៊ើបអង្កេតបន្ថែមទៀត |
| ១០ | ភ្នំពេញ ១៩.០៦.១២ | ឧក្រិដ្ឋ ២២ខែ | ០៣.០៨.១០* ដល់ ២៩.០៦.១២ | ២៦ថ្ងៃ | ទោសពន្ធនាគារ ៦ឆ្នាំ និង ៦ខែ ព្រមទាំងពិន័យ១លានរៀល | មិនពាក់ព័ន្ធ |
| ១១ | បន្ទាយមានជ័យ ០៣.០៥.១២ | មជ្ឈិម ១០ខែ | ២៥.០៦.១១* ដល់ ០៣.០៦.១២ | ១ខែ ៩ ថ្ងៃ | ទោសពន្ធនាគារ ២ឆ្នាំ | មិនពាក់ព័ន្ធ |
| ១២ | បន្ទាយមានជ័យ ២១.០៥.១២ | មជ្ឈិម ១០ខែ | ១៩.០១.១១* ដល់ ០៥.០៦.១២ | ៦ខែ ២២ថ្ងៃ | ទោសពន្ធនាគារ ១ឆ្នាំ | មិនពាក់ព័ន្ធ |
| ១៣ | បន្ទាយមានជ័យ ២១.០៥.១២ | មជ្ឈិម ១០ខែ | ២៩.០៦.១១* ដល់ ០៩.០៥.១២ | ១០ថ្ងៃ | ទោសពន្ធនាគារ ២ឆ្នាំ | សារភាពនៅពេលចាប់ខ្លួន |
| ១៤ | បន្ទាយមានជ័យ ០៨.០៦.១២ | មជ្ឈិម ១០ខែ | ១១.១១.១១* ដល់ ១៣.០៦.១២ | ២ថ្ងៃ | ទោសពន្ធនាគារ ១ឆ្នាំ និងសាកល្បង១ឆ្នាំ | មិនពាក់ព័ន្ធ |
| ១៥ | បន្ទាយមានជ័យ ២២.០៥.១២ | មជ្ឈិម ១០ខែ | ២៤.០៨.១១* ដល់ ០៨.០៦.១២ | ៣ខែ ១៥ថ្ងៃ | មិនដឹង | ពុំមានភស្តុតាងត្រូវបានបង្ហាញនៅក្នុងពេលសវនាការទេ |
| ១៦ | បន្ទាយមានជ័យ ២០.០៦.១២ | មជ្ឈិម ១០ខែ | ១០.០៧.១១* ដល់ ២០.០៦.១២ | ១ខែ ១០ថ្ងៃ | ទោសពន្ធនាគារ ១ឆ្នាំ និងសាកល្បង១ឆ្នាំ | សារភាពនៅពេលចាប់ខ្លួន |

*កាលបរិច្ឆេទនៃការចាប់ខ្លួន នៅក្នុងករណីជាច្រើន កាលបរិច្ឆេទនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានអនុវត្តពុំត្រូវបានប្រកាសនៅក្នុងតុលាការទេ ហេតុដូច្នេះទើបមានករណីខ្លះដាក់សញ្ញា (*) ហើយកាលបរិច្ឆេទនៃការចាប់ខ្លួនចាត់ទុកថាជាថ្ងៃដែលការឃុំខ្លួនបានធ្វើឡើង។

រយៈពេលអតិបរមាដែលអនុញ្ញាតសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នបង្ហាញអំពីរយៈពេលអតិបរមាដែលអាចនឹងអនុវត្តសម្រាប់ករណីនីមួយៗ។ ដោយពុំមានកាលបរិច្ឆេទជាក់លាក់នៃការអនុវត្តន៍ការឃុំខ្លួនបណ្តោះអាសន្ន រួមជាមួយនឹងកាលបរិច្ឆេទចេញដីកាដំណោះស្រាយនៅក្នុងករណីនីមួយៗ នេះជាការលំបាកក្នុងគណនារយៈពេលឲ្យបានច្បាស់លាស់។ ជាការពិត រយៈពេលអតិបរមានៃការឃុំខ្លួនតាមផ្លូវច្បាប់គឺខុសគ្នាទៅតាមករណីនីមួយៗ។ រយៈពេលអតិបរមានៅក្នុងតារាងខាងលើនេះគឺត្រូវបានបង្កើតឡើងនូវរយៈពេលអតិបរមាដែលអនុញ្ញាតតាមមាត្រា ២០៨ ដល់ ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយ

មានរយៈពេល៤ខែបន្ថែមទៀត ដែលត្រូវបានអនុញ្ញាត នៅពេលដែលចៅក្រមចេញដីកាដំណោះស្រាយនៅក្នុងករណីនោះ (មាត្រា២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

មន្ត្រីសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានរកឃើញករណីចំនួន១៦ ដែលមានការឃុំខ្លួនបណ្ដោះអាសន្នលើស និងខុសច្បាប់។ ករណីទាំងអស់នេះ លើកលែងតែមួយករណីចេញគឺជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទមជ្ឈិម។ នៅក្នុងករណីខ្លះ ការផ្ដន្ទាទោសគឺធ្វើឡើងដោយផ្អែកទាំងស្រុងលើការសារភាពរបស់ជនជាប់ចោទ ហេតុដូចនេះតុលាការពុំអាចលើកសម្អាងហេតុដូចជា ការរៀបចំ និង/ឬ ការប្រមូលភស្តុតាង ដើម្បីធ្វើយុត្តិកម្មលើការពន្យារសវនាការចំពោះករណីទាំងនោះ។ រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នដែលហួសយូរជាងគេគឺមានរយៈពេល ៧ ខែ និង ២៤ ថ្ងៃ ហើយដែលបានកើតឡើងនៅក្នុងករណីមួយនៅតុលាការខេត្តរតនគិរី។ ការផ្ដន្ទាទោសចុងក្រោយក្នុងករណីនេះនោះគឺមានរយៈពេល ១ ឆ្នាំជាទោសពន្ធនាគារ។

## សិទ្ធិយល់ពីបទចោទប្រកាន់

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(៣)(ក) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *ជនជាប់ចោទ "ត្រូវទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។"*
- **មាត្រា១៤(៣)(ច) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមាដោយស្មើភាពគ្នាយ៉ាងពេញលេញ...ទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងតុលាការ។"*
- **មាត្រា៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីជនរងគ្រោះសាក្សី និងអ្នកជំនាញព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។"*
- **មាត្រា៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រាប់ជនជាប់ចោទឲ្យដឹងអំពីបទចោទដែលគេចោទប្រកាន់មកលើខ្លួន។"*
- **មាត្រា៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ក្នុងករណីចាំបាច់ប្រធានអាចហៅរកអ្នកបកប្រែ។"*
- **មាត្រា៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"កាលណាសំណួរត្រូវសួរដល់ជនគ និងថ្លង់ក្រឡាបញ្ជីត្រូវសរសេរសំណួរហើយឲ្យសាមីខ្លួនអាននិងឆ្លើយជាលាយល័ក្ខណ៍អក្សរ។ ក្នុងករណីសាមីជនមិនចេះអាន ឬ មិនចេះអក្សរប្រធានត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៣៣០[...] ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជនគ និងថ្លង់នោះមកបកប្រែ។*

ជនជាប់ចោទនៃបទល្មើសព្រហ្មទណ្ឌត្រូវបានប្រាប់ពីបទចោទប្រភេទនៃបទល្មើស ដែលខ្លួនត្រូវបានចោទប្រកាន់។ បើសិនជាពុំមានព័ត៌មានបឋមទាំងនេះទេ នេះពិតជាពុំអាចឲ្យជនជាប់ចោទរៀបការពារក្ដីឲ្យបានត្រឹមត្រូវ ឬ ផ្ដល់ការណែនាំឲ្យបានច្បាស់លាស់ដល់មេធាវីនៅក្នុងសំណុំរឿងនោះ ក្នុងករណីដែលជន

ជាប់ចោទត្រូវបានមេធាវីតំណាងតាមផ្លូវច្បាប់។ មន្ត្រីសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យអំពីព័ត៌មានដែលទាក់ទងទៅនឹងជនជាប់ចោទនៅពេលបើកសវនាការ។ ទោះបីជាព័ត៌មាននេះគួរតែត្រូវបានផ្តល់ជូនរួចហើយទៅជនជាប់ចោទនៅក្នុងអំឡុងពេលនៃនីតិវិធីមុនសវនាការ/ស៊ើបសួរយ៉ាងណាក្តី តែជាការចាំបាច់សម្រាប់ចៅក្រមក្នុងការរម្លឹកដល់ជនជាប់ចោទអំពីព័ត៌មានទាំងនេះ នៅមុនពេលសវនាការចាប់ផ្តើម។ ជាពិសេស ពេលខ្លះមានបទចោទក្នុងករណីមួយចំនួនអាចត្រូវបានផ្លាស់ប្តូរ ឬ កែប្រែនៅចន្លោះពេលនៃការចាប់ខ្លួន/ការចោទប្រកាន់ និងពេលជំនុំជម្រះ។

**តួលេខទី៧៖ សិទ្ធិយល់ពីបទចោទប្រកាន់ - នៅគ្រប់តុលាការទាំងអស់ដែលបានសង្កេតក្នុងអំឡុងពេលនៃរបាយការណ៍ទី៦**

| តើចៅក្រមបានប្រាប់ពីបទចោទប្រកាន់ដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៨១ | ៩៩ | ១៣៣ | ៩៥ | ៣០ | ១០០ |
| គ្មាន | ២ | ១ | ៨ | ៦ | ០ | ០ |
| តើចៅក្រមប្រាប់ពីមាត្រាច្បាប់ដែលពាក់ព័ន្ធដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១០៥ | ៥៧ | ៨៧ | ៦២ | ៣០ | ១០០ |
| គ្មាន | ៧៨ | ៤៣ | ៥៤ | ៣៨ | ០ | ០ |
| តើចៅក្រមបានប្រាប់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៤៨ | ៨១ | ១០៤ | ៧៤ | ៣០ | ១០០ |
| គ្មាន | ៣៥ | ១៩ | ៣៧ | ២៦ | ០ | ០ |
| តើចៅក្រមបានប្រាប់ពីទីកន្លែងប្រព្រឹត្តបទល្មើសដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |

| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
|---|---|---|---|---|---|---|
| មាន | ១៤១ | ៧៧ | ៩៨ | ៧០ | ៣០ | ១០០ |
| គ្មាន | ៤២ | ៣៣ | ៤៣ | ៣០ | ០ | ០ |
| តើចៅក្រមបានរៀបរាប់ពីឈ្មោះភាគីដែលពាក់ព័ន្ធដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៦១ | ៨៨ | ១៣១ | ៩៤ | ៣០ | ១០០ |
| គ្មាន | ២២ | ១២ | ១០ | ៦ | ០ | ០ |
| ប្រសិនបើត្រូវការ តើអ្នកបកប្រែត្រូវបានផ្តល់ឲ្យដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ(៩ករណីត្រូវការអ្នកបកប្រែ) | | តុលាការខេត្តបន្ទាយមានជ័យ(១ករណីត្រូវការអ្នកបកប្រែ) | | តុលាការខេត្តរតនគិរី(១ករណីត្រូវការអ្នកបកប្រែ) | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៩ | ១០០ | ១ | ១០០ | ១ | ១០០ |
| គ្មាន | ០ | ០ | ០ | ០ | ០ | ០ |
| ប្រសិនបើត្រូវការ តើជនពិការត្រូវបានគេផ្តល់ជំនួយដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | ០ | ០ |
| គ្មាន | ០ | ០ | ០ | ០ | ០ | ០ |
| មិនដឹង | ១៨៣ | ១០០ | ១៤១ | ១០០ | ៣០ | ១០០ |

បទចោទព្រហ្មទណ្ឌត្រូវបានប្រាប់ដោយចៅក្រមនៅស្ទើរតែគ្រប់ករណី ដែលបានសង្កេតការណ៍ទាំងអស់ក្នុងអំឡុងពេលរបាយការណ៍ទី៦នេះ។ ម.ស.ម.ក សង្ឃឹមថានឹងឃើញភាពប្រសើរឡើងថែមទៀត ដែលនឹងអាចសង្ឃឹមថានឹងសម្រេចបាននូវអត្រា ១០០% នៅគ្រប់តុលាការទាំងអស់។ ចៅក្រមនៅតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តបន្ទាយមានជ័យបានខកខានក្នុងការប្រកាសពីបទចោទក្នុងករណីតិចតួចតែ

ប៉ុណ្ណោះ (នៅតុលាការរាជធានីភ្នំពេញមាន ២ ករណី និង ៨ ករណីនៅតុលាការខេត្តបន្ទាយមានជ័យ)។ មានករណីច្រើនគួរសមដែរនៅតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តបន្ទាយមានជ័យ ដែលចៅក្រមខកខានពុំបានលើកឡើងពីមាត្រាច្បាប់ដែលពាក់ព័ន្ធ កាលបរិច្ឆេទនៃបទល្មើស ឬទីកន្លែងដែលបទល្មើសបានកើតឡើង។ ព័ត៌មាននេះគឺចាំបាច់ណាស់ ប្រសិនជាជនជាប់ចោទត្រូវមានជំហរមួយដែលត្រូវឆ្លើយតបចំពោះបទចោទប្រកាន់ប្រឆាំងនឹងខ្លួនឲ្យបានត្រឹមត្រូវ។ តុលាការរាជធានីភ្នំពេញ និងតុលាការខេត្តបន្ទាយមានជ័យសម្រេចបានជោគជ័យច្រើនពាក់ព័ន្ធនឹងការលើកឡើងបញ្ជាក់ពីភាគី ដែលទាក់ទិននៅក្នុងសំណុំរឿង។ តុលាការខេត្តរតនគិរីជាថ្មីបានសម្រេចដល់ទៅអត្រា ១០០% ក្នុងការអនុវត្តន៍នីតិវិធី។ នៅគ្រាដែលតុលាការខេត្តរតនគិរីសម្រេចបានអត្រា ១០០% ក្នុងការផ្តល់ព័ត៌មានទាក់ទិននឹងបទចោទ ជាការសំខាន់ដែលគួរកត់ចំណាំថាមានករណីតិចតួចជាខ្លាំងដែលបានសង្កេតការណ៍នៅតុលាការ ហេតុដូច្នេះការធ្វើការប្រៀបធៀបដោយផ្ទាល់ជាមួយនឹងការអនុវត្តន៍នៅតុលាការពីរទៀតគឺពុំសូវជាសមហេតុផលប៉ុន្មានទេ។

មានករណីចំនួន ១២ ដែលបានសង្កេតការណ៍នៅក្នុងអំឡុងពេលរបាយការណ៍ទី៦ ដែលត្រូវការអ្នកបកប្រែ ហើយមន្ត្រីតុលាការបានធានាថាតម្រូវការទាំងនោះត្រូវបានជួយសម្របសម្រួលក្នុងករណីនីមួយៗ។ ពុំមានករណីណាមួយ ដែលត្រូវការជំនួយសម្រាប់ជនជាប់ចោទជាជនពិការនៅក្នុងអំឡុងពេលរបាយការណ៍ទី៦ នេះទេ។

**តួលេខទី៨៖ និន្នាការសរុបចំពោះសិទ្ធិយល់ដឹងពីប្រភេទនៃបទចោទប្រកាន់**

| តើចៅក្រមបានប្រាប់ពីបទចោទប្រកាន់ដែរឬទេ? | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៩៨ | ៩៩ | ៥០៣ | ៩៥ | ៥៤៥ | ៩៣ | ៣៨៥ | ៩៧ | ៤២០ | ៩៥ | ៣៤៤ | ៩៧ |
| គ្មាន | ១ | ១ | ២៩ | ៥ | ៤០ | ៧ | ១៣ | ៣ | ២៣ | ៥ | ១០ | ៣ |
| តើចៅក្រមប្រាប់ពីមាត្រាច្បាប់ដែលពាក់ព័ន្ធដែរឬទេ? | | | | | | | | | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៦៩ | ៨៥ | ៣១៣ | ៥៩ | ២៩៩ | ៥១ | ២៧៧ | ៧០ | ២៩០ | ៦៣ | ២២២ | ៦៣ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| គ្មាន | ៣០ | ១៥ | ២១៩ | ៤១ | ២៨៦ | ៤៩ | ១២១ | ៣០ | ១៧៣ | ៣៧ | ១៣២ | ៣៧ |
| តើថៅក្រមបានប្រាប់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសដែរឬទេ? | | | | | | | | | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ទិន្នន័យមិនត្រូវបានប្រមូលទេក្នុងអំឡុងពេលនៃរបាយការណ៍ទី១និងទី២ | | | | ៤១៧ | ៧១ | ៣២៥ | ៨២ | ៣៤៩ | ៧៥ | ២៨២ | ៨០ |
| គ្មាន | | | | | ១៦៨ | ២៩ | ៧៣ | ១៨ | ១១៤ | ២៥ | ៧២ | ២០ |
| តើថៅក្រមបានប្រាប់ពីទីកន្លែងប្រព្រឹត្តបទល្មើសដែរឬទេ? | | | | | | | | | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ទិន្នន័យមិនត្រូវបានប្រមូលទេក្នុងអំឡុងពេលនៃរបាយការណ៍ទី១និងទី២ | | | | ៣៩៤ | ៦៧ | ៣១៥ | ៧៩ | ៣៣៦ | ៧៣ | ២៦៩ | ៧៦ |
| គ្មាន | | | | | ១៩១ | ៣៣ | ៨៣ | ២១ | ១២៧ | ២៧ | ៨៥ | ២៤ |
| តើថៅក្រមបានរៀបរាប់ពីឈ្មោះភាគីដែលពាក់ព័ន្ធដែរឬទេ? | | | | | | | | | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៩៦ | ៩៨ | ៤៤៣ | ៨៣ | ៥១២ | ៨៨ | ៣៦០ | ៩០ | ៤១៨ | ៩០ | ៣២២ | ៩១ |
| គ្មាន | ៣ | ២ | ៨៩ | ១៧ | ៧៣ | ១២ | ៣៨ | ១០ | ៤៥ | ១០ | ៣២ | ៩ |
| ប្រសិនបើត្រូវការ តើអ្នកបកប្រែត្រូវបានផ្តល់ឲ្យដែរឬទេ? | | | | | | | | | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ពុំមានករណីត្រូវការអ្នកបកប្រែ | | ១៨ | ៩៥ | ២៣ | ៩៦ | ១០ | ១០០ | ១០ | ១០០ | ១១ | ១០០ |
| គ្មាន | | | ១ | ៥ | ១ | ៤ | ០ | ០ | ០ | ០ | ០ | ០ |
| ប្រសិនបើត្រូវការ តើជនពិការត្រូវបានគេផ្តល់ជំនួយដែរឬទេ? | | | | | | | | | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | ២ | ១០០ | ១ | ១០០ | ០ | ០ | ០ | មិនពាក់ព័ន្ធ |
| គ្មាន | ១ | ១០០ | ៣ | ១០០ | ០ | ០ | ០ | ០ | ១ | ១០០ | ០ | មិនពាក់ព័ន្ធ |

និន្នាការសរុប ដែលបង្ហាញនៅក្នុងតុលាការទាំងអស់ ដែលបានសង្កេតការណ៍ចាប់តាំងពីការចាប់ផ្តើមនៃគម្រោងនេះ កំពុងតែជំរុញឲ្យមានការរីកចម្រើន និងបង្ហាញថាតុលាការកំពុងតែរំកិលយ៉ាងសន្សឹមៗឆ្ពោះទៅរកគោលដៅនៃការប្រតិបត្តិតាមឲ្យបាន ១០០% របស់ ម.ស.ម.ក។ ចំពោះការដែលចៅក្រមបញ្ជាក់ពីបទចោទប្រកាន់ពាក់ព័ន្ធ មានភាពប្រសើរឡើងនូវចំនួនតួលេខដ៏ទាបបំផុតចំនួន ៩៣% នៅក្នុងអំឡុងពេលនៃរបាយការណ៍លើកទី៣ ទៅដល់ ៩៧% ក្នុងអំឡុងពេលនៃរបាយការណ៍លើកទី៦។

ពុំមានការផ្លាស់ប្តូរឡើយក្នុងការដែលចៅក្រមប្រាប់ពីមាត្រាច្បាប់ ដែលពាក់ព័ន្ធចាប់តាំងពីអំឡុងពេលនៃរបាយការណ៍លើកទី៥ ហេតុដូច្នេះផ្នែកនេះចាំបាច់នៅតែត្រូវធ្វើឲ្យប្រសើរឡើងថែមទៀត។ មានភាពប្រសើរឡើងចំពោះការបញ្ជាក់ពីកាលបរិច្ឆេទនៃបទល្មើសពីចំនួន ៧៥% ក្នុងអំឡុងពេលរបាយការណ៍លើកទី៥ ទៅដល់ ៨០% ក្នុងអំឡុងពេលរបាយការណ៍លើកទី៦។ ស្រដៀងគ្នានេះដែរ ចំពោះការបញ្ជាក់ពីទីតាំងនៃបទល្មើសដែលបានកើតឡើង មានការប្រសើរឡើងពីចំនួន ៧៣% ទៅដល់ ៧៦% នៅក្នុងអំឡុងពេលដូចគ្នានេះ។ ទាំងអស់នេះគឺជាភាពប្រសើរឡើងដោយកម្រិត ប៉ុន្តែយ៉ាងណាក្តី នេះគឺជាការបោះជំហានទៅរកទិសដៅដ៏ត្រឹមត្រូវ។ មានភាពប្រសើរឡើងជាលំដាប់ស្រដៀងគ្នាដែរក្នុងចំនួននៃសំណុំរឿងដែលចៅក្រមបានបញ្ជាក់ពីភាគីដែលពាក់ព័ន្ធ ស្របពេលដែលតុលាការបានធានាថាភាគីត្រូវទទួលអ្នកបកប្រែនៅពេលមានការទាមទារ ដោយពុំមានករណីលើកលែង ចាប់តាំងពីអំឡុងពេលរបាយការណ៍លើកទី៤មក។

## ការពន្យល់ប្រាប់សិទ្ធិ

> **ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**
>
> - **មាត្រា១៤(៣)(ក) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** ជនជាប់ចោទ *"ត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។"*
> - **មាត្រា៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ប្រធានសវនាការប្រាប់ជនជាប់ចោទឲ្យដឹងអំពីអំពើដែលគេចោទប្រកាន់មកលើខ្លួននិងធ្វើការសួរចម្លើយជននោះ។"*

បុគ្គលម្នាក់អាចអនុវត្តសិទ្ធិស្របច្បាប់របស់ខ្លួនបាន ប្រសិនបើបុគ្គលនោះត្រូវបានគេជូនដំណឹងពេញលេញដល់ខ្លួន។ ម.ស.ម.ក សង្កេតការណ៍មិនត្រឹមតែថាតើចៅក្រមជូនដំណឹងដល់ជនជាប់ចោទពីសិទ្ធិដែលត្រូវទទួលបាននានាដូចដែលបង្ហាញនៅក្នុងតារាងខាងក្រោមនេះប៉ុណ្ណោះទេ ថែមទាំងសង្កេតមើលថាតើចៅក្រមបានពន្យល់ពេញលេញនៃសិទ្ធិទាំងនេះដែរឬយ៉ាងណា។ ម.ស.ម.ក ក៏កំពុងតែស្ថិតក្នុងដំណើរការនៃការប្រាស្រ័យទាក់ទងជាមួយនឹងប្រធានតុលាការផងដែរ ដោយមានគោលបំណងចែកប័ណ្ណផ្សព្វផ្សាយដែលកំណត់អំពីសិទ្ធិស្របច្បាប់ជាមូលដ្ឋាន ដែលជនជាប់ចោទនៃបទល្មើសព្រហ្មទណ្ឌម្នាក់ៗ ត្រូវទទួលបានដើម្បីបិទបង្ហាញនៅតាមបណ្តាតុលាការទាំងអស់។

**តួលេខទី៩៖ ការពន្យល់ប្រាប់សិទ្ធិក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើចៅក្រមបានប្រាប់ និងពន្យល់ជនជាប់ចោទពីសិទ្ធិទទួលបានជំនួយពីមេធាវីដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រាប់ | ១១១ | ៦១ | ៨៦ | ៦១ | ៩ | ៣០ |
| ប្រាប់និងពន្យល់ | ០ | ០ | ១២ | ៨ | ១៦ | ៥៣ |
| គ្មានប្រាប់និងគ្មានពន្យល់ | ៦៨ | ៣៧ | ២២ | ១៦ | ១ | ៤ |
| មិនពាក់ព័ន្ធ | ៤ | ២ | ២១ | ១៥ | ៤ | ១៣ |
| តើចៅក្រមបានប្រាប់ និងពន្យល់ជនជាប់ចោទពីសិទ្ធិមិននិយាយស្តីដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |

| | | | | | | |
|---|---|---|---|---|---|---|
| ប្រាប់ | ៣៧ | ២០ | ០ | ០ | ១ | ៣ |
| ប្រាប់និងពន្យល់ | ០ | ០ | ០ | ០ | ០ | ០ |
| គ្មានប្រាប់និងគ្មានពន្យល់ | ១៤២ | ៧៨ | ១២០ | ៨៥ | ២៥ | ៨៣ |
| មិនពាក់ព័ន្ធ | ៤ | ២ | ២១ | ១៥ | ៤ | ១៤ |

មានការព្រួយបារម្ភមួយចំនួនដែលថាទិន្នន័យ ដែលប្រមូលបានក្នុងអំឡុងពេលរបាយការណ៍ទី៦នៅតែបង្ហាញថាចៅក្រមផ្តល់ការពន្យល់ពីសិទ្ធិជនជាប់ចោទឲ្យបានពេញលេញនៅមានចំនួនតិចតួចនៅឡើយ។ ចំពោះសិទ្ធិមានអ្នកតំណាងស្របច្បាប់ទៀតសោត ពុំមានចៅក្រមណាម្នាក់នៅតុលាការរាជធានីភ្នំពេញបានផ្តល់ការពន្យល់ទៅកាន់ជនជាប់ចោទនោះទេក្នុងអំឡុងពេលនៃសវនាការ ដែលបានសង្កេតការណ៍ដោយ ម.ស.ម.ក។ ស្រដៀងគ្នានេះដែរ ចំពោះសិទ្ធិពុំនិយាយស្តី ក៏ពុំមានចៅក្រមណាម្នាក់បានផ្តល់ការពន្យល់ទៅដល់ជនជាប់ចោទនៅក្នុងសវនាការដែលបានសង្កេតនោះដែរ។ ស្ថិតិទាំងនេះគួរឲ្យមានការចាប់អារម្មណ៍។ ប្រសិនបើជនជាប់ចោទពុំត្រូវបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ចំពោះសិទ្ធិ ដែលខ្លួនត្រូវទទួលបានតាមផ្លូវច្បាប់ នោះនឹងកាន់តែលំបាកដល់ការអនុវត្តន៍សិទ្ធិទាំងនោះឲ្យបានត្រឹមត្រូវ ហើយជាការងាយស្រួលក្នុងការធ្វើឲ្យប៉ះពាល់ ឬរំលោភបំពានចំពោះសិទ្ធិទាំងនោះ។

តំណាងតុលាការរាជធានីភ្នំពេញ បានអះអាងនៅក្នុងកិច្ចពិភាក្សាជាមួយនឹង ម.ស.ម.ក កាលពីខែកញ្ញា ឆ្នាំ២០១៣ ថា ក្រមនីតិវិធីព្រហ្មទណ្ឌពុំតម្រូវឲ្យចៅក្រមជំនុំជម្រះត្រូវប្រាប់ ឬ ពន្យល់អំពីសិទ្ធិទៅជនជាប់ចោទនៅក្នុងពេលសវនាការជំនុំជម្រះនោះទេ។ តំណាងតុលាការបញ្ជាក់ថា តាមមាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការប្រាប់ពីសិទ្ធិមានមេធាវី និងសិទ្ធិនៅស្ងៀមទៅដល់ជនត្រូវចោទ ជាតួនាទីរបស់ចៅក្រមស៊ើបសួរ។[20] ថ្វីបើជាយ៉ាងនេះក្តី មាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តថា ប្រធានសវនាការត្រូវរ៉ាប់រងឲ្យសិទ្ធិខាងការការពារបានប្រព្រឹត្តទៅដោយសេរី។ ម្យ៉ាងវិញទៀត ជនជាប់ចោទម្នាក់ៗត្រូវដឹងពីសិទ្ធិរបស់ខ្លួនដើម្បីឲ្យខ្លួនអាចអនុវត្តសិទ្ធិទាំងនោះបាន។ ឧទាហរណ៍ ម.ស.ម.ក បានកត់សម្គាល់ឃើញសំណុំរឿងពីបទមជ្ឈិមជាច្រើន ជនជាប់ចោទពុំមានមេធាវីការពារនោះទេ ដែលប្រការនេះអាចបញ្ជាក់បានថា នៅតែមានភាពចាំបាច់សម្រាប់ចៅក្រមជំនុំជម្រះក្នុងការរម្លឹកពីសិទ្ធិរបស់ជនជាប់ចោទ ជាពិសេសសិទ្ធិមានមេធាវីការពារតាមផ្លូវច្បាប់ ដើម្បីធានានូវភាពស្មើគ្នានៃការតតាំង និងការជំនុំជម្រះដោយយុត្តិធម៌។

[20] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការរាជធានីភ្នំពេញ លោកចៅក្រម អៀង សៀង អនុប្រធានតុលាការ លោកចៅក្រម កោ វណ្ណី អនុប្រធានតុលាការ លោកព្រះរាជអាជ្ញារង សុខ រឿន លោកចៅក្រម សេង នាង លោកចៅក្រម អ៊ី ឋាវរៈ លោកស្រីចៅក្រម សែម សក្តិកូឡា និងលោកស្រីចៅក្រម ចាំង ស៊ីណាត នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

## សិទ្ធិមានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្ដី

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(៣)(ខ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួនជនគ្រប់រូបមានសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។"*
- **មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ:** *"ក្នុងរយៈពេល២៤ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី..."*
- **មាត្រា៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"មុនពេលសវនាការមេធាវីអាចពិនិត្យមើលសំនុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។ មេធាវីឬលេខារបស់មេធាវីអាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឲ្យធ្វើការចម្លងលិខិតសំណុំរឿងដោយខ្លួនជាអ្នកចេញសោហ៊ុយនិងនៅក្រោមការពិនិត្យរបស់ក្រឡាបញ្ជី។"*

បុគ្គលណា ដែលប្រឈមនឹងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌគួរតែត្រូវបានផ្តល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមការពារខ្លួនចំពោះបទចោទប្រកាន់ទាំងនោះ។ រយៈពេលដែលថា "គ្រប់គ្រាន់" អាស្រ័យលើប្រភេទ និងភាពស្មុគស្មាញនៃបទចោទប្រកាន់ ចំនួននៃបទចោទប្រកាន់ និងប្រភេទនៃភស្តុតាងក្នុងចំណោមកត្តាដទៃៗផ្សេងទៀត។ មធ្យោបាយចាំបាច់ក្នុងការរៀបចំការពារខ្លួនរាប់បញ្ចូលទាំងការទទួលបាននូវឯកសារ និងភស្តុតាងនានានៃសំណុំរឿង ដូច្នេះជនជាប់ចោទដឹងពីបទចោទប្រកាន់មកលើខ្លួនបានពេលលេញ ហើយជនជាប់ចោទអាចមានលទ្ធភាពផ្តល់ព័ត៌មានពេលលេញដល់មេធាវីរបស់ខ្លួន។

**តួលេខទី១០៖ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តីក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើមានអ្វីដែលបង្ហាញថា មេធាវីជនជាប់ចោទត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១ | ០,៣ | ៤ | ១ | ០ | ០ |
| គ្មាន | ៣៤០ | ៩៩,៧ | ៣២៧ | ៩៩ | ៤៧ | ១០០ |
| **តើមានបញ្ហាថេរវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីត្រូវបានលើកឡើងដោយភាគីជនជាប់ចោទដែរឬទេ?** | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |

| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
|---|---|---|---|---|---|---|
| មាន | ៥ | ១.៥ | ១ | ០.៣ | ០ | ០ |
| គ្មាន | ៣៣៦ | ៩៨.៥ | ៣៣០ | ៩៩.៧ | ៩៧ | ១០០ |

ជាការគួរឲ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា កង្វះពេលវេលា និង/ឬ មធ្យោបាយដើម្បីរៀបចំការពារខ្លួនគឺពុំមែនជាបញ្ហានោះទេនៅក្នុងចំនួនច្រើនលើសលប់នៃករណីទាំងអស់។ សិទ្ធិនេះបង្កើតបានផ្នែកជាមូលដ្ឋានមួយនៃការជំនុំជម្រះដោយយុត្តិធម៌ ហើយជាការចាំបាច់ដែលជនជាប់ចោទពីបទព្រហ្មទណ្ឌទាំងនោះ ព្រមទាំងមេធាវីរបស់ពួកគេក្នុងករណីដែលជនជាប់ចោទមានតំណាងស្របច្បាប់ ទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារករណីរបស់ខ្លួនក្នុងសវនាការឲ្យបានត្រឹមត្រូវ។ ក្នុងអំឡុងពេលរបាយការណ៍ទី៥ គ្រប់តុលាការដែលបានសង្កេតការណ៍ទាំងអស់លើកលែងតែតុលាការខេត្តបន្ទាយមានជ័យដែលមានចំនួន ៤ ករណីបង្ហាញថាមេធាវីត្រូវបានចាត់តាំងនៅថ្ងៃជំនុំជម្រះ បានគោរពតាមបទដ្ឋានជំនុំជម្រះដោយយុត្តិធម៌ទាំងនេះបាន ១០០%។ ទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍ទី៦បង្ហាញថាមានការធ្លាក់ចុះតិចតួចបំផុតក្នុងការប្រតិបត្តិតាមនៅក្នុងអំឡុងពេលរបាយការណ៍ទី៦។ មានតែចំនួនករណីតិចតួចប៉ុណ្ណោះបានបង្ហាញនូវភ័ត្តកង្វល់ហេតុដូចនេះ ម.ស.ម.ក ជឿជាក់ថាការប្រតិបត្តិតាម ១០០% អាចនឹងសម្រេចបានសារជាថ្មីនៅក្នុងពេលអនាគត។

កាលពីខែសីហា ឆ្នាំ២០១៣ តំណាងតុលាការខេត្តបន្ទាយមានជ័យបានពន្យល់ប្រាប់ថា តុលាការផ្ទាល់ប្រឈមនឹងផលលំបាកមួយចំនួនក្នុងការស្វែងរកមេធាវីពីគណៈមេធាវី (មានការពន្យារពេលយូរណាស់ទើបមានការឆ្លើយតប)។ ដោយពិចារណាដល់សិទ្ធិរបស់ជនជាប់ចោទដែលត្រូវទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល និងបន្ទាប់ពីមានការលើកពេលសវនាការច្រើនដងហើយនោះ ជារឿយៗ ចៅក្រមសម្រេចចាត់តាំងមេធាវីភ្លាមៗនៅថ្ងៃជំនុំជម្រះតែម្តងទៅ។[21]

## សិទ្ធិមានមេធាវី និង មានវត្តមាននៅក្នុងសវនាការ

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ៖** *"ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"*
- **មាត្រា១៤(៣)(ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយផ្នែកច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិប្រសិនបើខ្លួនគ្មានជំនួយផ្នែកច្បាប់ហើយត្រូវទទួលបានជំនួយផ្នែកច្បាប់សម្រាប់ខ្លួនក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ*

[21] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

*និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះបើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយផ្នែកច្បាប់ទេ។"*

- **មាត្រា៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរនៅក្នុងលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"*
- **មាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជំនួយពីមេធាវីត្រូវមានជាដាច់ខាតក្នុងករណីដូចតទៅ៖ (១)ករណីបទឧក្រិដ្ឋឬ (២)កាលណាជនជាប់ចោទជាអនីតិជន។"*

ការដែលត្រូវចោទប្រកាន់ពីបទល្មើសណាមួយអាចជាបទពិសោធន៍គួរឲ្យខ្លាច ហើយនីតិវិធីច្បាប់អាចមានភាពស្មុគស្មាញ និងច្របូកច្របល់ ហេតុដូច្នោះជាការសំខាន់ណាស់ដែលបុគ្គលគ្រប់រូបមានឱកាសទទួលបានមេធាវី។ សិទ្ធិមានមេធាវីធានាថាជនជាប់ចោទមានឱកាសក្នុងការទទួលបានការណែនាំផ្នែកវិជ្ជាជីវៈពីអ្នកជំនាញខាងតស៊ូមតិ ដែលមានលទ្ធភាពពន្យល់នូវបទចោទប្រកាន់ប្រឆាំងនឹងខ្លួន ពន្យល់ពីសិទ្ធិណែនាំពីដំណើរការជំនុំជម្រះ និងការពារផលប្រយោជន៍ដល់ខ្លួននៅក្នុងតុលាការ។ ជាសេចក្តីតម្រូវសម្រាប់បុគ្គលម្នាក់ត្រូវទទួលបានមេធាវី ប្រសិនបើបុគ្គលនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬក៏ជននោះជាអនីតិជន។ នៅខណៈដែលពុំមានការតម្រូវដោយច្បាប់ចំពោះការទទួលបានមេធាវី ប្រសិនជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម (លើកលែងតែអនីតិជន) ជននោះនៅតែមានជម្រើសមានមេធាវី បើខ្លួនត្រូវការ (ទោះបីជាយ៉ាងក្តី ករណីបែបនេះ បន្ទុកក្នុងការមានមេធាវីពុំស្ថិតលើតុលាការនោះទេ)។

**តួលេខទី១១៖ សិទ្ធិមានមេធាវីក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើជនជាប់ចោទទទួលបានជំនួយពីមេធាវីដែរឬទេ? (ទាំងសវនាការពីបទឧក្រិដ្ឋ និងបទមជ្ឈិម) | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ២១៤ | ៦៣ | ១៣៥ | ៤១ | ៣២ | ៦៨ |
| គ្មាន | ១២៧ | ៣៧ | ១៩៦ | ៥៩ | ១៥ | ៣២ |
| **តើជនជាប់ចោទទទួលបានជំនួយពីមេធាវីដែរឬទេ (សវនាការបទឧក្រិដ្ឋ)?** | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៥០ | ១០០ | ៨៥ | ៩៦ | ៩ | ១០០ |
| គ្មាន | ០ | ០ | ៤ | ៤ | ០ | ០ |

| តើជនជាប់ចោទទទួលបានជំនួយពីមេធាវីដែរឬទេ (សវនាការបទមជ្ឈិម)? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៦៤ | ៣៣,៥ | ៥០ | ២១ | ២៣ | ៦១ |
| គ្មាន | ១២៧ | ៦៦,៥ | ១៩២ | ៧៩ | ១៥ | ៣៩ |

ដោយពិនិត្យឃើញថា ការទទួលបានមេធាវីការពារចំពោះសវនការបទឧក្រិដ្ឋជាសេចក្តីតម្រូវដោយច្បាប់ ស្របពេលដែលទិន្នន័យបញ្ជាក់ពីកម្រិតខ្ពស់នៃការទទួលបានមេធាវី ម.ស.ម.ក យល់ថាតួលេខនេះគួរតែ ១០០% នៅគ្រប់តុលាការទាំងអស់។ ការជំនុំជម្រះបទឧក្រិដ្ឋណាដែលធ្វើឡើងដោយពុំមានមេធាវី គឺជាការអនុវត្តន៍បំពានក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ តុលាការខេត្តរតនគិរីជាគំរូវិជ្ជមានមួយដោយធានាថាច្បាប់ត្រូវបានគោរពតាមចំពោះសិទ្ធិទទួលបានមេធាវីនៅគ្រប់ករណី ដែល ម.ស.ម.ក បានសង្កេតការណ៍ ដែលជាការបន្តនូវអត្រាប្រតិបត្តិតាម ១០០% របស់ខ្លួនក្នុងអំឡុងពេលរបាយការណ៍ទី៥។ ខណៈដែលតួលេខនេះជាការគួរឲ្យលើកទឹកចិត្តយ៉ាងច្បាស់នោះ យើងគួរកត់សម្គាល់ថាមានបទឧក្រិដ្ឋតែ ៩ ករណីប៉ុណ្ណោះត្រូវបានសង្កេតការណ៍នៅតុលាការខេត្តរតនគិរី។ ហេតុដូច្នេះ ការប្រៀបធៀបដោយផ្ទាល់ជាមួយនឹងតុលាការដែលបានសង្កេតដទៃៗទៀត ដែលមានសំណុំរឿងច្រើនជាងនោះ គឺពុំសមរម្យនោះទេ។

ជាការគួរឲ្យខកចិត្តដោយឃើញថា កម្រិតនៃការមានមេធាវីចំពោះករណីបទមជ្ឈិមនៅតែមានកម្រិតទាប។ មានការកើនឡើងតិចតួចចំពោះកម្រិតនៃការទទួលបានមេធាវីសម្រាប់ករណីបទមជ្ឈិមនៅតុលាការរាជធានីភ្នំពេញ ពីចំនួន ៣៣% នៅក្នុងអំឡុងពេលរបាយការណ៍ទី៥ ទៅដល់ ៣៤% នៃអំឡុងពេលរបាយការណ៍ទី៦នេះ។ យ៉ាងណាក្តី ទាំងតុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី មានការធ្លាក់ចុះចំពោះអត្រាទទួលបានមេធាវីសម្រាប់បទមជ្ឈិមពីចំនួន ២៧% នៅតុលាការខេត្តបន្ទាយមានជ័យ និងចំនួន ៧៧% នៅតុលាការខេត្តរតនគិរីនៅក្នុងអំឡុងពេលរបាយការណ៍ទី៥ មកត្រឹមតចំនួន ២១% និង ៦១% នៃអំឡុងពេលរបាយការណ៍ទី៦ ជាពិសេសមានការធ្លាក់ចុះជាខ្លាំងនៅតុលាការខេត្តរតនគិរី។

នៅក្នុងជំនួបពិភាក្សាដាច់ដោយឡែកពីគ្នារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តរតនគិរី[22] និងតុលាការរាជធានីភ្នំពេញ[23] តំណាងតុលាការទាំងពីរនេះ បានឆ្លើយតបស្រដៀងគ្នាថា នៅក្នុងសំណុំរឿងពីបទមជ្ឈិមច្បាប់មិនតម្រូវឲ្យមានមេធាវីការពារនោះទេ ប៉ុន្តែអាស្រ័យថា តើជនជាប់ចោទស្នើសុំឲ្យមានមេធាវីការពារ ឬក៏អត់។ តំណាងតុលាការខេត្តបន្ទាយមានជ័យបានពន្យល់យ៉ាងខ្លី និងច្បាស់លាស់ថា កង្វះមេធាវី

[22] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តរតនគិរី លោកចៅក្រម សួស ឡា ប្រធានតុលាការ និងលោកចៅក្រម ឯក ប៉ូលីហ្វីល និងលោកចៅក្រម អ៊ី សុវណ្ណ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

[23] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការរាជធានីភ្នំពេញ លោកចៅក្រម អៀង សៀង អនុប្រធានតុលាការ លោកចៅក្រម កោវណ្ណី អនុប្រធានតុលាការ លោកព្រះរាជអាជ្ញារង សុខ រឿន លោកចៅក្រម សេង នាង លោកចៅក្រម អ៊ី ឋារះ លោកស្រីចៅក្រម សែម សក្តិកូឡា និងលោកស្រីចៅក្រម ចាំង ស៊ីណាត នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

ការពារនៅក្នុងខេត្តជាបញ្ហាប្រឈមដ៏ចម្បងរបស់តុលាការក្នុងការអនុវត្តន៍សិទ្ធិមានមេធាវីការពាររបស់ជនជាប់ចោទ។[24]

ទាក់ទិននឹងសិទ្ធិមានវត្តមាននៅក្នុងសវនាការ (ពុំបានរាយការណ៍ក្នុងអំឡុងពេលរបាយការណ៍ទី៥) ជនជាប់ចោទភាគច្រើនមានវត្តមាន។ អវត្តមានអាចបណ្តាលមកពីកត្តាច្រើនយ៉ាងរួមទាំងការគេចខ្លួន ឬការខកខានមិនបាននាំជនជាប់ចោទពីមន្ទីរឃុំឃាំងទៅកាន់តុលាការដើម្បីធ្វើការជំនុំជម្រះ។ បើយោងតាមប្រធានតុលាការខេត្តរតនគិរី[25] និងតំណាងតុលាការខេត្តបន្ទាយមានជ័យ[26] ជនជាប់ចោទមួយចំនួនពុំបានចូលបង្ហាញខ្លួននៅពេលសវនាការជំនុំជម្រះទេ ដោយសារតែជនជាប់ចោទទាំងនោះមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ទោះជាយ៉ាងនេះក្តី ម.ស.ម.ក ពុំមានសមត្ថកិច្ចក្នុងការផ្ទៀងផ្ទាត់ព័ត៌មាននេះទេ។

**តួលេខទី១២៖ សិទ្ធិមានវត្តមានក្នុងសវនាការក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើជនជាប់ចោទមានវត្តមានក្នុងសវនាការដែរឬទេ? (គ្រប់សវនាការទាំងអស់) | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៣១៤ | ៩២ | ២២០ | ៦៦ | ៣៩ | ៨៣ |
| គ្មាន | ២៧ | ៨ | ១១១ | ៣៤ | ៨ | ១៧ |
| តើជនជាប់ចោទមានវត្តមានក្នុងសវនាការដែរឬទេ (សវនាការបទឧក្រិដ្ឋ)? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៤៧ | ៩១ | ៤៣ | ៤៨ | ៦ | ៦៧ |
| គ្មាន | ១៤ | ៩ | ៤៦ | ៥២ | ៣ | ៣៣ |
| តើជនជាប់ចោទមានវត្តមានក្នុងសវនាការដែរឬទេ (សវនាការបទមជ្ឈិម)? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |

[24] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

[25] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តរតនគិរី លោកចៅក្រម សួស ឡា ប្រធានតុលាការ និងលោកចៅក្រម ឯក ប៉ូលីហ្វីល និងលោកចៅក្រម អ៊ី សុវណ្ណ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

[26] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
|---|---|---|---|---|---|---|
| មាន | ១៦៧ | ៩៣ | ១៧៧ | ៧៣ | ៣៣ | ៨៧ |
| គ្មាន | ១៣ | ៧ | ៦៥ | ២៧ | ៥ | ១៣ |

## សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ៖** *"ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។"*
- **មាត្រា១៤(២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មតជាមុនថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់។"*

សច្ចធារណ៍នៃនិរទោស គឺជាសិទ្ធិមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសកលថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សច្ចធារណ៍នេះឆ្លុះបញ្ចាំងពីគោលការណ៍ដែលថា បន្ទុកនៃភស្តុតាងស្ថិតនៅលើស្ថាប័នអយ្យការ មិនមែនជាបន្ទុករបស់ជនជាប់ចោទទេ ដូច្នេះ តុលាការត្រូវជឿជាក់ថាភស្តុតាងដែលបានលើកឡើងត្រូវបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទហួសពីវិមតិសង្ស័យ។ ពុំមែនអាស្រ័យលើជនជាប់ចោទក្នុងការបង្ហាញនូវភស្តុតាងដើម្បីបង្ហាញថា ខ្លួនជាជនគ្មានទោសនោះឡើយ។

**តួលេខទី១៣៖ ការសន្មតជាមុនថាគ្មានទោសក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានជាអ្នកទោសនៅពេលសវនាការដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ២៨៥ | ៨៣ | ០ | ០ | ៣៣ | ៧០ |
| គ្មាន | ៣០ | ៩ | ២១៨ | ៦៦ | ៦ | ១៣ |
| មិនពាក់ព័ន្ធ | ២៧ | ៨ | ១១៣ | ៣៤ | ៨ | ១៧ |

| តើជនជាប់ចោទត្រូវបានដាក់ខ្នោះក្នុងពេលសវនាការដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | ០ | ០ |

| | | | | | | |
|---|---|---|---|---|---|---|
| គ្មាន | ៣១៦ | ៩២,៥ | ២១៨ | ៦៦ | ៣៩ | ៨៣ |
| មិនពាក់ព័ន្ធ | ២៥ | ៧,៥ | ១១៣ | ៣៤ | ៨ | ១៧ |
| តើចៅក្រមបាននិយាយពីភាពមាន ឬគ្មានទោសរបស់ជនជាប់ចោទ មុនពេលប្រកាសសាលក្រមដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | ០ | ០ |
| គ្មាន | ៣៤១ | ១០០ | ៣៣១ | ១០០ | ៤៧ | ១០០ |

ទាំងនៅតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តរតនគិរី ចំនួននៃជនជាប់ចោទចូលរួមក្នុងសវនាការក្នុងឯកសណ្ឋានជាអ្នកទោសមានការកើនឡើងបន្តិច ដោយប្រៀបធៀបទៅនឹងអំឡុងពេលរបាយរណ៍ទី ៥ ដែលមាន ៧៥% នៅតុលាការរាជធានីភ្នំពេញ និង ៦៧% នៅតុលាការខេត្តរតនគិរីនៃចំនួនជនជាប់ចោទបានចូលសវនាការដោយស្លៀកសម្លៀកបំពាក់ជាអ្នកទោស នៅខណៈដែលតួលេខនេះមានចំនួន ៨៣% និង ៧០% នៅក្នុងអំឡុងពេលរបាយការណ៍ទី៦។ ចៅក្រម និងមន្ត្រីរបស់តុលាការបានពន្យល់ច្រើនលើកច្រើនសារហើយថា បញ្ហានេះគឺជាការទទួលខុសត្រូវខាងផ្នែកពន្ធនាគារ ពុំមែនជាការទទួលខុសត្រូវរបស់តុលាការនោះឡើយ។ យ៉ាងណាក្តី មានភាពប្រសើរឡើងជាខ្លាំងនៅតុលាការខេត្តបន្ទាយមានជ័យ ដែលការឲ្យជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានរបស់ពន្ធនាគារបង្ហាញនៅចំពោះមុខតុលាការ បានត្រូវលុបបំបាត់ជាផ្នែក (ជនជាប់ចោទខ្លះនៅតែស្លៀកខោរជាអ្នកទោស) ដោយប្រៀបធៀបទៅនឹងចំនួន ៣១% នៃចំនួនជនជាប់ចោទដែលបានចូលរួមសវនាការដោយស្លៀកសម្លៀកបំពាក់ជាអ្នកទោសក្នុងអំឡុងពេលរបាយការណ៍ទី៥។

នៅពេលដែលជនជាប់ចោទចូលរួមសវនាការដោយឯកសណ្ឋានពន្ធនាគារ សច្ចធារណ៍នៃនិរទោសត្រូវបានប៉ះពាល់ជាពិសេស នៅពេលដែលឯកសណ្ឋាននោះពុំបង្ហាញពីភាពខុសគ្នារវាងអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការ និងទណ្ឌិត។ នៅពេលដែលអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការចូលទៅតុលាការជាឯកសណ្ឋានពន្ធនាគារ ពួកគេត្រូវបានបង្ហាញក្នុងវិធីដូចគ្នានឹងអ្នកទោសដែលប្រហែលជាត្រូវបានផ្តន្ទាទោស និងកាត់ទោសរួចហើយពាក់ព័ន្ធនឹងបុគ្គល និងបទល្មើសមិនទាក់ទិនគ្នាដទៃផ្សេងទៀត។ ដោយសារតែពុំមានភាពខុសគ្នាត្រូវបានបញ្ជាក់រវាងប្រភេទទាំងពីរនេះរបស់អ្នកទោស ការអនុវត្តន៍នេះធ្វើឲ្យមានការសន្មតយ៉ាងជាក់ស្តែងថា ជនជាប់ចោទគឺពិតជាជនល្មើសដែលត្រូវបានផ្តន្ទាទោសរួចហើយ។ សូម្បីតែនៅពេលជនជាប់ចោទកំពុងអនុវត្តទោស ហេតុដែលថាជនជាប់ចោទទាំងនោះបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារគឺធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍យុត្តិធម៌ដូចគ្នាដែរ។ ការអនុវត្តន៍បែបនេះបង្ហាញភស្តុតាងដោយប្រយោលនៃការប្រព្រឹត្ត និងការផ្តន្ទាទោសពីមុនដែលមិនត្រូវបានបញ្ញត្តនៅត្រង់ចំណុចណាមួយក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយដែលធ្វើឲ្យប៉ះពាល់ទៀតដល់សច្ចធារណ៍នៃនិរទោស។

ប្រធានតុលាការខេត្តរតនគិរី អះអាងថា ចាប់តាំងពីពេលដែលលោកត្រូវបានតែងតាំងជាប្រធាននៅចុងឆ្នាំ២០១២មក លោកបានណែនាំដល់មន្ត្រីតុលាការថា ជនជាប់ចោទមិនគួរចូលបង្ហាញខ្លួនក្នុងឯក

សណ្ដានអ្នកទោសទេ លើកលែងតែជនទាំងឡាយណាដែលត្រូវបានតុលាការផ្ដន្ទាទោសជាស្ថាពរចំពោះបទល្មើសណាមួយ។ យ៉ាងណាក្ដី ម.ស.ម.ក ពុំអាចផ្ទៀងផ្ទាត់ព័ត៌មាននេះបានទេ ដោយសារតែសកម្មភាពសង្កេតការណ៍របស់ ម.ស.ម.ក នៅតុលាការខេត្តរតនគិរីនេះបានបញ្ចប់នៅខែមិថុនា ឆ្នាំ២០១២។ តំណាងតុលាការខេត្តបន្ទាយមានជ័យបានទទួលស្គាល់ថា ជនជាប់ចោទភាគច្រើនបានបង្ហាញខ្លួនដោយមានខោជាអ្នកទោស និងអាវជាឯកសណ្ឋានធម្មតា តែតំណាងតុលាការបានបញ្ជាក់ថា នេះជាការទទួលខុសត្រូវរបស់ពន្ធនាគារ ជាជាងការទទួលខុសត្រូវរបស់តុលាការ។ យ៉ាងណាក៏ដោយ តំណាងតុលាការបានប្ដេជ្ញាធ្វើកិច្ចការនេះជាមួយនឹងពន្ធនាគារ ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវឲ្យមានលក្ខណៈជាប្រព័ន្ធលើឯកសណ្ឋានស៊ីវិលរបស់ជនជាប់ចោទ។[27]

## ភាពឯករាជ្យ ភាពមិនលម្អៀង និង វិជ្ជាជីវៈរបស់ចៅក្រម

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញ៖** *"អំណាចតុលាការជាអំណាចឯករាជ្យ។អំណាចតុលាការធានារក្សាអនាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។"*
- **មាត្រា១៣២ នៃរដ្ឋធម្មនុញ្ញ៖** *"ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។"*
- **មាត្រា១៤ (១) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"ក្នុងការសម្រេចផ្ដន្ទាទោសឧក្រិដ្ឋទៅលើជនណាម្នាក់ និង ក្នុងការសម្រេចអំពីសិទ្ធិ និង កាតព្វកិច្ចរបស់ជនណាម្នាក់ក្នុងករណីមានការប្ដឹងផ្ដល់សាមីខ្លួនត្រូវមានសិទ្ធិស្នើសុំឲ្យមានការកាត់សេចក្ដីឲ្យបានសមរម្យជាសាធារណៈដោយសាលាក្ដីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងដែលបង្កើតឡើងដោយច្បាប់។"*

សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀងគឺជាគ្រឹះធំមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជនជាប់ចោទត្រូវជំនុំជម្រះដោយផ្អែកលើភាពសត្យានុម័ត និងការបង្ហាញពីពិរុទ្ធភាព វិមតិសង្ស័យ ត្រូវតែសម្អាងទាំងស្រុងលើភស្ដុតាងដែលអនុញ្ញាតឲ្យបង្ហាញទៅតុលាការ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នេះ ត្រូវបានអធិប្បាយដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប ថាជា *"សិទ្ធិមួយដាច់ខាត គ្មានករណីលើកលែង"*[28] ប្រាកដណាស់ ប្រសិនបើតុលាការពុំឯករាជ្យ ឬ លម្អៀង ដូច្នេះ រាល់សិទ្ធិទទួលបានការជំនុំជម្រះដទៃៗទៀតក្លាយទៅជាឥតប្រយោជន៍។ តុលាការដែលទទួលរង និងទទួលឥទ្ធិពលពីប្រភពខាងក្រៅពុំមានសមត្ថភាពក្នុងការបំពេញតួនាទីរបស់ខ្លួនដើម្បីធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌នោះទេ។

---

[27] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តរតនគិរី លោកចៅក្រម សួស ឡា ប្រធានតុលាការ និងលោកចៅក្រម ឯក ប៉ូលីហ្វីល និងលោកចៅក្រម អ៊ី សុវណ្ណ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

[28] គណៈកម្មាធិការសិទ្ធិមនុស្ស - ទស្សនៈនៃគណៈកម្មាធិការសិទ្ធិមនុស្សតាមមាត្រា៥កថាខណ្ឌទី៤ នៃពិធីសារបន្ថែមរបស់កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយកថាខណ្ឌ៥.២នៃសេចក្ដីជូនដំណឹងលេខ២៦៣/១៩៨៧៖ *អិម. ហ្គនហ្សាឡេស ដេលរីយ៉ូ ជាមួយនឹងប្រទេសប៉េរូ* (ក.ស.អ.ស.ព.ន/គ/៤៦/ឃ/២៦៣/១៩៨៧) ចុះថ្ងៃទី២៨ខែតុលាឆ្នាំ១៩៩២។

**តូលេខទី១៤៖ ឯករាជ្យភាព ភាពមិនលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រមក្នុងអំឡុងពេលរបាយការណ៍ទី៦**

<table>
<tr><td colspan="7">តើមានអ្វីមួយបង្ហាញថា ចៅក្រមមានប្រយោជន៍នៅក្នុងរឿងក្តីដោយសារតួនាទីនៅក្នុងវិស័យតុលាការដែរឬទេ?</td></tr>
<tr><td rowspan="2">ទិន្នន័យ</td><td colspan="2">តុលាការរាជធានីភ្នំពេញ</td><td colspan="2">តុលាការខេត្តបន្ទាយមានជ័យ</td><td colspan="2">តុលាការខេត្តរតនគិរី</td></tr>
<tr><td>ចំនួន</td><td>ភាគរយ</td><td>ចំនួន</td><td>ភាគរយ</td><td>ចំនួន</td><td>ភាគរយ</td></tr>
<tr><td>មាន</td><td>០</td><td>០</td><td>០</td><td>០</td><td>០</td><td>០</td></tr>
<tr><td>គ្មាន</td><td>១៨៣</td><td>១០០</td><td>១៥១</td><td>១០០</td><td>៣០</td><td>១០០</td></tr>
<tr><td colspan="7">តើមានអ្វីមួយបង្ហាញថា ភាគីណាមួយបាននិយាយជាមួយចៅក្រមក្នុងអំឡុងពេលពិភាក្សាចេញសេចក្តីសម្រេចដែរឬទេ?</td></tr>
<tr><td rowspan="2">ទិន្នន័យ</td><td colspan="2">តុលាការរាជធានីភ្នំពេញ</td><td colspan="2">តុលាការខេត្តបន្ទាយមានជ័យ</td><td colspan="2">តុលាការខេត្តរតនគិរី</td></tr>
<tr><td>ចំនួន</td><td>ភាគរយ</td><td>ចំនួន</td><td>ភាគរយ</td><td>ចំនួន</td><td>ភាគរយ</td></tr>
<tr><td>មាន</td><td>៦</td><td>៣</td><td>០</td><td>០</td><td>០</td><td>០</td></tr>
<tr><td>គ្មាន</td><td>២៦</td><td>១៤</td><td>១</td><td>០.៧</td><td>១៤</td><td>៤៧</td></tr>
<tr><td>មិនដឹង</td><td>១៥១</td><td>៨៣</td><td>១៣៩</td><td>៩៨,៦</td><td>១៦</td><td>៥៣</td></tr>
</table>

បើទោះជាករណី ដែលមានភាគីដទៃទៀតមានឱកាសក្នុងនិយាយទៅកាន់ចៅក្រមក្នុងអំឡុងពេលកិច្ចពិភាក្សានៅមានកម្រិតទាប ជាការសំខាន់ដែលថាករណីបែបនេះត្រូវលុបបំបាត់ទាំងស្រុង។ ខណៈដែលទិន្នន័យរបស់មន្ត្រីសង្កេតការណ៍សវនាការរបស់ ម.ស.ម.កបានប្រមូលពុំបង្ហាញច្បាស់លាស់ថា មានករណីណាខ្លះមានការជ្រៀតជ្រែកនៅក្នុងកិច្ចពិភាក្សាណាមួយនោះ ចៅក្រមត្រូវតែធានាថា ការប្រព្រឹត្តរបស់ខ្លួនមិនធ្វើឲ្យមានការយល់ឃើញថាករណីនេះអាចកើតឡើងនោះឡើយ។

ជារឿងចាំបាច់សម្រាប់ចៅក្រមក្នុងការផ្តល់នូវគំរូនៃវិជ្ជាជីវៈរបស់ខ្លួនគ្រប់ពេលវេលាទាំងអស់ បើសិនជាចង់ធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់តុលាការកម្ពុជាមានភាពប្រសើរនៅក្នុងក្រសែភ្នែកអ្នកអង្កេតការណ៍ជាតិ និងអន្តរជាតិ។ ជាប្រការគួរឲ្យស្តាយដែរ បញ្ហាចៅក្រមលើកទូរសព្ទដៃនៅបន្តកើនឡើងខ្ពស់នៅតុលាការដែលបានសង្កេតការណ៍ ហើយហាក់ដូចជាពុំបានធ្វើឲ្យប្រសើរសោះ។

តួលេខទី១៥៖ វិជ្ជាជីវៈរបស់ចៅក្រម ការប្រើប្រាស់ទូរសព្ទដៃរបស់ចៅក្រមនៅក្នុងសវនាការក្នុងអំឡុងពេលរបាយការណ៍ទី៦

| តើចៅក្រមនិយាយទូរសព្ទដៃរឬទេ ក្នុងអំឡុងពេលសវនាការ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៣៥ | ១៩ | ២៩ | ២១ | ៥ | ១៧ |
| គ្មាន | ១៤៨ | ៨១ | ១១២ | ៧៩ | ២៥ | ៨៣ |
| ប្រសិនបើមាន តើចៅក្រមឆ្លើយតបបែបណា? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ឆ្លើយដោយខ្លីហើយដាក់ចុះ | ៩ | ២៦ | ១៣ | ៤៦ | ៥ | ១០០ |
| បន្តការសន្ទនាតាមទូរសព្ទ | ២៦ | ៧៤ | ១៦ | ៥៤ | ០ | ០ |

តាមទិន្នន័យបង្ហាញថា ការប្រើប្រាស់ទូរសព្ទដោយចៅក្រមនៅបន្តកើតឡើងក្នុងអំឡុងពេលរបាយការណ៍ទី៦។ នៅគ្រាដែលមានការធ្លាក់ចុះចំពោះការនិយាយទូរសព្ទនៅតុលាការរាជធានីភ្នំពេញ (ពីចំនួន ៣២% ក្នុងអំឡុងពេលរបាយការណ៍ទី៥ មកត្រឹមចំនួន ១៩%) មានការកើនឡើងជាភាគរយនៃករណីដែលចៅក្រមបាននិយាយទូរសព្ទក្នុងអំឡុងពេលសវនាការនៅតុលាការខេត្តបន្ទាយមានជ័យ និងនៅតុលាការខេត្តរតនគិរី (ពីចំនួន ១៨% នៅតុលាការខេត្តបន្ទាយមានជ័យ និងចំនួន ៩% នៅតុលាការខេត្តរតនគិរី ក្នុងអំឡុងពេលរបាយការណ៍ទី៥ ទៅដល់ចំនួន ២១% និង ១៧%)។

ប្រធានតុលាការខេត្តរតនគិរី បានទទួលស្គាល់ថា ចៅក្រមខ្លះលើកទូរសព្ទឆ្លើយក្នុងអំឡុងពេលសវនាការជំនុំជម្រះ និងថា ទោះបីជាគ្មានច្បាប់ណាមួយហាមឃាត់ចៅក្រម និងព្រះរាជអាជ្ញាមិនឲ្យឆ្លើយទូរសព្ទរបស់ខ្លួនយ៉ាងណាក៏ដោយ ការឆ្លើយទូរសព្ទបែបនេះមិនត្រឹមត្រូវតាមក្រមសីលធម៌ និងវិជ្ជាជីវៈកម្រិតខ្ពស់របស់ចៅក្រម និងព្រះរាជអាជ្ញានោះទេ។ ប្រធានតុលាការក៏បានប្ដេជ្ញាផងដែរថា នឹងចេញសេចក្ដីណែនាំស្នើដល់ចៅក្រមកុំឲ្យលើកទូរសព្ទឆ្លើយនៅពេលសវនាការជំនុំជម្រះ លើកលែងតែព្រះរាជអាជ្ញាដែលចាំបាច់ត្រូវឆ្លើយតបទៅនឹងការស្នើសុំយោបល់ជាបន្ទាន់ពីមន្ត្រីនគរបាលយុត្តិធម៌គ្រប់ពេលវេលា នៅក្នុងដែនសមត្ថ

កិច្ចរបស់ខ្លួន។[29] ផ្ទុយទៅវិញ តំណាងតុលាការខេត្តបន្ទាយមានជ័យ[30] និងតុលាការរាជធានីភ្នំពេញ[31] បានឆ្លើយតបថា ចៅក្រមលើកទូរសព្ទឆ្លើយតែក្នុងករណីចាំបាច់តែប៉ុណ្ណោះ ដូចជា ការស្នើសុំយោបល់ពីមន្ត្រីនគរបាលយុត្តិធម៌ ឬ សំណុំរឿងដែលស្ថិតក្រោមការស៊ើបសួរ។

**តួលេខ ១៦៖ ទិដ្ឋភាពទូទៅនៃការប្រើប្រាស់ទូរសព្ទដោយចៅក្រម**

| តើចៅក្រមនិយាយទូរសព្ទដែរឬទេ ក្នុងអំឡុងពេលសវនាការ? | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៧ | ២៨ | ១៥១ | ២៨ | ១២៦ | ២២ | ៧៣ | ១៨ | ១២៨ | ២៧ | ៦៩ | ១៩ |
| គ្មាន | ៤៣ | ៧២ | ៣៨១ | ៧២ | ៤៥៩ | ៧៨ | ៣២៥ | ៨២ | ៣៤៥ | ៧៣ | ២៨៥ | ៨១ |
| ប្រសិនបើមាន តើចៅក្រមឆ្លើយតបបែបណា? | | | | | | | | | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ឆ្លើយដោយខ្លីហើយដាក់ចុះ | ១១ | ៦៥ | ៨២ | ៥៤ | ៨២ | ៦៥ | ៤៤ | ៦០ | ៥២ | ៤៤ | ២៧ | ៤០ |
| បន្តការសន្ទនាតាមទូរសព្ទ | ៦ | ៣៥ | ៦៩ | ៤៦ | ៤៤ | ៣៤ | ២៩ | ៤០ | ៦៦ | ៥៦ | ៤២ | ៦០ |

បើទោះជាកម្រិតនៃការប្រើប្រាស់ទូរសព្ទ នៅតែពុំមានការផ្លាស់ប្តូរទូលំទូលាយក្នុងរយៈពេលនៃការអនុវត្តន៍គម្រោងនេះក្តី ជាការពិតមានការកើនឡើងនូវភាគរយនៃចំនួនករណី ដែលចៅក្រមធ្វើការសន្ទនាតាមទូរសព្ទក្នុងអំឡុងពេលការជំនុំជម្រះ ដែលខុសគ្នាទៅនឹងការនិយាយដោយខ្លី ហើយដាក់ទូរសព្ទចុះវិញ។ ការនិយាយទូរសព្ទក្នុងកំឡុងពេលជំនុំជម្រះគឺមិនអាចទទួលយកបាននោះទេ។ ចៅក្រមត្រូវតែប្រើ

[29] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តរតនគិរី លោកចៅក្រម សួស ឡា ប្រធានតុលាការ និងលោកចៅក្រម ឯក ប៉ូលីហ្វីល និងលោកចៅក្រម អ៊ី សុវណ្ណ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

[30] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

[31] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការរាជធានីភ្នំពេញ លោកចៅក្រម អឿង សៀង អនុប្រធានតុលាការ លោកចៅក្រម កោវណ្ណី អនុប្រធានតុលាការ លោកព្រះរាជអាជ្ញារង សុខ រឿន លោកចៅក្រម សេង នាង លោកចៅក្រម អ៊ី ឋាវរៈ លោកស្រីចៅក្រម សែម សក្តិកូឡា និងលោកស្រីចៅក្រម ចាំង ស៊ីណាត នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

ទូរសព្ទរបស់ខ្លួននៅពេលដែលតុលាការសម្រាក ឬក៏ក្នុងករណីការងារផ្លូវការរបស់តុលាការ សមាជិករបស់តុលាការដទៃទៀតគួរធ្វើសារ។ នៅក្នុងពេលជំនុំជម្រះ ចៅក្រមត្រូវតែផ្ដោតយកចិត្តទុកដាក់ទាំងស្រុងលើភស្តុតាងដែលត្រូវបង្ហាញ ហើយមិនអាចត្រូវមានការរំខានដោយបញ្ហាណាមួយឡើយខណៈពេលសវនាការកំពុងប្រព្រឹត្តទៅ។

## សិទ្ធិបង្ហាញភស្តុតាង

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(៣)(ង) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"ជនគ្រប់រូបមានសិទ្ធិ [...] មានការសួរចម្លើយឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុកនិងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។"*
- **មាត្រា១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានប្រយោជន៍ក្នុងការសំដែងឲ្យឃើញការពិត[...]ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ[...]និងសាក្សីផងបានដែរ។"*
- **មាត្រា២៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ជនជាប់ចោទនិងដើមបណ្ដឹងរដ្ឋប្បវេណីអាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយណា ដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ។"*
- **មាត្រា៣២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"នៅពេលបើកពិភាក្សាដេញដោល ភាគីអាចសុំឲ្យតុលាការស្ដាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គល ដែលមានវត្តមាននៅក្នុងបន្ទប់ប៉ុន្តែមិនកោះហៅឲ្យត្រឹមត្រូវទេ។ ការស្ដាប់ចម្លើយសាក្សីនេះត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណនិងអញ្ជើញសាក្សីនេះឲ្យថយទៅនៅក្នុងបន្ទប់រង់ចាំ។"*
- **មាត្រា៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ប្រធានសវនាការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីជនរងគ្រោះសាក្សី និងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ថាមានប្រយោជន៍ [...] ព្រះរាជអាជ្ញាមេធាវីនិងភាគីអាចត្រូវបានឲ្យលើកសំណួរសួរ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការនិងមេធាវីសំណួរផ្សេងទៀតត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ាប្រធានសវនាការសម្រេចដោយឥស្សរចិត្តថាតើសំណួរនេះត្រូវតែសួរឬទេ។"*

រាល់សេចក្ដីសម្រេចទាំងអស់របស់តុលាការត្រូវតែផ្អែកទាំងស្រុងលើភស្តុតាង ដែលបានបង្ហាញនៅក្នុងដំណាក់កាលនៃការជំនុំជម្រះ។ ដូច្នេះ ជាការសំខាន់ដែលភាគីនីមួយៗមានឱកាសដើម្បីបង្ហាញនូវភស្តុតាង និងហៅសាក្សីនានាជាការគាំទ្រទៅលើសំណុំរឿងរបស់ខ្លួន។[32] ជាការចាំបាច់ដូចគ្នា ដែលភាគីនីមួយៗត្រូវបានផ្ដល់ឱកាសដើម្បីសួរដេញដោលសាក្សី និងធ្វើការបដិសេធនូវភស្តុតាងដែលខ្លួនមិនទទួលយក។

[32] មាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ហេតុដូច្នេះ ដូចទិន្នន័យខាងក្រោមចង្អុលបង្ហាញ ជាការគួរឲ្យលើកទឹកចិត្តដោយឃើញថាមានករណីតិចតួចប៉ុណ្ណោះដែលភស្តុតាងពុំត្រូវបានបង្ហាញ ឬនៅពេលដែលមានការបង្ហាញមួយថាភាគីមួយត្រូវបានហាមឃាត់ពីការបង្ហាញភស្តុតាង។

**តួលេខទី១៧៖ សិទ្ធិបង្ហាញភស្តុតាងក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើភស្តុតាងត្រូវបានបង្ហាញដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៨៣ | ១០០ | ១៣៥ | ៩៦ | ៣០ | ១០០ |
| គ្មាន | ០ | ០ | ៦ | ៤ | ០ | ០ |
| **តើមានអ្វីមួយ ដែលបង្ហាញថាភាគីណាមួយមិនទទួលបានឱកាសបង្ហាញភស្តុតាងដែរឬទេ?** | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | ០ | ០ |
| គ្មាន | ១៨៣ | ១០០ | ១៤១ | ១០០ | ៣០ | ១០០ |

ភស្តុតាងត្រូវបានបង្ហាញនៅគ្រប់ករណីទាំងអស់ លើកលែងតែចំនួន ៦ ករណី (ដែលករណីទាំង ៦ នេះកើតឡើងនៅតុលាការខេត្តបន្ទាយមានជ័យ)។ ទិន្នន័យប្រមូលបាននៅក្នុងអំឡុងពេលរបាយការណ៍ទី៦ បង្ហាញពីការបន្តប្រកាន់ខ្ជាប់លើសិទ្ធិបង្ហាញភស្តុតាងក្នុងកម្រិតខ្ពស់ បើប្រៀបធៀបជាមួយនឹងអំឡុងពេលរបាយការណ៍មុនៗ។

ចំនួនដ៏ច្រើនលើសលុបនៃភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ ដែលបានសង្កេតការណ៍គឺភស្តុតាងជាឯកសារ។ នៅគ្រាដែលមានការគួរឲ្យសរសើរដោយឃើញថាតុលាការបន្តស្វែងរកភស្តុតាងនៅក្នុងដំណាក់កាលនៃការជំនុំជម្រះតុលាការត្រូវតែធានាផងដែរថាភស្តុតាងដែលត្រូវបានយកមកធ្វើសម្អាង គឺមានគុណភាពគ្រប់គ្រាន់ ហើយគ្រប់ភាគីទាំងអស់មានឱកាសក្នុងការតតាំងនឹងភស្តុតាងទាំងនោះ។ បន្ថែមពីលើភស្តុតាងជាឯកសារ ចៅក្រម និងព្រះរាជអាជ្ញាគួរតែធ្វើការស្វែងរក និងធ្វើការត្រួតពិនិត្យឲ្យបានខ្លាំងក្លាទៅលើប្រភេទនៃភស្តុតាងដែលពាក់ព័ន្ធដទៃៗទៀត ដូចជា ភស្តុតាងផ្នែកវេជ្ជសាស្ត្រ និងភស្តុតាងផ្នែកបច្ចេកទេស។

នៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សាជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យកាលពីខែសីហា ឆ្នាំ ២០១៣ តំណាងតុលាការបានអះអាងបញ្ជាក់ថា ជាគោលការណ៍ ភស្តុតាងអាចដាក់ជូនតុលាការពិនិត្យបាន

ដោយសេរី លើកលែងតែករណីណាដែលភស្តុតាងនោះត្រូវបានពិនិត្យពិចារណាដោយចៅក្រមជំនុំជម្រះរួចរាល់ហើយ និង/ឬ ភស្តុតាងទាំងឡាយណាដែលមិនពាក់ព័ន្ធ ព្រមទាំងអាចធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធី។[33]

### តួលេខ១៨៖ ទិដ្ឋភាពទូទៅចំពោះសិទ្ធិបង្ហាញភស្តុតាង

| តើភស្តុតាងត្រូវបានបង្ហាញដែរឬទេ? | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៥៣ | ៧៧ | ៥១២ | ៩៦ | ៥៦៩ | ៩៧ | ៣៩៤ | ៩៩ | ៤៥៧ | ៩៩ | ៣៤៨ | ៩៨ |
| គ្មាន | ៤៦ | ១៣ | ២០ | ៤ | ១៦ | ៣ | ៤ | ១ | ៦ | ១ | ៦ | ២ |
| តើមានអ្វីមួយ ដែលបង្ហាញថាភាគីណាមួយមិនទទួលបានឱកាសបង្ហាញភស្តុតាងដែរឬទេ? | | | | | | | | | | | | |
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៣ | ២ | ៣ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| គ្មាន | ១៩៦ | ៩៨ | ៥២៩ | ៩៩ | ៥៨៥ | ១០០ | ៣៩៨ | ១០០ | ៤៦៣ | ១០០ | ៣៥៤ | ១០០ |

មានករណីតែមួយប៉ុណ្ណោះដែលភាគីម្ខាងត្រូវបានបដិសេធសិទ្ធិក្នុងការហៅសាក្សី។ ករណីនេះគឺនៅតុលាការរាជធានីភ្នំពេញ និងជាការជំនុំជម្រះទៅលើអ្នកតវ៉ាបឹងកក់ (សូមមើលករណីសិក្សាខាងក្រោម)។

### តួលេខទី១៩៖ សិទ្ធិហៅ និងសាកសួរសាក្សីក្នុងអំឡុងពេលរបាយការណ៍ទី៦

| តើមានអ្វីមួយបង្ហាញថា ភាគីណាមួយមិនបានទទួលឱកាសកោះហៅសាក្សីដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១ | ០.៥ | ០ | ០ | ០ | ០ |

[33] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

| | | | | | | |
|---|---|---|---|---|---|---|
| គ្មាន | ១៨២ | ៩៩.៥ | ១៤១ | ១០០ | ៣០ | ១០០ |
| មិនពាក់ព័ន្ធ | ០ | ០ | ០ | ០ | ០ | ០ |
| ក្នុងករណីដែលសាក្សីត្រូវបានកោះហៅ តើសាក្សីមានវត្តមានក្នុងបន្ទប់សវនាការមុនពេលត្រូវបានសាកសួរដែរឬទេ? | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៥ | ១៨ | ៣ | ១៤ | ០ | ០ |
| គ្មាន | ២៣ | ៨២ | ១៨ | ៨៦ | ១៧ | ១០០ |

តំណាងតុលាការខេត្តបន្ទាយមានជ័យបានពន្យល់ប្រាប់ថា វត្តមានរបស់សាក្សីនៅក្នុងបន្ទប់សវនាការមុនពេលត្រូវបានស្តាប់ចម្លើយ គឺជាកង្វះខាតសមត្ថភាពផ្នែកបច្ចេកទេសរបស់ចៅក្រមម្នាក់ៗនៅក្នុងការដឹកនាំសវនាការ។ ហេតុដូច្នេះ តំណាងតុលាការបានផ្តល់ជាអនុសាសន៍ក្នុងការពង្រឹងបន្ថែមលើសមត្ថភាពរបស់ចៅក្រម។[34]

<u>**ករណីសិក្សា៖ សវនាការលើសំណុំរឿងអ្នកតវ៉ាតំបន់បឹងកក់**</u>

**កាលបរិច្ឆេទ៖** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២

**តុលាការ៖** តុលាការរាជធានីភ្នំពេញ

**ចៅក្រម៖** ឮ ពៅស៊ុន

**ចោទប្រកាន់៖**

<u>មាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ៖ បទប្រឆាំងនឹងអ្នករាជការសាធារណៈ</u>

*"ការប្រឆាំងនឹងអ្នករាជការសាធារណៈ គឺជាអំពើប្រឆាំងដោយប្រើការតទល់ដោយហិង្សានឹងអ្នករាជការសាធារណៈដែលធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់ បញ្ជារបស់អាជ្ញាធរសាធារណៈ ឬសេចក្តីសម្រេចរបស់តុលាការ។ បទប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៣ខែ និងពិន័យជាប្រាក់ពី១សែនរៀល ទៅ ៥សែនរៀល"។*

<u>មាត្រា៥០៤ នៃក្រមព្រហ្មទណ្ឌ៖ ស្ថានទម្ងន់ទោស (បទប្រឆាំងនឹងអ្នករាជការសាធារណៈ)៖</u>

*"ការប្រឆាំងនឹងអ្នករាជការសាធារណៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ១ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លានរៀល ទៅ ២ លានរៀលនៅក្នុងករណីដូចតទៅ៖*

[34] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

*(១) ការប្រឆាំងនឹងអ្នករាជការសាធារណៈ បានប្រព្រឹត្តដោយបុគ្គលច្រើនរូប ធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត។*

*(២) ចារីមានអាវុធ"។*

<u>មាត្រា២៥៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១៖ អំពីការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ៖</u>

*"ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្តន្ទាទោសជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ៥០.០០០.០០០ រៀល (ហាសិបលានរៀល) និង/ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំដល់ ៥ (ប្រាំ) ឆ្នាំ។*

*ចារីត្រូវមានកាតព្វកិច្ចចាកចេញពីទ្រព្យសម្បត្តិសាធារណៈនោះជាបន្ទាន់។ ចារីគ្មានសិទ្ធិទារកំរៃអំពីពលកម្ម ឬការរៀបចំដែលបានធ្វើលើទ្រព្យនោះឡើយ។*

*ក្នុងករណីដែលអ្នកកំពុងកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ មុនច្បាប់នេះចូលជាធរមាន ហើយមានឯកសារសម្អាង និងបញ្ជាក់ជាក់លាក់ថា ខ្លួនបានទិញពីជនណាម្នាក់អាចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចដើម្បីអនុវត្តតាមវិធានច្បាប់ចំពោះបុគ្គលដែលបានលក់ទ្រព្យសម្បត្តិសាធារណៈនេះដោយខុសច្បាប់ និងដើម្បីជាប្រយោជន៍របស់ខ្លួនដែលបានរងគ្រោះដោយសារទង្វើនេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជនរងគ្រោះនេះពុំមានសិទ្ធិកាន់កាប់បន្តលើទ្រព្យសម្បត្តិសាធារណៈបានឡើយ។"*

<u>មាត្រា៣៤ នៃច្បាប់ភូមិបាលឆ្នាំ២០០១៖ និយមន័យនៃការកាន់កាប់ទ្រព្យសម្បត្តិដោយខុសច្បាប់៖</u>

*អ្នកកាន់កាប់ថ្មីលើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ឬបុគ្គលឯកជនដោយគ្មានប័ណ្ណក្រោយច្បាប់នេះចូលជាធរមាន ត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោសដូចមានចែងក្នុងមាត្រា២៥៩ នៃច្បាប់នេះ។*

**ធាតុផ្សំនៃបទល្មើសដែលត្រូវបានបង្ហាញឡើងដើម្បីធានាការផ្តន្ទាទោស៖**
១. អ្នករាជការសាធារណៈត្រូវបានប្រឆាំង
២. អ្នករាជការសាធារណៈកំពុងតែបំពេញតួនាទីរបស់ខ្លួនដើម្បីអនុវត្តច្បាប់ ឬបញ្ជាពីអាជ្ញាធរសាធារណៈ ឬសេចក្តីសម្រេចរបស់តុលាការ។
៣. ការប្រឆាំងនឹងអ្នករាជការសាធារណៈត្រូវបានធ្វើឡើងដោយចារីច្រើនរូប ហើយចារីនោះមានកាន់អាវុធ។
៤. ចារីនោះគឺ "អ្នកកាន់កាប់" លើដី ហើយជាធម្មតាមិនបង្ហាញពីគោលបំណងនៃការធ្វើបាតុកម្មជាបណ្តោះអាសន្ន។
៥. ដីដែលបានកាន់កាប់នោះគឺ "ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ" ឬជាកម្មសិទ្ធិរបស់បុគ្គលសាធារណៈឬបុគ្គលឯកជន។

**សាវតារ៖**

នាព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ក្រុមស្ត្រី ១៣ រូបត្រូវបានចាប់ខ្លួន និងឃុំខ្លួនចំពោះការជាប់ពាក់ព័ន្ធក្នុងបាតុកម្មមួយដែលបានកើតឡើងនៅតំបន់បឹងកក់។ ក្នុងចំណោមស្ត្រីទាំងនោះ មានស្ត្រីវ័យចំណាស់អាយុ៧២ ឆ្នាំម្នាក់បានធ្វើការតវ៉ាជាការគាំទ្រដល់គ្រួសារមួយដែលព្យាយាមសាងសង់លំនៅដ្ឋាន

របស់ខ្លួនដែលត្រូវបានបំផ្លាញដោយក្រុមហ៊ុន ស៊ូកាគូ ដែលជាម្ចាស់ដីមានទំនាស់នោះ(កម្មសិទ្ធិរបស់សមាជិកព្រឹទ្ធសភា ឡៅ ម៉េងឃិន មកពីគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សគ្រប់គ្រងអំណាច)។ ខ្សែអាត់វីដេអូនៃការបង្ក្រាបបាតុកម្មរបស់នគរបាល និងការចាប់ខ្លួនស្ត្រីទាំង ១៣ រូបនោះអាចស្វែងរកបានតាមរយៈ៖

http://www.youtube.com/watch?v=kkUDHMENOSI&list=UUOrJ1nXDwVTGLW35asZ06OA&index=2&feature=plcp

**របៀបដំណើរការនីតិវិធី៖**

នីតិវិធីនៅក្នុងសំណុំរឿងនេះត្រូវបានធ្វើឡើងជា *'ករណីនៃការចូលបង្ហាញខ្លួនភ្លាមៗ'*។ យោងតាមមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ព្រះរាជអាជ្ញាអាចត្រឹមតែបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ប្រសិនបើបទល្មើសត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ *'មិនតិចជាង ១ ឆ្នាំ'* និង *'មិនលើសពី ៥ ឆ្នាំ'*។ ស្របពេលដែលលក្ខខណ្ឌនេះត្រូវបានបំពេញចំពោះបទល្មើសតាមមាត្រា ២៥៩ នៃច្បាប់ភូមិបាល ដែលត្រូវផ្តន្ទាទោសចន្លោះពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ លក្ខខណ្ឌដូចគ្នានេះមិនអាចអនុវត្តចំពោះបទល្មើសតាមមាត្រា៥០៤ នៃក្រមព្រហ្មទណ្ឌនោះឡើយ។ ស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈត្រូវផ្តន្ទាទោសអប្បបរមានៃទោសដាក់ពន្ធនាគាររយៈពេល ៦ ខែ ហើយអតិបរមានៃទោសមានរយៈពេល ១ ឆ្នាំ។ ហេតុដូច្នេះ ដោយសារតែបទល្មើសនេះត្រូវផ្តន្ទាទោសតិចជាង ១ ឆ្នាំ ជាការអាចត្រូវបានគេលើកឡើងថាជាការពុំស្របច្បាប់ចំពោះករណីនេះដែលត្រូវអនុវត្តនីតិវិធីនៃការចូលបង្ហាញខ្លួនភ្លាម។ ការស៊ើបសួរតាមផ្លូវច្បាប់ត្រឹមត្រូវមួយគួរតែត្រូវបានធ្វើឡើង ដែលជាការផ្តល់ឱកាសដល់ស្ត្រីទាំងនោះក្នុងការទទួលបានមេធាវីការពារ និងធ្វើការពិនិត្យ ព្រមទាំងតតាំងចំពោះភស្តុតាងប្រឆាំងនឹងខ្លួន។

**ការប្រព្រឹត្តទៅនៃសវនាការ៖**

បន្ទាប់ពីត្រូវបានស្ថិតនៅក្នុងការឃុំខ្លួនរបស់នគរបាលចាប់តាំងពីការចាប់ខ្លួនរបស់ពួកគេ កាលពីថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ ស្ត្រីទាំងនោះត្រូវបានបង្ហាញខ្លួននៅក្នុងតុលាការនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១២ ហើយសវនាការនោះបានប្រព្រឹត្តទៅនៅវេលាម៉ោង ១៣៖៣០នាទី។ នៅខណៈដែលចៅក្រមបានប្រាប់ដល់ពួកគេពីសិទ្ធិទទួលបានមេធាវី និងសិទ្ធិនៅស្ងៀម ចៅក្រមខកខានពុំបានផ្តល់នូវការពន្យល់ពីសិទ្ធិទាំងនោះទេ។ ស្ត្រីទាំង ១៣ រូប ត្រូវបានការពារជាដំបូងដោយមេធាវីពីររូប។ នៅពេលចាប់ផ្តើមនៃសវនាការ មេធាវីការពារក្តីខាងជនជាប់ចោទបានស្នើទៅចៅក្រមឲ្យលើកពេលសវនាការ ដើម្បីឲ្យខ្លួនមានពេលវេលាក្នុងការរៀបចំការពារដល់កូនក្តីរបស់ខ្លួន។ ចៅក្រមបានបដិសេធចំពោះសំណើនេះ ដោយខកខានមិនបានពន្យល់ពីហេតុផលលម្អិតចំពោះការបដិសេធរបស់ខ្លួននោះឡើយ។ មេធាវីបន្តស្នើសុំការអនុញ្ញាតដើម្បីហៅសាក្សីខាងចុងចោទបួនរូប ដោយធ្វើការពន្យល់ថា សាក្សីស្ថិតនៅខាងក្រៅតុលាការ ហើយនគរបាលបដិសេធមិនអនុញ្ញាតឲ្យពួកគេចូលក្នុងអាគារតុលាការនោះទេ។ ជាថ្មីម្តងទៀត ចៅក្រមបានបដិសេធនូវសំណើដែលលើកឡើងថា សាក្សីគួរត្រូវបានអនុញ្ញាតឲ្យបង្ហាញខ្លួននៅក្នុងតុលាការ។ នៅត្រង់ចំណុចនេះ មេធាវីការពារក្តី ហាក់ដូចជាពុំអាចការពារកូនក្តីរបស់ខ្លួន ហើយក៏បានដើរចេញ។ ចៅក្រមបានបន្តសវនាការនូវសំណុំរឿងនោះដោយពុំមានវត្តមានមេធាវីសម្រាប់ជនជាប់ចោទទាំង ១៣ រូបនោះ។ សវនាការបានប្រព្រឹត្តទៅក្នុងរយៈពេលប្រហែលជា៣ម៉ោង ដែលនៅក្នុងអំឡុងពេលនោះ តុលាការបានពិនិត្យភស្តុតាងមកពីខាងសាក្សីដាក់បន្ទុក ៣នាក់ និងបានមើលខ្សែអាត់វីដេអូនៃឧប្បទ្ទវហេតុនោះ។ ចៅ

ក្រុមចំណាយពេលអស់២៥នាទីសម្រាប់ធ្វើការពិភាក្សាសម្រេចក្នុងការកាត់ទោសជនជាប់ចោទទាំង១៣រូបនោះ មុននឹងសម្រេចដាក់ទោសពន្ធនាគារចាប់ពី ១ ឆ្នាំ ដល់ ២ ឆ្នាំកន្លះ។

នីតិវិធីនៃការជំនុំជម្រះលើស្ត្រីទាំងនោះត្រូវបានធ្វើឡើងជានីតិវិធីបង្ហាញខ្លួនភ្លាម គឺជាការពុំស្របច្បាប់នៅក្នុងកាលៈទេសៈនេះ ហើយបានធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេ។ ប្រាកដណាស់ថា ស្ត្រីទាំងនោះត្រូវបានបដិសេធសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានមួយចំនួនដូចជា សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន សិទ្ធិមានមេធាវី និងសិទ្ធិហៅរកសាក្សី ដែលជាលទ្ធផលទោសរបស់ពួកគាត់ត្រូវបានបន្ធូរបន្ថយនៅសាលាឧទ្ធរណ៍ និងត្រូវបានដោះលេងឲ្យមានសេរីភាព ទោះជាយ៉ាងណាក្តីក៏ការផ្តន្ទាទោសលើពួកគេនៅតែរក្សា។ ម្យ៉ាងវិញទៀត ហាក់ដូចជាពុំអាចទៅរួចសម្រាប់ចៅក្រមក្នុងការពិនិត្យនូវចំណុច និងធាតុផ្សំនៃបទចោទតាមផ្លូវច្បាប់នីមួយៗឲ្យបានលម្អិតគ្រប់គ្រាន់នៅក្នុងរយៈពេលតែបីម៉ោង។

នៅក្នុងដំណាក់កាលនៃសវនាការ ពុំមានទឡ្ហីករណ៍តាមផ្លូវច្បាប់ហ្មត់ចត់ត្រូវបានធ្វើឡើងឡើយ (ស្ត្រីទាំងនោះពុំមានមេធាវី) ពាក់ព័ន្ធនឹងធាតុផ្សំសំខាន់នៃបទល្មើស។ ឧទាហរណ៍ ខណៈពេលដែលមានចំនួនបាតុករជាច្រើនមានវត្តមានយ៉ាងច្បាស់នៅពេលធ្វើបាតុកម្ម ពួកគេពុំបង្ហាញខ្លួនដោយមានអាវុធនៅក្នុងដៃនៅក្នុងខ្សែអាត់វីដេអូនៅលើយូធ្យូបនោះទេហើយអាវុធទាំងនោះពុំត្រូវបានគេរកឃើញនោះឡើយ។

សិទ្ធិទទួលបានការបង្ហាញយ៉ាងពេញលេញសំដៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវឯកសារទាំងអស់ហើយត្រូវបានធ្វើឲ្យមានការដឹងឮនូវភស្តុតាងទាំងអស់ដែលពាក់ព័ន្ធទៅនឹងការជំនុំជម្រះ។ ចំណុចនេះត្រូវរាប់បញ្ចូលទាំងសំណុំរឿងដែលបានរៀបចំដោយចៅក្រមស៊ើបសួរ ដែលរក្សានូវការចោទប្រកាន់ ភស្តុតាងទាំងអស់ដែលប្រមូលបាន និងសេចក្តីសន្និដ្ឋាននានាដែលបានធ្វើឡើងដោយចៅក្រមស៊ើបសួរ។ ជនជាប់ចោទគួរតែទទួលបាននូវការបើកបង្ហាញរាល់ភស្តុតាងដទៃៗពាក់ព័ន្ធទៅនឹងសំណុំរឿងដែលអាចជួយដល់ភាគីជនជាប់ចោទ ឬ បន្ថយនូវការដាក់បន្ទុក។

### តួលេខទី២០៖ សិទ្ធិទទួលបានការបង្ហាញយ៉ាងពេញលេញក្នុងអំឡុងពេលរបាយការណ៍ទី៦

| តើមានអ្វីដែលបង្ហាញថា ភាគីណាមួយមិនត្រូវបានអនុញ្ញាតឲ្យមើលសំណុំរឿងក្តីរបស់ខ្លួនឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | ០ | ០ |
| គ្មាន | ១៨៣ | ១០០ | ១៣២ | ៩៤ | ៣០ | ១០០ |
| មិនពាក់ព័ន្ធ | ០ | ០ | ៩ | ៦ | ០ | ០ |

នៅគ្រាដែលមានចំណុចវិជ្ជមានជាខ្លាំង ដែលមន្ត្រីសង្កេតការណ៍សវនាការពុំបានអង្កេតឃើញមានករណីណាមួយ ដែលភាគីត្រូវបានរារាំងមិនឲ្យទទួលបាននូវសំណុំរឿងទេនោះ គួរធ្វើការកត់សម្គាល់ថា មានតែមេធាវីប៉ុណ្ណោះ ហើយមិនមែនជនជាប់ចោទខ្លួនឯងទេ ត្រូវបានផ្តល់សិទ្ធិក្នុងការទទួលបាននូវសំណុំរឿង

បាន។ ដូច្នេះ *អាច*មានករណីខ្លះ ដែលជនជាប់ចោទពុំមានមេធាវីពុំទទួលបាននូវការបង្ហាញពេញលេញនូវសំណុំរឿងរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ទិដ្ឋភាពនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រង់ផ្នែកនេះពុំមែនជាងាយស្រួលក្នុងការសង្កេតនោះទេ ដោយសារតែចរិតលក្ខណៈនៃទិដ្ឋភាពមួយនេះ។ ស្រដៀងគ្នានេះដែរពិតជាមិនអាចទៅរួចនោះឡើយចំពោះការសង្កេតលើករណីដែលមេធាវី និង/ឬ ជនជាប់ចោទមិនទទួលបានការបង្ហាញពេញលេញ ដោយហេតុថាព័ត៌មានដែលរក្សាទុកខ្លះនៅតែមិនត្រូវបានបង្ហាញឲ្យដឹង។

## សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ៖** *"ច្បាប់ការពារមិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ [...] ការចោទប្រកាន់ការចាប់ខ្លួនការឃាត់ខ្លួនឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ [...]។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ [...]។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"*
- **មាត្រា១៤(៣)(ឆ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួនជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ [...] មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។"*

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាពរួមបញ្ចូលការហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្មនិងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬដាក់ទណ្ឌកម្ម។ ចំណុចនេះគឺមានន័យថា ពុំការគាបសង្កត់ផ្លូវចិត្ត ឬផ្លូវកាយ ដោយផ្ទាល់ ឬដោយប្រយោលគួរតែប្រព្រឹត្តទៅលើជនជាប់ចោទដោយអាជ្ញាធរស៊ើបសង្កេត ឬតុលាការ ដើម្បីទទួលបានចម្លើយសារភាពពីពិរុទ្ធភាពឡើយ។

### តួលេខទី២១៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពក្នុងអំឡុងពេលរបាយការណ៍ទី៦

តើមានអ្វីមួយបង្ហាញថា ជនជាប់ចោទត្រូវបានគំរាមកំហែង ឬបង្ខំឲ្យសារភាពដែរឬទេ ក្នុងករណីដែលជនជាប់ចោទបានឆ្លើយសារភាពនៅមុនពេលសវនាការ?

| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ៣ | ០.៩ | ០ | ០ |
| គ្មាន | ៣៩១ | ១០០ | ៣២៨ | ៩៩.១ | ៩៧ | ១០០ |

| តើមានអ្វីមួយបង្ហាញថា ជនជាប់ចោទត្រូវបានគេធ្វើទារុណកម្ម ឬហិង្សាលើរូបកាយ បង្ខំឲ្យសារភាព ដែរ ឬទេក្នុងករណីដែលជនជាប់ចោទបានឆ្លើយសារភាពនៅមុនពេលសវនាការ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ១៣ | ៤ | ១១ | ៣ | ០ | ០ |
| គ្មាន | ៣២៨ | ៩៦ | ៣២០ | ៩៧ | ៤៧ | ១០០ |

នៅខណៈដែលមានតែចំនួននៃករណីតិចតួចប៉ុណ្ណោះ ដែលមានការបង្ហាញពីការបង្ខិតបង្ខំ ផ្លូវចិត្ត ឬផ្លូវកាយ តែនេះជាបញ្ហាគួរឲ្យបារម្ភដែលថាតុលាការត្រូវតែស៊ើបអង្កេតឲ្យបានហ្មត់ចត់។ ប្រសិនបើការអះអាងណាមួយពីប្រភេទនៃការបង្ខិតបង្ខំត្រូវបានបង្ហាញបន្ទាប់ពីការស៊ើបអង្កេត ដូច្នេះ ចៅក្រមត្រូវស្ថិតក្រោមកាតព្វកិច្ចផ្លូវច្បាប់ក្នុងការចាត់វិធានការលើភស្តុតាង ដែលមានការសារភាពជាបន្តបន្ទាប់ ដែលមិនត្រូវបានអនុញ្ញាត។ ខណៈដែលបញ្ហានេះគួរតែត្រូវបានដោះស្រាយក្នុងអំឡុងពេលនៃដំណាក់កាលនីតិវិធីស៊ើបអង្កេត ចៅក្រមជំនុំជម្រះត្រូវតែមានការប្រុងប្រយ័ត្នផងដែរ ហើយត្រូវធានាថាការអះអាងពីការបង្ខិតបង្ខំដែលមិនទាន់ត្រូវបានដោះស្រាយក្នុងអំឡុងពេលនៃដំណាក់កាលមុនការជំនុំជម្រះលើករណីនោះត្រូវស៊ើបអង្កេតយ៉ាងហ្មត់ចត់មុនពេលសវនាការត្រូវអនុញ្ញាតឲ្យបន្តទៅមុខទៀត។

តំណាងតុលាការខេត្តបន្ទាយមានជ័យបានពន្យល់ប្រាប់ថា ជនជាប់ចោទចំនួន ៨០% ផ្លាស់ប្តូរចម្លើយរបស់ខ្លួននៅពេលសវនាការជំនុំជម្រះ ដោយអះអាងថា នគរបាលបង្ខំយកចម្លើយសារភាពដោយប្រើទារុណកម្ម តែខកខានមិនបានបង្ហាញពីភស្តុតាងជាក់លាក់។ តំណាងតុលាការបានពន្យល់ទៀតថា យ៉ាងណាក៏ដោយ ចៅក្រមសម្រេចដាក់ទណ្ឌកម្មដោយមានស្ថានសម្រាល ប្រសិនជនជាប់ចោទសារភាព។[35] តំណាងតុលាការរាជធានីភ្នំពេញ បានលើកឡើងស្រដៀងគ្នាពីហេតុដែលជនជាប់ចោទខកខានពុំបានបង្ហាញភស្តុតាងនៃការធ្វើទារុណកម្ម ឬការគំរាមកំហែងថា ការសារភាពអាចត្រូវបានទទួលយកមកថ្លឹងថ្លែងដូចជាភស្តុតាងដែរ ហើយថានៅពេលជនជាប់ចោទអះអាងថា ខ្លួនត្រូវបានធ្វើទារុណកម្ម ចៅក្រមតែងតែកោះហៅមន្រ្តីនគរបាលយុត្តិធម៌ដែលពាក់ព័ន្ធមកសាកសួរ។[36]

[35] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

[36] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការរាជធានីភ្នំពេញ លោកចៅក្រម អឿង សៀង អនុប្រធានតុលាការ លោកចៅក្រម កោ វណ្ណី អនុប្រធានតុលាការ លោកព្រះរាជអាជ្ញារង សុខ រឿន លោកចៅក្រម សេង នាង លោកចៅក្រម អ៊ី ឋាវរៈ លោកស្រីចៅក្រម សែម សក្តិកូឡា និងលោកស្រីចៅក្រម ចាំង ស៊ីណាត នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

## ហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(៧) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"គ្មានជនណាម្នាក់ត្រូវជំនុំជម្រះ ឬដាក់ទោសម្តងទៀតចំពោះបទល្មើសដែលជននោះត្រូវបានផ្តន្ទាទោស ឬត្រូវបានលើកលែងពីបទចោទប្រកាន់ជាស្ថាពររួចហើយស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌនៃរដ្ឋនោះឡើយ។"*
- **មាត្រា២៣ នៃក្រមព្រហ្មទណ្ឌ៖** *"ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬ ក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល។"*
- **មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។"*

ការជំនុំជម្រះទ្វេដងចំពោះបទល្មើសដដែល ឬគោលការណ៍អាជ្ញាអស់ជំនុំ (ពោលគឺថា "បានវិនិច្ឆ័យរួចហើយ") សំដៅលើសិទ្ធិរបស់បុគ្គលដែលត្រូវបានការពារមិនឲ្យមានការជំនុំជម្រះលើសពីម្តងចំពោះអំពើ ឬបទល្មើសដដែល។ ករណីនេះកំណត់ថាសេចក្តីសម្រេចចុងក្រោយរបស់តុលាការ ទោះបីជាការលើកលែង ឬការផ្តន្ទាទោសជនជាប់ចោទក្តី នឹងក្លាយជារបាំងហាមមិនឲ្យមានការចោទប្រកាន់បន្ថែមថែមទៀតចំពោះអំពើល្មើសនោះ។ មានអត្ថប្រយោជន៍ជាច្រើនសម្រាប់ទាំងបុគ្គលជាជនជាប់ចោទ និងសង្គមជារួម ក្នុងការទទួលយកសេចក្តីសម្រេចចុងក្រោយនេះ រួមទាំងការបង្ការមិនឲ្យមានភាពខ្ជះខ្ជាយធនធានផ្នែកច្បាប់ នៅពេលដែលសេចក្តីសម្រេចត្រូវបានធ្វើរួចរាល់ហើយនោះ។

**តួលេខទី២២៖ ការហាមឃាត់ចំពោះកាវិនិច្ឆ័យទោសពីរដងក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទធ្លាប់ត្រូវបានជំនុំជម្រះរឿងក្តីដូចគ្នានេះពីមុនមកដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ១ | ០.៣ | ០ | ០ |
| គ្មាន | ៣៩១ | ១០០ | ៣៣០ | ៩៩,៧ | ៤៧ | ១០០ |

មានតែករណីតែមួយប៉ុណ្ណោះនៅតាមតុលាការខេត្តបន្ទាយមានជ័យ ដែលមានការបង្ហាញថា ជនជាប់ចោទត្រូវបានតុលាការកាត់ទោសម្តងរួចហើយចំពោះបទល្មើសដដែល។ ចំណុចនេះបង្ហាញថាពុំមានបញ្ហាធ្ងន់ធ្ងរ ដែលអាចមើលឃើញពាក់ព័ន្ធទៅនឹងការជំនុំជម្រះទ្វេដងនេះទេ។ ជាការសំខាន់ក្នុងការកត់សម្គាល់ដោយហេតុដែលថា មានការបង្ហាញមួយបានត្រូវលើកឡើងដោយភាគី ដែលថាជនជាប់ចោទត្រូវ

បានកាត់ទោសម្តងរួចហើយចំពោះបទល្មើសដដែលពុំបង្ហាញថា នេះគឺជាបញ្ហានោះទេ។ យ៉ាងណាក្តី ជាការចាំបាច់សម្រាប់តុលាការក្នុងការស៊ើបអង្កេតឲ្យបានពេញលេញចំពោះការបង្ហាញណាមួយក្នុងគោលបំណងដើម្បីធានាថាសិទ្ធិប្រឆាំងទៅនឹងការកាត់ទោសទ្វេរដង មិនត្រូវបានបំពានតាមមធ្យោបាយណាមួយនោះឡើយ។

**តួលេខ២៣៖ ទិដ្ឋភាពនៃនិន្នាការចំពោះការហាមឃាត់ការកាត់ទោសទ្វេរដង**

| តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទធ្លាប់ត្រូវបានជំនុំជម្រះរឿងក្តីដូចគ្នានេះពីមុនមកដែរឬទេ? | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងពេលរបាយការណ៍ ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ទី៦ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ទិន្នន័យនេះពុំបានប្រមូលក្នុងអំឡុងពេលរបាយការណ៍ទី១ និងទី២ទេ | | | | ១ | 0.១ | ១ | 0.២ | ១ | 0.១ | ១ | 0.១ |
| គ្មាន | | | | | ១០២៨ | ៩៩,៩ | ៦៨៧ | ៩៩,៨ | ៩១៥ | ៩៩,៩ | ៧១៨ | ៩៩,៩ |

ស្របពេលដែលនិន្នាការសរុបបង្ហាញពីការកើតឡើងឋិតថេរនៃចំនួនករណីដែលបង្ហាញថា ជនជាប់ចោទអាចបានត្រូវកាត់ទោសចំពោះបទល្មើសដដែលច្រើនជាងម្តង ទិន្នន័យសរុបពុំបង្ហាញពីបញ្ហាជាសំខាន់នៅក្នុងផ្នែកនេះទេ។

## ការហាមឃាត់ប្រឆាំងនឹងការអនុវត្តន៍អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

**ប្រភពច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ**

- **មាត្រា១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖** *"គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោស ដែលអនុវត្ត ក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើ ក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។ គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្តី និងការផ្តន្ទាទោសជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលអំពើ ឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ"។*
- **មាត្រា៣ នៃក្រមព្រហ្មទណ្ឌ៖** *"មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន"។*
- **មាត្រា១០ នៃក្រមព្រហ្មទណ្ឌ៖** *"បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាង ត្រូវអនុវត្តភ្លាម ។ ប៉ុន្តែ ការផ្តន្ទាទោសដែលជាស្ថាពរហើយនោះត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្ត តែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ។"*

គោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌ គឺថាពុំមានជនណាម្នាក់ត្រូវបានគេរកឃើញពីពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខាន ដែលមិនបានបង្កើតជាបទល្មើសព្រហ្មទណ្ឌនៅពេលដែលអំពើ ឬការខកខាននោះបានកើតឡើងឡើយ។ ស្រដៀងគ្នានេះ ទោសធ្ងន់ជាងមិនអាចអនុវត្តក្រៅតែពីទោសដែលត្រូវអនុវត្តនៅពេលដែលបទល្មើសព្រហ្មទណ្ឌនោះត្រូវបានប្រព្រឹត្តឡើយ។

**តួលេខ២៤៖ ការហាមឃាត់ការអនុវត្តន៍អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌអំឡុងពេលរបាយការណ៍ទី៦**

| តើទោសស្ថិតក្នុងចន្លោះនៃទណ្ឌកម្មដែលអនុវត្តនៅពេលបទល្មើសបានប្រព្រឹត្តដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៣៩២ | ៩៩,៧ | ៣៣០ | ៩៩.៧ | ៤៧ | ១០០ |
| គ្មាន | ១ | ០,៣ | ១ | ០,៣ | ០ | ០ |

មានករណីតែមួយប៉ុណ្ណោះក្នុងអំឡុងពេលរបាយការណ៍ទី៦នៅតុលាការខេត្តបន្ទាយមានជ័យ និងនៅតុលាការរាជធានីភ្នំពេញ ដែលបង្ហាញថា តុលាការបានដាក់ទោស ដែលពុំស្ថិតក្នុងកម្រិតទោសជាធរមាននៅពេលនៃការប្រព្រឹត្តបទល្មើស។ នៅក្នុងករណីកើតឡើងនៅតុលាការខេត្តបន្ទាយមានជ័យ កាលបរិច្ឆេទនៃបទល្មើសដែលបានចោទប្រកាន់គឺនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ ប៉ុន្តែជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទ *"រំលោភលើសេចក្តីទុកចិត្ត"* តាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ដែលមិនទាន់ចូលជាធរមានរហូតដល់ខែវិច្ឆិកា ឆ្នាំ២០១០។ ច្បាប់អ៊ុនតាក់ ដែលបានចូលជាធរមានមុនក្រមព្រហ្មទណ្ឌនេះ មិនមានចែងពីបទល្មើសស្រដៀងទៅនឹងបទល្មើស *"រំលោភលើសេចក្តីទុកចិត្ត"* នោះទេ។ ក្នុងករណីនេះ តុលាការបានសម្រេចអនុវត្តទោសស្រាលជាងដល់ជនជាប់ចោទ។ នៅក្នុងករណីមួយទៀតនៅតុលាការរាជធានីភ្នំពេញ បទល្មើសដែលចោទប្រកាន់ត្រូវបានប្រព្រឹត្តកាលពីឆ្នាំ២០០៩ និងឆ្នាំ២០១០ តែជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទ *"ឆបោក"* តាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងបទ *"រំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀត"* តាមមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ។ ក្នុងករណីនេះ តុលាការបានសម្រេចដាក់ទោសដែលធ្ងន់ជាងតាមក្រមព្រហ្មទណ្ឌ។

## សវនាការពាក់ព័ន្ធនឹងអនីតិជន

អនីតិជនទាំងឡាយដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ដែលអនុវត្តចំពោះនីតិជនដែរ ព្រមទាំងទទួលបានកិច្ចការពារបន្ថែមដោយសារការពិនិត្យមើលអាយុ ភាពចាស់ទុំ និងការវិវឌ្ឍន៍ផ្នែកសតិបញ្ញា។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក") ចែងពីបទប្បញ្ញត្តិជាក់លាក់មួយចំនួនសម្រាប់ការប្រព្រឹត្តចំពោះអនីតិជននៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងត្រូវបានគាំទ្រដោយវិធាន និងសេចក្តីណែនាំជា

អន្តរជាតិមួយចំនួនទៀត។ មាត្រា៣១ និងមាត្រា៤៨ នៃរដ្ឋធម្មនុញ្ញបានទទួលស្គាល់យ៉ាងច្បាស់នូវ អ.ស.ក និងធានាថារដ្ឋត្រូវការពារសិទ្ធិកុមារស្របពេល ដែលក្របខណ្ឌគតិយុត្តក៏បានបង្កើតបទប្បញ្ញត្តិសម្រាប់ការអនុវត្តន៍ដាច់ដោយឡែកចំពោះអនីតិជននៅក្នុងផ្នែកសំខាន់ៗមួយចំនួនផងដែរ។

**តួលេខទី២៥៖ សវនាការពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជនក្នុងអំឡុងពេលរបាយការណ៍ទី៦**

| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
|---|---|---|---|---|---|---|
| ចំនួនសវនាការ | ២៨ | | ១៤ | | ០ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| បទឧក្រិដ្ឋ | ១០ | ៣៦ | ៣ | ២១ | - | - |
| បទមជ្ឈិម | ១៨ | ៦៤ | ១១ | ៧៩ | - | - |

## អនីតិជន-ភាពឯកជន

**ប្រភពតាមច្បាប់ជាតិ និងអន្តរជាតិ៖**

- **មាត្រា ១៤(១)នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** *"សារព័ត៌មាន និងសាធារណជនអាចមិនឲ្យចូលរួមទាំងស្រុង ឬផ្នែកខ្លះនៃសវនាការ [...] នៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ [...] ប៉ុន្តែការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬបណ្តឹងតាមផ្លូវច្បាប់ត្រូវប្រកាសជាសាធារណៈលើកលែងតែផលប្រយោជន៍អនីតិជនតម្រូវផ្សេងពីនេះ ឬនីតិវិធីរឿងក្តីនៃទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។"*
- **មាត្រា ៤០(២)(ខ)(VII)នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖** *"រដ្ឋភាគីត្រូវធានា ជាពិសេសថា... [កុមារទទួល] បាននូវការគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារ នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។"*

ជាទូទៅ សវនាការព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងនីតិជនគួរតែធ្វើឡើងជាសាធារណៈដើម្បីអនុវត្តតាមសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ។ ក៏ប៉ុន្តែដរាបណាសវនាការពាក់ព័ន្ធនឹងអនីតិជនជាការស្របច្បាប់ក្នុងការដាក់កម្រិតចំពោះការចូលរួមស្តាប់សវនាការ និងដាក់កម្រិតលើការរាយការណ៍ ដើម្បីការពារភាពឯកជនរបស់អនីតិជន និងចៀសវាងទទួលការស្អប់ខ្ពើមពីសង្គម។

**តួលេខទី២៦៖ ភាពឯកជនក្នុងសវនាការរបស់អនីតិជនក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើការជូនដំណឹងអំពីសវនាការត្រូវបានបិទផ្សាយលើក្តារខៀនសាធារណៈដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៥ | ១៨ | ៤ | ២៩ | - | - |
| គ្មាន | ២៣ | ៨២ | ១០ | ៧១ | - | - |
| **តើសាធារណជនត្រូវបានរារាំង ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ?** | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | - | - |
| គ្មាន | ២៨ | ១០០ | ១៤ | ១០០ | - | - |
| **តើមានវិធានការការពារភាពឯកជនរបស់ជនជាប់ចោទជាអនីតិជននៅក្នុងសវនាការដែរឬទេ?** | | | | | | |
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | - | - |
| គ្មាន | ២៨ | ១០០ | ១៤ | ១០០ | - | - |

ពុំមានជនជាប់ចោទជាអនីតិជននោះទេនៅក្នុងសវនាការ ដែលត្រូវបានសង្កេតការណ៍នៅតុលាការខេត្តរតនគិរី។ ស្របពេលដែលមានការជូនដំណឹងតិចតួចពាក់ព័ន្ធសវនាការត្រូវបានបិទផ្សាយនោះ មានចំនួន ៥ ករណីនៅតុលាការរាជធានីភ្នំពេញ និង ៤ ករណីនៅតុលាការខេត្តបន្ទាយមានជ័យ ដែលតុលាការទាំងពីរនេះ បានអនុវត្តដោយពុំបានរឹតត្បិតចំពោះសាធារណជនចូលរួមក្នុងសវនាការពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជននោះទេ។ នៅគ្រាដែលជារឿងសំខាន់ដែលសាធារណជនអាចចូលទៅក្នុងបន្ទប់តុលាការចំពោះសវនាការលើនីតិជន សវនាការពាក់ព័ន្ធនឹងអនីតិជន គួរតែត្រូវបានធ្វើឡើងដោយរបៀបផ្សេងពីនេះ។ ការចូលរួមស្តាប់របស់សាធារណជនក្នុងសវនាការលើអនីតិជនគួរតែត្រូវបានរឹតត្បិត ដើម្បីការពារភាពឯកជនរបស់អនីតិជន ឧទាហរណ៍ តាមរយៈការចាត់ចែងបន្ទប់សវនាការដាច់ដោយឡែកមួយសម្រាប់សំណុំរឿងអនីតិជន។ ប្រសិនបើពុំអាចធ្វើដូច្នោះបានទេនោះ សាធារណជនមួយចំនួន (ក្រៅពីឪពុកម្តាយ ឬអាណាព្យា

បាលស្របច្បាប់របស់អនីតិជន) មិនគួរត្រូវអនុញ្ញាតឲ្យចូលរួមសវនាការលើអនីតិជននោះឡើយ។ ឈ្មោះ របស់ ឬអត្តសញ្ញាណលម្អិតដទៃទៀតរបស់ជនជាប់ចោទជាអនីតិជន មិនត្រូវបង្ហាញនៅលើក្តារខៀនជូនដំណឹងជាសាធារណៈនោះឡើយ។ សិទ្ធិឯកជនរបស់អនីតិជនអាចត្រូវបានការពារបន្ថែមតាមរយៈការប្រើប្រាស់ឧបករណ៍មានដូចជា ប្រព័ន្ធបង្ហាញការឆ្លងឆ្លើយតាមវីដេអូ ដែលត្រូវបានតំឡើងនៅតាមបន្ទប់សវនាការរបស់តុលាការខ្លះរួចទៅហើយ។ ការអនុវត្តន៍បែបនេះ អាចធ្វើទៅស្របតាមបទដ្ឋានអន្តរជាតិ ដែលធានាដោយ អ.ស.ក។[37]

នៅខណៈដែលតំណាងតុលាការខេត្តបន្ទាយមានជ័យបានបញ្ជាក់ថា ចៅក្រមសម្រេចរក្សាភាពឯកជនរបស់ជនជាប់ចោទជាអនីតិជន ឬ បទល្មើសជាក់លាក់ដូចជា បទរំលោភសេពសន្ថវៈ[38] តំណាងតុលាការរាជធានីភ្នំពេញបានលើកឡើងថា ពុំមានបទប្បញ្ញត្តិជាក់លាក់តម្រូវឲ្យតុលាការបើកសវនាការជាសម្ងាត់នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជននោះទេ។[39]

## អនីតិជន–ការឃុំខ្លួនបណ្តោះអាសន្ន

**ប្រភពនៅក្នុងច្បាប់នៅកម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ។"*
- **មាត្រា២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"អនីតិជនអាយុតិចជាង ១៤ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជនឲ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។"*
- **មាត្រា២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ចំពោះអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋចិរវេលាឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ៖*
  1. *ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ខែបានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦ឆ្នាំ។*
  2. *ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ខែបានទេ កាលណាអនីតិជនមានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។*
- **មាត្រា២១៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"ចំពោះអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំដល់ក្រោម ១៨ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ៖*

[37] មាត្រា៤០(២)(ខ) (vii) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក")។

[38] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

[39] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការរាជធានីភ្នំពេញ លោកចៅក្រម អៀង សៀង អនុប្រធានតុលាការ លោកចៅក្រម កោ វណ្ណី អនុប្រធានតុលាការ លោកព្រះរាជអាជ្ញារង សុខ រឿន លោកចៅក្រម សេង នាង លោកចៅក្រម អ៊ី ឋាវរៈ លោកស្រីចៅក្រម សែម សក្តិកូឡា និងលោកស្រីចៅក្រម ចាំង ស៊ីណាត នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

*១. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២ខែបានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ឆ្នាំ។*

*២. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ខែបានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ ដល់ក្រោម១៨ឆ្នាំ។*

*ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នតាមចំណុចទី១ និងចំណុចទី២ខាងលើនេះ មិនត្រូវលើសពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។"*

ទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន បទដ្ឋានអន្តរជាតិមិនជំរុញឲ្យមានការអនុវត្តន៍ការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជនឡើយ សូម្បីការឃុំខ្លួនបណ្តោះអាសន្ននេះពាក់ព័ន្ធនឹងជនជាប់ចោទជានីតិជនក៏ដោយ។ ក្នុងករណីភាគច្រើន ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារត្រូវបានការពារ ដោយមិនត្រូវបំបែកពួកគេឲ្យនៅឆ្ងាយពីឪពុកម្តាយគេឡើយ។[40] ការឃុំខ្លួនកុមាររួមទាំងបន្ទាប់ពីការចាប់ខ្លួន និងមុនពេលសវនាការគួរតែត្រូវចៀសវាងតាមដែលអាចធ្វើទៅបាន និងគួរតែត្រូវប្រើជាវិធានការចុងក្រោយបង្អស់ក្នុងរយៈពេលមួយខ្លីសមល្មម។[41] ទាំងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិចែងយ៉ាងជាក់លាក់ថាក្នុងករណីពិសេសដែលអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន នីតិជននោះគួរតែត្រូវបានដាក់ដាច់ដោយឡែកពីនីតិជន។[42]

**តួលេខទី២៧៖ ការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជនក្នុងអំឡុងពេលរបាយការណ៍ទី៦**

| តើមានការឃុំខ្លួនបណ្តោះអាសន្នដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ៣៥ | ៩២ | ១៩ | ៩០ | - | - |
| គ្មាន | ៣ | ៨ | ២ | ១០ | - | - |
| មិនពាក់ព័ន្ធ | ០ | ០ | ០ | ០ | - | - |

[40] មាត្រា៩នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[41] មាត្រា៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។មាត្រា៩៦និងមាត្រា២១២នៃក្រមនីតិវិធីព្រហ្មទណ្ឌ។មាត្រា២១២ នៃនីតិវិធីក្រមព្រហ្មទណ្ឌហាមឃាត់ការឃុំខ្លួនអនីតិជនអាយុក្រោម១៤ឆ្នាំដោយមាត្រា២១៣និងមាត្រា២១៤កំណត់ថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់អនីតិជនអាយុពី១៤ឆ្នាំ ទៅ១៨ឆ្នាំដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម។

[42] មាត្រា១៦៦នៃក្រមព្រហ្មទណ្ឌចែងអំពីលក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារៈ*"អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេសខណ្ឌដាច់ពីនីតិជន។"* សូមអានផងដែរមាត្រា៣៧(គ)នៃអនុសញ្ញាស្តីពីសិទ្ធិកុមារនិងវិធាន ១៣.៤នៃវិធានអប្បរមានៃការគ្រប់គ្រងយុត្តិធមិសម្រាប់កុមារនៃអង្គការសហប្រជាជាតិ (វិធានទីក្រុងប៉េកាំង)ដែលបានអនុម័តដោយសេចក្តីសម្រេចមហាសន្និបាតលេខ ៤០/៣៣ចុះថ្ងៃទី២៩ខែវិច្ឆិកាឆ្នាំ១៩៨៥។

| តើមានអ្វីមួយបញ្ជាក់ថា ជនជាប់ចោទមិនត្រូវឃុំដាច់ដោយឡែកពីនីតិជនដែរឬទេ ប្រសិនបើមានការឃុំខ្លួនបណ្ដោះអាសន្ន? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ២ | ១០,៥ | - | - |
| គ្មាន | ៣៣ | ៨៧ | ១៧ | ៧៩ | - | - |
| មិនពាក់ព័ន្ធ | ៥ | ១ | ២ | ១០,៥ | - | - |

មានការគួរឲ្យខកចិត្តជាខ្លាំងដោយឃើញថា អត្រាជាទូទៅនៃការឃុំខ្លួនបណ្ដោះអាសន្ននៅតែមានកម្រិតខ្ពស់។ ការបន្តប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីជាច្រើន គឺជាការព្រួយបារម្ភជាខ្លាំងនៅពេលដែលការឃុំខ្លួននេះអនុវត្តលើជនជាប់ចោទជាអនីតិជន។ ការឃុំឃាំងអនីតិជន ជាពិសេសអនីតិជនដែលមិនទាន់ផ្តន្ទាទោស ត្រូវតែប្រើប្រាស់ជាវិធានការចុងក្រោយបង្អស់តែប៉ុណ្ណោះ។ ដោយហេតុដែលថា តុលាការរាជធានីភ្នំពេញ និងតុលាការខេត្តបន្ទាយមានជ័យដែលបានអនុវត្តការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីភាគច្រើនបំផុតនៃជនជាប់ចោទជាអនីតិជន ការធ្វើបែបនេះបង្ហាញពីការប៉ះពាល់ជាខ្លាំងដល់សច្ចធារណ៍នៃនិរទោស និងសិទ្ធិមានសេរីភាព។ ដោយហេតុថា មានករណីចំនួន ២ នៅតុលាការខេត្តបន្ទាយមានជ័យ ដែលមានការបង្ហាញថា ជនជាប់ចោទជាអនីតិជនមិនត្រូវបានបំបែកចេញពីនីតិជនគឺជាក្តីបារម្ភយ៉ាងខ្លាំង។ អនីតិជនងាយនឹងទទួលនូវឥទ្ធិពលអវិជ្ជមានជាខ្លាំង ដោយសារតែភាពក្មេងខ្ចីផ្នែកបញ្ញាស្មារតី និងចិត្តគំនិតរបស់ពួកគេ។ អនីតិជនមិនត្រូវដាក់ក្នុងពន្ធនាគារជាមួយនឹងជនល្មើសដែលមានវ័យចាស់ជាង ដែលមានបទពិសោធន៍ជាង និងដែលឆ្លាតវាងវៃជាងនោះទេ។

## អនីតិជន៖ ការផ្តន្ទាទោស

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ**

- **មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ៖** *"អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤(ដប់បួន) ឆ្នាំ ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។"*
- **មាត្រា៤០ នៃក្រមព្រហ្មទណ្ឌ៖** *"វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ មានដូចតទៅ៖*
  *១. ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងមានទំនុកចិត្ត។*
  *២. ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។*
  *៣. ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។*

*៤. ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។*

*៥. ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។"*

- **មាត្រា៤០ (៤) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖** *"ក្រៅពីការរក្សានៅក្នុងមន្ទីរអប់រំ មានបញ្ញត្តិគ្រប់គ្រងជាច្រើនទៀត ដូចជាការថែទាំ ការតម្រែតម្រង់ និងការពិនិត្យគ្រប់គ្រង ការផ្តល់មតិទូន្មាន ការសាកល្បង ការដាក់ឲ្យរស់នៅតាមគ្រួសារ កម្មវិធីអប់រំទូទៅ និងអប់រំវិជ្ជាជីវៈ ព្រមទាំងដំណោះស្រាយផ្សេងទៀតដែលអាចប្រើប្រាស់បាន ដើម្បីធានាថាកុមារត្រូវបានទទួលការថែទាំមួយសមស្របជាមួយនឹងផាសុខភាពរបស់ខ្លួន ហើយដែលស៊ីកម្រិតគ្នានឹងស្ថានភាពរបស់កុមារផង និងទម្ងន់នៃបទល្មើសនោះផង។"*

នៅពេលដែលបង្គាប់ ឬសម្រេចដាក់ទោសលើអនីតិជន ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសបំពាននឹងច្បាប់ព្រហ្មទណ្ឌ ចៅក្រមត្រូវពិចារណាទៅលើឧត្តមប្រយោជន៍របស់កុមារជាអាទិភាព។[43] ការអនុវត្តន៍ទោសពន្ធនាគារលើអនីតិជនត្រូវតែធ្វើការពិចារណាជាវិធានការចុងក្រោយបង្អស់ដែលត្រូវអនុវត្តតែក្នុងករណីពិសេសប៉ុណ្ណោះ។[44]

### តួលេខ២៨៖ ការផ្តន្ទាទោសអនីតិជនក្នុងអំឡុងពេលរបាយការណ៍ទី៦

តើមានអ្វីមួយដែលបង្ហាញថា ចៅក្រមពិចារណាទៅលើទោសមិនមែនពន្ធនាគារ មុននឹងអនុវត្តទោសពន្ធនា-គារដែរឬទេ?

| ទិន្នន័យ | តុលាការរាជធានីភ្នំពេញ | | តុលាការខេត្តបន្ទាយមានជ័យ | | តុលាការខេត្តរតនគិរី | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ១ | ៥ | - | - |
| គ្មាន | ៣០ | ១០០ | ១៩ | ៩៥ | - | - |

មានករណីតែមួយប៉ុណ្ណោះ ដែលចៅក្រមបានធ្វើការពិចារណាអនុវត្តទោសក្រៅពីទោសពន្ធនាគារទៅលើជនជាប់ចោទជាអនីតិជនម្នាក់។ ក្នុងករណីនោះ អនីតិជនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ៣ ឆ្នាំ និង ៦ ខែ ប៉ុន្តែ ចៅក្រមបានដាក់ទោសក្នុងពន្ធនាគារចំនួន ៦ ខែ ហើយអនុវត្តទោសសាកល្បងចំនួន ៣ ឆ្នាំ។ ជាសរុបទៅ នៅគ្រប់ករណីទាំងអស់ដែលបានសង្កេតការណ៍ក្នុងអំឡុងពេលរបាយការណ៍ទី៦នេះ នៅពេលដែលជនជាប់ចោទជាអនីតិជនត្រូវបានផ្តន្ទាទោស ទោសពន្ធនាគារត្រូវបានអនុវត្តភ្លាមៗ។ តួលេខទាំងនេះគឺជាក្តីបារម្ភជាខ្លាំង និងជាករណីប្លែកទៅនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលចែងថាការឃុំខ្លួនទៅលើជនល្មើសជាអនីតិជន ត្រូវអនុវត្តតែក្នុងវិធានការចុងក្រោយប៉ុណ្ណោះ។ ជាការគួរឲ្យបារម្ភដែលថា តុលាការពុំបានប្រើប្រាស់ជម្រើសផ្សេងទៀតនៃការផ្តន្ទាទោស ដែលអាចអនុវត្តបានចំពោះជនជាប់ចោទជាអនីតិជន។

---

[43] មាត្រា២(១)នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។សូមមើលផងដែរគណៈកម្មាធិការសិទ្ធិកុមារ- កថាខណ្ឌទី១០និងទី៧១ នៃ *បទអត្ថាធិប្បាយទូទៅលេខ១០៖ សិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន។*

[44] មានត្រា៣៧(ខ)នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

តំណាងតុលាការខេត្តបន្ទាយមានជ័យបានពន្យល់ប្រាប់ថា តុលាការមានបំណងក្នុងការអនុវត្តន៍ទោសមិនជាប់ពន្ធនាគារលើជនជាប់ចោទជាអនីតិជន ប៉ុន្តែមានបញ្ហាប្រឈមក្នុងការអនុវត្តន៍បែបនេះ ដោយសារតែកង្វះវិធានការតាមដាន។[45] ដោយឡែកតំណាងតុលាការរាជធានីភ្នំពេញបានបញ្ជាក់ពីគោលជំហររបស់ខ្លួនថា ចៅក្រមតែងតែពិចារណាពីស្ថានសម្រាលជានិច្ច នៅពេលសម្រេចដាក់ទោសលើជនជាប់ចោទជាអនីតិជន ដោយអនុលោមតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។[46]

**តួលេខ២៩៖ ទិដ្ឋភាពនៃការផ្តន្ទាទោសអនីតិជន**

ក្នុងចំណោមជនជាប់ចោទជាអនីតិជនដែលត្រូវផ្តន្ទាទោសបន្ទាប់ពីសវនាការ តើមានអ្វីមួយដែលបង្ហាញថា ចៅក្រមបានពិចារណាលើការអនុវត្តន៍ទោសមិនមែនពន្ធនាគារមុននឹងគិតដល់ទោសពន្ធនាគារដែរឬទេ?

| ទិន្នន័យ | អំឡុងពេលរបាយការណ៍ទី១ | | អំឡុងពេលរបាយការណ៍ទី២ | | អំឡុងពេលរបាយការណ៍ទី៣ | | អំឡុងពេលរបាយការណ៍ទី៤ | | អំឡុងពេលរបាយការណ៍ទី៥ | | អំឡុងពេលរបាយការណ៍ ទី៦ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ២ |
| គ្មាន | ២០ | ១០០ | ៤៦ | ១០០ | ៣២ | ១០០ | ១៥ | ១០០ | ៣៦ | ១០០ | ៤៩ | ៩៨ |

ករណីនៅតុលាការខេត្តបន្ទាយមានជ័យនៅក្នុងអំឡុងពេលរបាយការណ៍ទី៦ បង្ហាញថាមានតែករណីពាក់ព័ន្ធនឹងអនីតិជនមួយប៉ុណ្ណោះក្នុងចំណោមសវនាការនានា ដែលបានសង្កេតចាប់តាំងពីការចាប់ផ្តើមនៃអំឡុងពេលរបាយការណ៍ទី១ ដែលនៅពេលនោះ ចៅក្រមមួយរូបបានពិចារណាអនុគ្គទោសមិនមែនពន្ធនាគារ។ នៅគ្រប់ករណីទាំងអស់ដែលបានសង្កេតដោយ ម.ស.ម.ក ជនជាប់ចោទជាអនីតិជនដែលត្រូវបានផ្តន្ទាទោសពីបទល្មើសត្រូវបានបញ្ជូនទៅពន្ធនាគារ។ លទ្ធផលទាំងនេះជាការគួរឲ្យភ្ញាក់ផ្អើល និងជាការចង្អុលបង្ហាញឲ្យឃើញពីភាពចាំបាច់សម្រាប់កំណែទម្រង់ជាបន្ទាន់ ចំពោះការអនុវត្តន៍លើការផ្តន្ទាទោសទាក់ទិននឹងអនីតិជន។

[45] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការខេត្តបន្ទាយមានជ័យ លោកចៅក្រម អ៊ឹម វណ្ណៈ និងលោកចៅក្រម ធាម ច័ន្ទពិសិដ្ឋ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

[46] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងតុលាការរាជធានីភ្នំពេញ លោកចៅក្រម អឿង សៀង អនុប្រធានតុលាការ លោកចៅក្រម កោវណ្ណី អនុប្រធានតុលាការ លោកព្រះរាជអាជ្ញារង សុខ រឿន លោកចៅក្រម សេង នាង លោកចៅក្រម អ៊ី ឋាវរៈ លោកស្រីចៅក្រម សែម សក្តិកូឡា និងលោកស្រីចៅក្រម ចាំង ស៊ីណាត នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

## ៤. សេចក្ដីសន្និដ្ឋាន និង អនុសាសន៍

ទិន្នន័យប្រមូលបានក្នុងអំឡុងពេលរបាយការណ៍ទី៦ គូសបញ្ជាក់អំពីភាពចាំបាច់សម្រាប់ធ្វើកំណែទម្រង់នៅក្នុងផ្នែកមួយចំនួន។ ខណៈពេលដែលតុលាការដែលបានសង្កេតការណ៍ជាទូទៅប្រកាន់ខ្ជាប់នីតិវិធីដែលសំដៅលើការធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការព្រួយបារម្ភកើតមាននៅលើបញ្ហាចម្បងៗជាច្រើនទៀត។ បញ្ហាសំខាន់បំផុតដែលត្រូវដោះស្រាយជាបញ្ហាអាទិភាពនោះរួមមាន កម្រិតខ្ពស់នៃការឃុំខ្លួនបណ្ដោះអាសន្ននៅតែបន្តមាន ការខកខានរបស់ចៅក្រមក្នុងការពន្យល់ប្រាប់សិទ្ធិរបស់ជនជាប់ចោទ និងសិទ្ធិមានមេធាវីនៅមានកម្រិតទាប។ បន្ថែមលើចំណុចគួរឲ្យព្រួយបារម្ភទាំងនេះ បញ្ហាសំខាន់ជាងនេះទៀតគឺយុត្តិធម៌ និងការអនុវត្តន៍ការផ្ដន្ទាទោសអនីតិជនត្រូវធ្វើការដោះស្រាយ។

ជាការឆ្លើយតបទៅនឹងកង្វះខាតទាំងឡាយ ដែលទិន្នន័យប្រមូលបានក្នុងអំឡុងពេលរបាយការណ៍ទី៦ បានលើកឡើងនោះ អនុសាសន៍របស់ ម.ស.ម.ក ត្រូវបានដាក់ចេញដូចខាងក្រោម។

### អនុសាសន៍ទាក់ទងទៅនឹងសិទ្ធិមានសេរីភាព និង សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលៈ

ច្បាប់ថ្មីគួរតែត្រូវបានព្រាងឡើងពាក់ព័ន្ធទៅនឹងការអនុវត្តន៍វិធានការឃុំខ្លួនបណ្ដោះអាសន្ន ការស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងកាតព្វកិច្ចរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការនៅតុលាការ។ ច្បាប់ស្ដីការធានានៅក្រៅឃុំ ការស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្ដោះអាសន្ននេះ គួរតែៈ

- ចែងពីលក្ខខណ្ឌឲ្យបានពិស្ដារចំពោះការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្ដោះអាសន្ន។ ចៅក្រមគួរតែត្រូវតម្រូវឲ្យផ្ដល់ទាំងសម្អាងហេតុ និងមូលដ្ឋានក្នុងការដកហូត ឬការរឹតត្បិតសេរីភាពរបស់ជនជាប់ចោទ។
- កាលបរិច្ឆេទដែលបានចាប់ផ្ដើមការឃុំខ្លួនបណ្ដោះអាសន្ន និងកាលបរិច្ឆេទនៃដីកាដំណោះស្រាយដែលបានចេញ គួរតែត្រូវបានប្រកាសក្នុងតុលាការជាសាធារណៈនៅពេលចាប់ផ្ដើមនៃសវនាការនីមួយៗ ដើម្បីឲ្យករណីណាដែលមានការឃុំខ្លួនបណ្ដោះអាសន្នហួស អាចត្រូវបានគណនាយ៉ាងត្រឹមត្រូវ។
- ផ្ដល់ជម្រើសជាក់លាក់ក្នុងការអនុញ្ញាតឲ្យស្ថិតនៅក្រៅឃុំដោយពុំមានលក្ខខណ្ឌ។
- បង្កើតឲ្យមានសិទ្ធិស្វ័យប្រវត្តិមួយសម្រាប់ការនៅក្រៅឃុំ/ការស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះបទល្មើសស្រាលៗ (ឧទាហរណ៍ បទល្មើសដែលអនុវត្តទោសពន្ធនាគារតិចជាង ៦ ខែ) ដែលជាការអនុគ្រោះចំពោះកាលៈទេសៈពិសេស។ 'កាលៈទេសៈពិសេស' គួរតែមានកំណត់ក្នុងច្បាប់ ហើយជាឧទាហរណ៍ គួរតែរាប់បញ្ចូលនូវការគន់គូរដែលជនជាប់ចោទបានខកខានម្ដងហើយម្ដងទៀតក្នុងការគោរពតាមលក្ខខណ្ឌនៃការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។
- ដាក់ទណ្ឌកម្មលើជនជាប់ចោទដែលខកខានមិនបានចូលរួមសវនាការ ដែលបង្កើតឲ្យមានជាបទល្មើសព្រហ្មទណ្ឌចំពោះការខកខានមិនចូលក្នុងតុលាការ ដោយពុំមានហេតុផលត្រឹមត្រូវ។ បទល្មើសនេះជាការលើកទឹកចិត្តដល់ជនជាប់ចោទឲ្យចូលរួមក្នុងសវនាការដូចដែលតម្រូវ ព្រមទាំង

ផ្តល់នូវការធានាមួយសម្រាប់ចៅក្រម ដែលថានឹងមានផលវិបាកដល់ជនជាប់ចោទដែលខកខានមិនបានគោរពតាមការបង្គាប់របស់តុលាការ ដោយហេតុនេះ ត្រូវលុបចោលនូវការអនុវត្តន៍នាពេលបច្ចុប្បន្នលើដាក់ឲ្យមានការឃុំខ្លួនបណ្តោះអាសន្នដែលបញ្ចូលគ្រប់រឿង ដោយសារតែការសង្ស័យដែលថាជនជាប់ចោទនឹងខកខានមិនចូលរួមសវនាការ។

ដើម្បីពង្រឹងនូវច្បាប់ដែលត្រូវស្នើឡើង ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃនិងក្រសួងសង្គមកិច្ចគួរធានាថាមានប្រព័ន្ធប្រាកដប្រជាមួយសម្រាប់គាំទ្រចំពោះការឃ្លាំមើល និងអនុវត្តលក្ខខណ្ឌនៃការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ រាជរដ្ឋាភិបាលត្រូវតែធានាថា មានធនធានគ្រប់គ្រាន់ដែលអាចប្រើប្រាស់បានសម្រាប់គាំទ្រនូវផែនការទាំងនេះ ដែលអាចធ្វើការអនុវត្តន៍សាកល្បងដំបូងនៅតំបន់ភូមិសាស្រ្តណាមួយ។

## អនុសាសន៍ពាក់ព័ន្ធនឹងការពន្យល់ប្រាប់ពីសិទ្ធិ

ទម្រង់បទដ្ឋានជាគំរូមួយគួរតែត្រូវព្រាងឡើង និងដាក់ឲ្យអនុវត្តសម្រាប់ជាការប្រើប្រាស់នៅតាមតុលាការទាំងអស់។ ទម្រង់នោះគួរតែត្រូវបានអានដោយក្រឡាបញ្ជី ហើយគួរតែកំណត់ព័ត៌មានដូចខាងក្រោម៖

- បទល្មើសនានា ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ និងច្បាប់ដែលពាក់ព័ន្ធ
- កាលបរិច្ឆេទ ពេលវេលា ទីកន្លែងនៃបទល្មើសដែលបានចោទប្រកាន់ និងភាគីដែលពាក់ព័ន្ធនានា និង
- សិទ្ធិទទួលបានការជំនុំជម្រះរបស់ជនជាប់ចោទ ស្របតាមបទដ្ឋាន និងការពន្យល់ឲ្យបានច្បាស់លាស់លើសិទ្ធិទាំងនោះ។

ការខកខានមិនបានអាននូវព័ត៌មានខាងលើនៅពេលចាប់ផ្តើមនៃសវនាការគួរបង្កើតជាមូលហេតុនៃការប្តឹងឧបាស្រ័យ។

គ្រប់តុលាការទាំងអស់គួរដាក់បង្ហាញនូវប័ណ្ណប្រកាសមួយនៅក្នុងបន្ទប់រង់ចាំនីមួយៗ ដែលបង្ហាញឲ្យច្បាស់ទៅកាន់ជនជាប់ចោទ ដោយមានចែងពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេ។

## អនុសាសន៍ពាក់ព័ន្ធនឹងសិទ្ធិមានមេធាវី

ម.ស.ម.ក ទទួលស្គាល់នូវផលលំបាក និងឧបសគ្គផ្នែកហិរញ្ញវត្ថុ ដែលប៉ះពាល់ដល់បទប្បញ្ញត្តិនៃការផ្តល់ជំនួយផ្លូវច្បាប់របស់មេធាវី។ ដើម្បីដោះស្រាយនូវផលលំបាកនេះ **គណៈមេធាវីកម្ពុជា** គួរអនុវត្តនូវផែនការ ដែលមេធាវីថ្មីៗត្រូវចាត់តាំងឲ្យជួយមេធាវីដែលមានបទពិសោធន៍ច្រើន ដែលកំពុងការពារក្តីឲ្យជនជាប់ចោទនៅលើមូលដ្ឋាននៃការផ្តល់ជំនួយផ្នែកច្បាប់។ គម្រោងការនេះគួរបង្កើតជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ផ្នែកវិជ្ជាជីវៈជាបន្តបន្ទាប់ឲ្យបានទូលំទូលាយ និងបង្កើតជាផ្នែកមួយនៃវគ្គបណ្តុះបណ្តាលផ្លូវការដល់មេធាវីថ្មីៗ។ មេធាវីថ្មីៗគួរតែត្រូវទទួលខុសត្រូវសម្រាប់ការសិក្សាស្រាវជ្រាវ និងការរៀបចំសំណុំរឿង ដែលជាការដកបន្ទុកមួយចំនួនពីមេធាវីដែលមានបទពិសោធន៍ច្រើន ដែលបន្ទាប់មកនឹងមានតួនាទីក្នុងការការពារជនជាប់ចោទជាច្រើននាក់។

រាជរដ្ឋាភិបាលត្រូវទទួលស្គាល់នូវបទប្បញ្ញត្តិនៃជំនួយផ្នែកច្បាប់ថាជាបញ្ហាអាទិភាព ហើយត្រូវលៃលកមូលនិធិឲ្យស្របទៅតាមនោះដែរ។

ដើម្បីបង្កើនការយល់ដឹងជាសាធារណៈពីសិទ្ធិមានមេធាវី អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ជំនួយផ្នែកច្បាប់គួរតែធ្វើការរួមគ្នាជាមួយនឹង រាជរដ្ឋាភិបាលដើម្បីចែកចាយនូវព័ត៌មាននៅថ្នាក់ឃុំ/សង្កាត់។

ជនជាប់ចោទគួរតែមានសិទ្ធិនិយាយទៅកាន់មេធាវីនៅពន្ធនាគារ ឬតាមទូរសព្ទក្នុងអំឡុងពេលការសាកសួររបស់នគរបាល ហើយគួរតែមានសិទ្ធិមានមេធាវីក្នុងពេលសាកសួរ។ នគរបាលមិនគួរត្រូវបានអនុញ្ញាតឲ្យហាមជនសង្ស័យក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃនោះទេ។ ការអនុវត្តន៍ទាំងនេះគួរត្រូវបានឆ្លុះបញ្ចាំងតាមរយៈការធ្វើវិសោធនកម្មជាចាំបាច់មួយចំនួនលើក្រមនីតិវិធីព្រហ្មទណ្ឌ។

## អនុសាសន៍ពាក់ព័ន្ធនឹងភាពឥតលម្អៀង និង វិជ្ជាជីវៈរបស់ចៅក្រម

ក្រសួងយុត្តិធម៌ និងគណៈមេធាវីកម្ពុជា គួរតែធ្វើការរួមគ្នាដើម្បីពិនិត្យមើលឡើងវិញនូវក្រមសីលធម៌របស់ចៅក្រម និងគួរធ្វើវិសោធនកម្មចាំបាច់មួយចំនួន។ វិសោធនកម្មគួរបញ្ចូលនូវការហាមឃាត់ទាំងស្រុងលើការប្រើប្រាស់ទូរសព្ទដៃ ខណៈដែលដំណើរការសវនាការកំពុងតែប្រព្រឹត្តទៅ និងបញ្ចូលនូវកាតព្វកិច្ចដល់ចៅក្រមក្នុងការពិភាក្សាទាំងអស់ជាលក្ខណៈដាច់ដោយឡែក។

## អនុសាសន៍ចំពោះសវនាការពាក់ព័ន្ធនឹងអនីតិជន

រាជរដ្ឋាភិបាលត្រូវធានាថាសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌កុមារត្រូវបានអនុម័តជាបញ្ហាអាទិភាព។ ច្បាប់នេះត្រូវដាក់បញ្ចូលនូវសេចក្តីណែនាំដ៏ត្រឹមត្រូវស្តីពីការអនុវត្តន៍ការឃុំខ្លួនបណ្តោះអាសន្ន ហើយគួរតែគាំទ្រឲ្យមានការអនុវត្តន៍វិធានការផ្សេងទៀតក្រៅពីការផ្តន្ទាទោសពន្ធនាគារដែលផ្តោតលើវិធានការអប់រំ ការធ្វើសមាហរណកម្ម និងការកែប្រែនីតិសម្បទា។

មុននឹងដឹកនាំ/ចូលរួមជាតំណាងអយ្យការលើករណីដែលពាក់ព័ន្ធជនជាប់ចោទជាអនីតិជន ចៅក្រម និងព្រះរាជអាជ្ញាគួរតែទទួលនូវវគ្គបណ្តុះបណ្តាលជាក់លាក់ចំពោះបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌កុមារ ការបណ្តុះបណ្តាលនេះគួរតែអនុវត្តរួមគ្នាដោយក្រសួងយុត្តិធម៌ និងគណៈមេធាវីកម្ពុជា។

ឧទាហរណ៍ ដរាបណាដែលអាចធ្វើទៅបាននៅក្នុងតុលាការដែលមានបន្ទប់សវនាការច្រើនដែលប្រព្រឹត្តនៅក្នុងពេលតែមួយបាន បន្ទប់សវនាការដាច់ដោយឡែកមួយគួរតែលៃទុកដើម្បីដោះស្រាយដាច់តែឯងចំពោះករណីដែលពាក់ព័ន្ធនឹងអនីតិជន។ ពុំគួរអនុញ្ញាតឲ្យមានការចូលជាសាធារណៈនោះទេ (ដែលអនុញ្ញាតឲ្យចូលបានតែឪពុកម្តាយ/អាណាព្យាបាលរបស់ជនជាប់ចោទជាអនីតិជន) និងគួរតែអនុវត្តនូវការរឹតត្បិតមួយចំនួនពាក់ព័ន្ធនឹងការធ្វើសេចក្តីរាយការណ៍។ នៅពេលដែលមិនអាចលៃទុកបន្ទប់សវនាការដាច់ដោយឡែកបាននោះ សាធារណជនពុំគួរអនុញ្ញាតឲ្យចូលស្តាប់សវនាការ ហើយឈ្មោះឬសេចក្តីលម្អិតបញ្ជាក់ពីអត្តសញ្ញាណដទៃទៀតរបស់កុមារ មិនត្រូវបង្ហាញនៅលើក្តារប្រកាសព័ត៌មានជាសាធារណៈនោះឡើយ។

ច្បាប់ស្តីពីយុត្តិធម៌របស់កុមារ គួរតែដាក់បញ្ចូលនូវបទប្បញ្ញត្តិដាច់ដោយឡែកពាក់ព័ន្ធនឹងការធានាឲ្យនៅក្រៅឃុំ ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមតុលាការ និងការឃុំខ្លួនបណ្តោះអាសន្នទៅលើអនីតិជន។ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច គួរតែអនុវត្តឲ្យមានជាផ្នែកគាំទ្រដាច់ដោយឡែកដែលបម្រើជាពិសេសដល់តម្រូវការរបស់ជនជាប់ចោទជាអនីតិជន។

អនីតិជនទាំងអស់ត្រូវផ្តល់សិទ្ធិឲ្យមាននីតិជនដ៏សមរម្យ (ឪពុកម្តាយ អាណាព្យាបាល ឬក៏បុគ្គលសមរម្យដទៃទៀតមានអាយុចាប់ពី ១៨ឆ្នាំឡើង) មានវត្តមានក្នុងអំឡុងពេលការសាកសួររបស់នគរបាល និងនៅគ្រប់ដំណើរការសវនាការរបស់តុលាការ។

ជម្រើសនៃការផ្តន្ទាទោសលើអនីតិជនត្រូវតែធ្វើឲ្យមានលក្ខណៈទូលំទូលាយ។ ក្រសួងយុត្តិធម៌ដែលគាំទ្រដោយក្រសួងសង្គមកិច្ច គួរតែអនុវត្តសេចក្តីណែនាំនៃការផ្តន្ទាទោសពាក់ព័ន្ធនឹងអនីតិជន ដែលថាបញ្ហាដែលត្រូវផ្តោតជាសំខាន់ គឺថាត្រូវធ្វើលើការកែប្រែនីតិសម្បទាឲ្យបានរឹងមាំប្រសើរជាងការពិន័យតែម្យ៉ាង។ ការដាក់ពន្ធនាគារលើកុមារត្រូវតែបញ្ចៀសនៅគ្រប់ស្ថានភាពទាំងអស់ ហើយគួរតែត្រូវបានអនុវត្តនៅក្នុងករណីធ្ងន់ធ្ងរតែប៉ុណ្ណោះ នៅពេលដែលទម្រង់នៃការផ្តន្ទាទោសដទៃទៀតបានប្រើប្រាស់អស់ហើយ ឬនៅពេលដែលការដាក់ពន្ធនាគារគឺជាហេតុផលចាំបាច់សម្រាប់ការពារជាសាធារណៈ។

ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច គួរអនុវត្តនូវផែនការពហុចម្រុះ ដែលជនល្មើសជាអនីតិជនត្រូវបានគាំទ្រ និងផ្តល់ការស្តារនីតិសម្បទានៅក្នុងសហគមន៍ជាជម្រើសក្នុងការកាត់ទោសជាផ្លូវការ។ ផែនការនេះត្រូវតែអនុវត្តលើជនល្មើសដែលប្រព្រឹត្តលើកដំបូងបង្អស់ ដោយលើកលែងតែបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ខែធ្នូ ឆ្នាំ២០១៣
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

# ៥. គន្ថនិទ្ទេស

## នីតិអន្តរជាតិ

### សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

ក្រុមប្រឹក្សាសហភាពអឺរ៉ុប៖ *អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស*ចុះថ្ងៃទី០៤ខែវិច្ឆិកា ឆ្នាំ១៩៥០។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាប្រឆាំងនឹងទារុណកម្មនិងការប្រព្រឹត្តអំពើឃោរ-ឃៅ អមនុស្សធម៌ឬបន្ថោកបន្ទាបបុទ្គលកម្ម* ចុះថ្ងៃទី១០ខែធ្នូ ឆ្នាំ១៩៨៤។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *អនុសញ្ញាស្តីពីសិទ្ធិកុមារ*ចុះថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ១៩៨៩។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ-បាយ* ចុះថ្ងៃទី១៦ខែធ្នូ ឆ្នាំ១៩៦៦។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងទារុណកម្មអនុគណៈកម្មាធិការបង្ការទារុណកម្ម*នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៧។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

### ឧបករណ៍ច្បាប់អន្តរជាតិដទៃទៀត

